**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ**
**និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**

# របាយការណ៍កម្មសិក្សាបញ្ចប់ការសិក្សា

# ការលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល របស់ធនាគារជាតិ នៃ កម្ពុជា

កម្មសិក្សាចាប់ពីថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០១៩ ដល់ថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ២០១៩

ឈ្មោះស្ថាប័ន៖ **ធនាគារជាតិ នៃ កម្ពុជា**

តាក់តែងឡើងដោយ
និស្សិតឈ្មោះ **ម៉ៅ សុមុន្នី**
**រិត ស្រីឡែន**

សាស្ត្រាចារ្យណែនាំ
បណ្ឌិត **ហួន ប៉ូលី**

ថ្នាក់បរិញ្ញាបត្រ ធនាគារ និងហិរញ្ញវត្ថុ
ជំនាន់ទី១២

ឆ្នាំចូលសិក្សា ២០១៥
ឆ្នាំសរសេររបាយការណ៍ ២០១៩

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំជានិស្សិតជំនាន់ទី១២ ជំនាញធនាគារ និងហិរញ្ញវត្ថុ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច មហាវិទ្យាល័យ វិទ្យាសាស្ត្រសេដ្ឋកិច្ច និងគ្រប់គ្រង ឆ្នាំសិក្សា២០១៨-២០១៩ ដូចមានរាយនាមខាងក្រោម៖

**១. លោក មៅ សុមុន្នី**

**២. កញ្ញា រិត ស្រីឡែន**

**សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ៖**

-លោកឪពុក អ្នកម្តាយ ដែលបានផ្តល់កំណើតដល់កូន និងខិតខំជំនះរាល់ឧបសគ្គទាំងឡាយ ដើម្បីថែរក្សាដល់កូនព្រមទាំងផ្គត់ផ្គង់ជាសម្ភារៈ និងថវិកាដល់ការសិក្សារបស់កូនជាដរាបរៀងមក។

**-ឯកឧត្តម បណ្ឌិត លុយ ចណ្ណា** សាកលវិទ្យាធិការ សាកលវិទ្យាធិការរង និងសាស្ត្រាចារ្យទាំងអស់ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យសាស្ត្រសេដ្ឋកិច្ច និងជាពិសេស **លោក សាស្ត្រាចារ្យ បណ្ឌិត ឃួន ម៉ូលី** ដែលជាសាស្ត្រាចារ្យដឹកនាំ បានយកចិត្តទុកដាក់ខិតខំបង្ហាត់បង្រៀន ណែនាំ និងផ្តល់ជាឯកសារដល់យើងខ្ញុំទាំងអស់គ្នា។

**-ឯកឧត្តម ទេសាភិបាល ធនាគារជាតិនៃកម្ពុជា** និងមន្ត្រី បុគ្គលិកទាំងអស់ដែលបានអនុញ្ញាតឱ្យយើងខ្ញុំបានចុះធ្វើកម្មសិក្សាដោយបានផ្តល់ឯកសារ និងធ្វើបទសម្ភាសន៍ដើម្បីប្រមូលទិន្នន័យចងក្រងរបាយការណ៍កម្មសិក្សានេះឡើង។

យើងខ្ញុំសូមជូនពរឱ្យលោកអ្នកមានគុណទាំងអស់ បានជួបប្រទះតែនឹងពុទ្ធពរទាំង៤ប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

យើងខ្ញុំជានិស្សិតជំនាន់ទី១២ ជំនាញធនាគារ និងហិរញ្ញវត្ថុ នៃសាកលវិទ្យាល័យ ភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច មហាវិទ្យាល័យ វិទ្យាសាស្ត្រសេដ្ឋកិច្ច និងគ្រប់គ្រង ឆ្នាំសិក្សា២០១៨-២០១៩ បានធ្វើការស្រាវជ្រាវ និងចងក្រងឯកសារកម្មសិក្សានេះឡើងក្នុងគោលបំណងដើម្បីពង្រីកនូវចំណេះដឹង និងស្វែងយល់បន្ថែមឱ្យកាន់តែច្បាស់ទៅលើវិស័យធនាគារទាំងទ្រឹស្តី និងការអនុវត្តជាក់ស្តែង ដែលបានឆ្លងកាត់តាមរយៈការសិក្សានៅសាកលវិទ្យាល័យអស់រយៈពេលបួនឆ្នាំកន្លងមក។

ដោយសង្កេតឃើញពីកំណើនឥតឈប់ឈរនៃលំហូរចូលរូបិយប័ណ្ណបរទេស ព្រមទាំងវត្តមានដ៏ច្រើនសន្ធឹកសន្ធាប់នៃរូបិយប័ណ្ណនៅកម្ពុជា ជាពិសេស ប្រាក់ដុល្លារអាមេរិក យើងខ្ញុំបានសម្រេចធ្វើការសិក្សាលើផលវិជ្ជមាន និងអវិជ្ជមាននៃបញ្ហាដុល្លារូបនីយកម្ម ជាមួយនិងការអនុវត្តយុទ្ធសាស្ត្រលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល ដើម្បីកាត់បន្ថយការប្រើប្រាស់រូបិយប័ណ្ណបរទេសនៅក្នុងសេដ្ឋកិច្ច។

ដើម្បីសម្រេចបានជោគជ័យនៅក្នុងការរៀបចំជាសៀវភៅនេះឡើង យើងខ្ញុំបានខិតខំស្រាវជ្រាវតាមរយៈការចុះកម្មសិក្សានៅធនាគារជាតិនៃកម្ពុជាស្នាក់ការកណ្តាល អស់រយៈពេលជាងមួយខែ ព្រមទាំងមានការជួយជ្រោមជ្រែងពន្យល់ ណែនាំ និងការផ្តល់មតិយោបល់ល្អៗពីសំណាក់សាស្ត្រាចារ្យដឹកនាំ។

ប្រធានបទ "ការលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលរបស់ធនាគារជាតិនៃកម្ពុជា" នេះ គឺជាគំនិតស្តួចស្តើងមួយដែលលេចឡើងជារូបរាង ដោយសារការខិតខំប្រឹងប្រែងរបស់ក្រុមយើងខ្ញុំដែលនឹងអាចជាទុនមួយសម្រាប់និស្សិតជំនាន់ក្រោយៗ ទុកជាគំរូឯកសារក្នុងការស្រាវជ្រាវបន្តទៀត។

យើងខ្ញុំជឿជាក់ថា ឯកសារកម្មសិក្សានេះប្រាកដជាពុំទាន់មានលក្ខណៈគ្រប់ជ្រុងជ្រោយនៅឡើយទេ តែទោះជាយ៉ាងណា យើងខ្ញុំសង្ឃឹមថា និស្សិតនិងមិត្តអ្នកអានទាំងអស់ពិតជាមានការយោគយល់អធ្យាស្រ័យនូវរាល់កំហុសឆ្គងទាំងឡាយ ដែលកើតមានឡើងដោយអចេតនា។ យើងខ្ញុំសូមស្វាគមន៍នូវរាល់មតិរិះគុណក្នុងន័យស្ថាបនាពីសំណាក់បងប្អូននិស្សិត និងមិត្តអ្នកអានទាំងឡាយ ហើយយើងខ្ញុំរីករាយនឹងធ្វើការកែតម្រូវទៅលើរាល់លក្ខណៈខ្វះខាតនានារបស់ប្រធានបទខាងលើ។

# មាតិកា

បញ្ជីអក្សរកាត់ ............ iv
វាក្យស័ព្ទធនាគារ ............ v
បញ្ជីតារាង............ viii
បញ្ជីរូបភាព ............ ix
បញ្ជីក្រាហ្វិក ............ x
បញ្ជីឧបសម្ព័ន្ធ ............ xi

# សេចក្តីផ្តើម

១. លំនាំបញ្ហានៃការស្រាវជ្រាវ............ ១
២. ចំណោទបញ្ហានៃការស្រាវជ្រាវ ............ ២
៣. គោលបំណងនៃការស្រាវជ្រាវ ............ ២
៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ ............ ៣
ក. ទំហំនៃការស្រាវជ្រាវ............ ៣
ខ. ដែនកំណត់នៃការស្រាវជ្រាវ ............ ៣
៥. វិធីសាស្ត្រក្នុងការស្រាវជ្រាវ............ ៣
ក. ប្រភពទិន្នន័យ ............ ៣
ខ. វិធីសាស្ត្រប្រមូលទិន្នន័យ ............ ៤
គ. វិធីសាស្ត្រវិភាគទិន្នន័យ............ ៤
៦. សារសំខាន់នៃការស្រាវជ្រាវ............ ៤
ក. សារសំខាន់សម្រាប់អ្នកសិក្សាស្រាវជ្រាវ និងអ្នកសិក្សាជំនាន់ក្រោយ............ ៤
ខ. សារសំខាន់សម្រាប់វិស័យធនាគារ............ ៥
គ. សារសំខាន់ចំពោះសង្គមជាតិ ............ ៥
៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ............ ៦

# ជំពូកទី១

# រំលឹកទ្រឹស្តី

១.១. និយមន័យ និងប្រតិបត្តិការរបស់ធនាគារកណ្តាល ............ ៨
១.២. រូបិយវត្ថុ............ ៩

១.២.១. មុខងារនៃរូបិយវត្ថុ ........................................................................................ ៩
១.២.១.១. មធ្យោបាយនៃការទូទាត់ ........................................................................ ៩
១.២.១.២. ឯកតាគណនី ........................................................................................ ៩
១.២.១.៣. ការរក្សាតម្លៃ .......................................................................................... ៩
១.២.១.៤. ស្តង់ដារនៃការទូទាត់ពន្យាពេល ........................................................... ១០
១.២.២. ទម្រង់នៃរូបិយវត្ថុ ...................................................................................... ១០
១.២.៣. លក្ខណៈពិសេសនៃរូបិយវត្ថុ ........................................................................ ១០
១.៣. និយមន័យដុល្លារូបនីយកម្ម ............................................................................... ១១
១.៤. ទម្រង់នៃដុល្លារូបនីយកម្ម .................................................................................. ១៣
១.៤.១. ដុល្លារូបនីយកម្មរូបវន្ត ................................................................................. ១៣
១.៤.២. ដុល្លារូបនីយកម្មប្រតិបត្តិការ ......................................................................... ១៣
១.៤.៣. ដុល្លារូបនីយកម្មហិរញ្ញវត្ថុ ............................................................................ ១៣

## ជំពូកទី២

## ស្ថានភាពទូទៅរបស់ធនាគារជាតិ នៃ កម្ពុជា

២.១. ប្រវត្តិនៃការកកើត និងការវិវឌ្ឍរបស់ធនាគារជាតិនៃកម្ពុជា ......................................... ១៤
២.១.១. ដំណាក់កាលឯករាជ្យភាពនិងការបង្កើតឡើងវិញ (១៩៥៤ - ១៩៦៤)................. ១៤
២.១.២. ដំណាក់កាលរបបខ្មែរក្រហម (១៩៧៥ - ១៩៧៩)............................................ ១៥
២.១.៣. ដំណាក់កាលកសាងធនាគារជាតិនៃកម្ពុជាឡើងវិញ (១៩៧៩ - ១៩៩៣).......... ១៧
២.១.៤. ដំណាក់កាលទំនើបភាវូនីយកម្មប្រព័ន្ធធនាគារ (១៩៩៣ ដល់ បច្ចុប្បន្ន).............. ១៨
២.២. ទីតាំងភូមិសាស្ត្រ និងសាខារបស់ធនាគារជាតិនៃកម្ពុជា ............................................ ១៨
២.៣. អត្តសញ្ញាណរបស់ធនាគារជាតិនៃកម្ពុជា ............................................................... ២២
២.៤. បេសកកម្ម មុខងារ និងតួនាទីរបស់ធនាគារជាតិនៃកម្ពុជា .......................................... ២២
២.៥. រចនាសម្ព័ន្ធរបស់ធនាគារជាតិនៃកម្ពុជា .................................................................. ២៣
២.៥.១. រចនាសម្ព័ន្ធការងារ ...................................................................................... ២៣
២.៥.២. ក្រុមប្រឹក្សាភិបាល ....................................................................................... ២៥
២.៥.៣. ស្ថិតិមន្ត្រីបុគ្គលិក ......................................................................................... ២៦

# ជំពូកទី៣
# លទ្ធផលនៃការស្រាវជ្រាវ

៣.១. មូលហេតុ និងឫសគល់នៃការបាត់បង់ទំនុកចិត្តមកលើប្រាក់រៀល.............................២៨
៣.២. គុណសម្បត្តិ និងគុណវិបត្តិនៃដុល្លារូបនីយកម្ម.......................................................៣១
៣.៣. ស្ថានភាពដុល្លារូបនីយកម្មនៅកម្ពុជា .....................................................................៣៤
៣.៤. ចក្ខុវិស័យ និងក្របខ័ណ្ឌគោលនយោបាយរបស់រាជរដ្ឋាភិបាល.................................៤៨
៣.៥. យុទ្ធសាស្ត្រលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល.......................................................៥១
៣.៥.១. គោលនយោបាយរូបិយវត្ថុ និងអត្រាប្តូរប្រាក់ ....................................................៥១
៣.៥.២. គោលនយោបាយសារពើពន្ធ ..........................................................................៥២
៣.៥.៣. គោលនយោបាយពាណិជ្ជកម្ម...........................................................................៥៣
៣.៥.៤. គោលនយោបាយហិរញ្ញវត្ថុ និងក្របខ័ណ្ឌបទប្បញ្ញត្តិប្រុងប្រយ័ត្ន.......................៥៥
៣.៥.៥. គោលនយោបាយអភិវឌ្ឍន៍ទីផ្សារ ....................................................................៥៧
៣.៥.៦. ការអភិវឌ្ឍប្រព័ន្ធទូទាត់.................................................................................៥៩
៣.៥.៧. ការលើកកម្ពស់ការយល់ដឹង និងការចូលរួម.....................................................៦០
៣.៥.៨. កិច្ចសហប្រតិបត្តិការដើម្បីអនុវត្តវិធានការប្រកបដោយប្រសិទ្ធភាព.....................៦០
៣.៥.៩. គោលនយោបាយគាំទ្រនានា............................................................................៦១
៣.៦. សារសំខាន់នៃប្រាក់រៀល ......................................................................................៦២
៣.៧. ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ ..............................................................៦៩
៣.៧.១. ការវិភាគលើចំណុចខ្លាំង.................................................................................៦៩
៣.៧.២. ការវិភាគលើចំណុចខ្សោយ..............................................................................៦៩

# សេចក្តីសន្និដ្ឋាន និងអនុសាសន៍

១. សេចក្តីសន្និដ្ឋាន.......................................................................................................៧១
២. អនុសាសន៍ ...............................................................................................................៧២
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# បញ្ជីអក្សរកាត់

| | |
|---|---|
| ATM | Automated Teller Machine (ម៉ាស៊ីនដក និងដាក់ប្រាក់ដោយស្វ័យប្រវត្តិ) |
| AMRO | ASEAN+3 Macroeconomic Research Office (ការិយាល័យស្រាវជ្រាវម៉ាក្រូសេដ្ឋកិច្ចអាស៊ាន+៣) |
| CCB | Cambodia Commercial Bank (ធនាគារពាណិជ្ជកម្ពុជា) |
| FCD | Foreign Currency Deposit (ប្រាក់បញ្ញើជារូបិយប័ណ្ណ) |
| GDP | Gross Domestic Product (ផលិតផលក្នុងស្រុកសរុប) |
| IMF | International Monetary Fund (មូលនិធិរូបិយវត្ថុអន្តរជាតិ) |
| JICA | Japan International Cooperate Agency (ភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន) |
| LPCO | Liquidity-Providing Collateralized Operation (ប្រតិបត្តិការផ្តល់សន្ទនីយភាពជាប្រាក់រៀលដោយមានការធានា) |
| MDI | Microfinance Deposit Taking Institutions (គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ) |
| NCD | Negotiable Certificate of Deposit (មូលបត្រអាចជួញដូរបាន) |
| UNTAC | United Nations Transitional Authorities in Cambodia (អាជ្ញាធរបណ្តោះអាសន្នរបស់អង្គការសហប្រជាជាតិនៅកម្ពុជា) |
| ផ.ស.ស | ផលិតផលក្នុងស្រុកសរុប |

# វាក្យស័ព្ទធនាគារ

| | |
|---|---|
| **-រូបិយវត្ថុទូទៅ** | ៖ គឺជាការរួមបញ្ចូលនៃរូបិយវត្ថុដែលកាន់កាប់ដោយសាធារណជន និងប្រាក់បញ្ញើដែលសាធារណជនដាក់ផ្ញើនៅធនាគារពាណិជ្ជ។ |
| **-អត្រាប្តូរប្រាក់** | ៖ គឺជាតម្លៃរូបិយវត្ថុរបស់ប្រទេសមួយធៀបនឹងរូបិយប័ណ្ណរបស់ប្រទេសដទៃទៀត។ |
| **-ទុនបម្រុងអន្តរជាតិ** | ៖ សំដៅលើទ្រព្យសម្បត្តិជារូបិយប័ណ្ណដែលកាន់កាប់ដោយធនាគារកណ្តាលនៃប្រទេសមួយ។ ទ្រព្យសម្បត្តិទាំងនោះរួមមាន សញ្ញាប័ណ្ណទីផ្សារអន្តរជាតិ មាស និងទុនបម្រុងនៅមូលនិធិរូបិយវត្ថុអន្តរជាតិ។ គោលបំណងនៃការកាន់កាប់ទុនបម្រុងអន្តរជាតិ គឺដើម្បីធ្វើការទូទាត់ជាលក្ខណៈអន្តរជាតិ និងការពារនូវហានិភ័យអត្រាប្តូរប្រាក់។ |
| **-អតិផរណា** | ៖ ជាការកើនឡើងកម្រិតថ្លៃជាទូទៅនៃទំនិញ និងសេវាក្នុងសេដ្ឋកិច្ច។ វាត្រូវបានគណនាជាភាគរយ និងវាស់វែងកំណើនជា ខែ ត្រីមាស និងឆ្នាំ។ |
| **-អត្រាការប្រាក់** | ៖ គឺអត្រាដែលការប្រាក់ត្រូវបានបង់ដោយអ្នកខ្ចីសម្រាប់ប្រាក់ដែលបានខ្ចីពីអ្នកផ្តល់កម្ចី។អត្រាការប្រាក់ជាធម្មតាត្រូវបានគិតជាភាគរយនៅក្នុងរយៈពេលមួយឆ្នាំ។ |
| **-មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF)** | ៖ អង្គការអន្តរជាតិ ដែលបានបង្កើតឡើងនៅក្នុងឆ្នាំ១៩៤៥ ក្នុងគោលបំណងលើកកម្ពស់ស្ថិរភាពហិរញ្ញវត្ថុអន្តរជាតិ និង សហប្រតិបត្តិការរូបិយវត្ថុ ជួយសម្របសម្រួលពាណិជ្ជកម្មអន្តរជាតិ និងជំរុញអនិកម្មភាព កំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព និងកាត់បន្ថយភាពក្រីក្រក្នុងពិភពលោក។ |

-ភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន ៖ អង្គការបានបង្កើតឡើងក្នុងឆ្នាំ២០០៣ ដើម្បីចូលរួមក្នុងការជំរុញសហប្រតិបត្តិការអន្តរជាតិ ក៏ដូចជាអភិវឌ្ឍន៍សេដ្ឋកិច្ចប្រទេសជប៉ុន និងសកលលោកតាមរយៈការជ្រោមជ្រែង ការអភិវឌ្ឍសេដ្ឋកិច្ចសង្គម ការងើបឡើងវិញ ឬស្ថិរភាពសេដ្ឋកិច្ចក្នុងប្រទេសកំពុងអភិវឌ្ឍន៍។

-អ្នកឱ្យខ្ចីចុងក្រោយ ៖ មុខងាររបស់ធនាគារកណ្តាលក្នុងការផ្តល់ឥណទានដល់ធនាគារ ដើម្បីដោះស្រាយបញ្ហាសន្ទនីយភាពដែលបណ្តាលមកពីភាពខុសគ្នានៃមូលនិធិ និងដើម្បីទប់ស្កាត់វិបត្តិសាច់ប្រាក់ងាយស្រួល។

-សន្ទនីយភាព ៖ កម្រិតដែលទ្រព្យសកម្ម ឬសញ្ញាប័ណ្ណ អាចត្រូវបានទិញ ឬលក់នៅក្នុងទីផ្សារ ដោយពុំមានការប៉ះពាល់ដល់តម្លៃនៃទ្រព្យសកម្មនោះ។ ទ្រព្យសកម្មដែលមានភាពងាយស្រួលក្នុងការទិញឬលក់ អាចចាត់ទុកជាទ្រព្យសកម្មដែលមានសន្ទនីយភាព។ សន្ទនីយភាពឆ្លុះបញ្ចាំងពីសមត្ថភាពនៅក្នុងការបម្លែងទ្រព្យសកម្មមួយឱ្យទៅជាសាច់ប្រាក់។

-មូលបត្រអាចជួញដូរបាន ៖ បំណុលមានការប្រាក់រយៈពេលខ្លី បោះផ្សាយដោយធនាគារកណ្តាល ត្រូវបានកំណត់ជាប្រាក់រៀល និងដុល្លារអាមេរិកក្នុងតម្លៃប្រមាណ ២.០០០ លានរៀល។

-ស្ថិរភាពថ្លៃ ៖ ស្ថានភាពមួយដែលថ្លៃនៅក្នុងសេដ្ឋកិច្ចមួយមិនមានការប្រែប្រួលខ្លាំង ក្នុងរយៈពេលណាមួយ។ ស្ថិរភាពថ្លៃអាចមានន័យថាសេដ្ឋកិច្ចមិនជួបប្រទះអតិផរណាឬបរិត្តផរណាខ្ពស់។

-ប្រាក់បម្រុងកាតព្វកិច្ច ៖ ចំនួននៃប្រាក់បញ្ញើ ដែលធនាគារពាណិជ្ជត្រូវរក្សាទុកក្នុងទម្រង់ជាសាច់ប្រាក់សុទ្ធ ឬជាបញ្ញើ

ជាមួយធនាគារកណ្ដាល។ ធនាគារកណ្ដាល គឺជានិយ័តករ ដែលអាចកំណត់ប្រាក់បម្រុងកាតព្វកិច្ច។ ធនាគារកណ្ដាល ប្រើប្រាស់ប្រាក់បម្រុងកាតព្វកិច្ចជាមធ្យោបាយគ្រប់គ្រងសន្ទនីយភាពក្នុងទីផ្សារ។ ប្រាក់បម្រុងកាតព្វកិច្ចទាបអនុញ្ញាតឱ្យមានសន្ទ-នីយភាពខ្ពស់ក្នុងប្រព័ន្ធធនាគារ។ ប្រាក់បម្រុងកាតព្វកិច្ចខ្ពស់ ធ្វើឱ្យមានសន្ទនីយភាពទាប។

**-គណៈកម្មការអត្រាប្ដូរប្រាក់ផ្លូវការ** ៖ អត្រាប្ដូរប្រាក់របស់ធនាគារជាតិនៃកម្ពុជា ត្រូវបានកំណត់ដោយគណៈកម្មការអត្រាប្ដូរប្រាក់ផ្លូវការរបស់ធនាគារជាតិនៃកម្ពុជា ដែលមានសមាជិកមកពី នាយកដ្ឋានពាក់ព័ន្ធដូចជា នាយកដ្ឋានបោះផ្សាយ នាយកដ្ឋានប្រតិបត្តិការ នាយកដ្ឋានគ្រប់គ្រងការប្ដូរប្រាក់ នាយកដ្ឋានស្ថិតិ និងនាយក-ដ្ឋានស្រាវជ្រាវសេដ្ឋកិច្ចនិងសហប្រតិបត្តិការអន្តរ-ជាតិ ។

**-គណៈកម្មការគោលនយោបាយរូបិយវត្ថុ** ៖ ជាគណៈកម្មការគោលនយោបាយជាន់ខ្ពស់ នៅធនាគារជាតិនៃកម្ពុជា ត្រូវបានបង្កើតឡើង ដើម្បីវាយតម្លៃការអភិវឌ្ឍសេដ្ឋកិច្ច និងហិរញ្ញវត្ថុរបស់ប្រទេស និងជាអ្នកសម្រេចគោលនយោបាយរូបិយវត្ថុ ក្នុងគោលបំណងរក្សាស្ថិរភាពថ្លៃ ។

# បញ្ជីតារាង

តារាងទី២.១ ៖ រចនាសម្ព័ន្ធការងាររបស់ធនាគារជាតិនៃកម្ពុជា ........................................២៤
តារាងទី២.២ ៖ ស្ថិតិមន្រ្តី-បុគ្គលិកធនាគារជាតិនៃកម្ពុជាប្រចាំឆ្នាំ២០១៨............................២៦
តារាងទី៣.១ ៖ ការប៉ាន់ស្មានការខាតបង់ចំណូលពីការបោះពុម្ពក្រដាសប្រាក់នៅកម្ពុជា
(១៩៩៤-២០០១)........................................................................................ ៣៩

# បញ្ជីរូបភាព


រូបភាពទី១ ៖ ម៉ូដែលនៃការស្រាវជ្រាវ ........ ៧

រូបភាពទី២.១ ៖ អគារធនាគារជាតិនៃកម្ពុជា នាសម័យសង្គមរាស្ត្រនិយម ........ ១៥

រូបភាពទី២.២ ៖ អគារធនាគារជាតិនៃកម្ពុជាត្រូវបានបំផ្លាញដោយរបបខ្មែរក្រហម ........ ១៦

រូបភាពទី២.៣ ៖ អគារស្នាក់ការកណ្តាលធនាគារជាតិនៃកម្ពុជា ........ ១៩

រូបភាពទី២.៤ ៖ និមិត្តសញ្ញារបស់ធនាគារជាតិនៃកម្ពុជា ........ ២២

រូបភាពទី២.៥ ៖ ក្រុមប្រឹក្សាភិបាលធនាគារជាតិនៃកម្ពុជា ........ ២៥

# បញ្ជីក្រាហ្វិក


ក្រាហ្វទី២.១ ៖ ស្ថិតិមន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជាតាមកម្រិតវប្បធម៌ ........................ ២៧

ក្រាហ្វទី៣.១ ៖ សមាសធាតុនិងកំណើនរូបិយវត្ថុទូទៅ(ឆ្នាំ២០០៨-២០១៨)...................... ៣៥

ក្រាហ្វទី៣.២ ៖ អត្រាប្តូរប្រាក់រៀលធៀបនឹងដុល្លារអាមេរិក(ឆ្នាំ២០១៦-២០១៨) ..............៣៧

ក្រាហ្វទី៣.៣ ៖ ភាពស៊ីជម្រៅផ្នែកហិរញ្ញវត្ថុនិងដុល្លារូបនីយកម្ម(២០០៨-២០១៨)............ ៣៨

ក្រាហ្វទី៣.៤ ៖ ប្រាក់បញ្ញើជារៀលនិងរូបិយវត្ថុក្នុងចរាចរណ៍(ឆ្នាំ២០០៨-២០១៨)............ ៣៨

ក្រាហ្វទី៣.៥ ៖ កម្រិតដុល្លារូបនីយកម្មតាមប្រភពនិងកម្រិតចំណូល(អង្គភាពគ្រួសារ) ....... ៤១

ក្រាហ្វទី៣.៦ ៖ សមាសធាតុរូបិយវត្ថុក្នុងចំណូលតាមតំបន់(អង្គភាពគ្រួសារ) ....................៤២

ក្រាហ្វទី៣.៧ ៖ សមាសធាតុរូបិយវត្ថុក្នុងចំណាយតាមតំបន់(អង្គភាពគ្រួសារ) ..................៤២

ក្រាហ្វទី៣.៨ ៖ ប្តូរប្រាក់(អង្គភាពគ្រួសារ) .................................................................... ៤៣

ក្រាហ្វទី៣.៩ ៖ សមាសធាតុរូបិយវត្ថុក្នុងឥណទានតាមតំបន់......................................... ៤៣

ក្រាហ្វទី៣.១០ ៖ សមាសធាតុរូបិយវត្ថុក្នុងចំណូល(សហគ្រាស) ........................................ ៤៤

ក្រាហ្វទី៣.១១ ៖សមាសធាតុរូបិយវត្ថុក្នុងចំណាយ (សហគ្រាស)........................................ ៤៤

ក្រាហ្វទី៣.១២ ៖ សមាសធាតុរូបិយវត្ថុក្នុងចំណូល ........................................................... ៤៦

ក្រាហ្វទី៣.១៣ ៖ សមាសធាតុរូបិយវត្ថុក្នុងចំណាយ......................................................... ៤៦

ក្រាហ្វទី៣.១៤ ៖ សមាសធាតុរូបិយវត្ថុក្នុងចំណូល ......................................................... ៤៧

ក្រាហ្វទី៣.១៥ ៖ សមាសធាតុរូបិយវត្ថុក្នុងចំណាយ......................................................... ៤៧

# បញ្ជីឧបសម្ព័ន្ធ

ឧបសម្ព័ន្ធទី១ ៖ ឯកសារកម្មសិក្សា

ឧបសម្ព័ន្ធទី២ ៖ កម្រងសំណួរ

ឧបសម្ព័ន្ធទី៣ ៖ ប្រាក់រៀលធៀបជាមួយរូបិយប័ណ្ណផ្សេងៗ

ឧបសម្ព័ន្ធទី៤ ៖ ស្ថានភាពរូបិយវត្ថុ

ឧបសម្ព័ន្ធទី៥ ៖ អនុសាសន៍លើផែនការសកម្មភាពការលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

ប្រទេសកម្ពុជាក្នុងកំឡុងរបបខ្មោងងឹតប្រល័យពូជសាសន៍ ការប្រើប្រាស់រូបិយវត្ថុត្រូវបានលុបចោលទាំងស្រុង។ លុះមកដល់ឆ្នាំ ១៩៧៩ ទើបប្រទេសកម្ពុជាចាប់ផ្តើមទទួលបានសន្តិភាពមកវិញ ប៉ុន្តែសន្តិភាពនេះនៅមិនទាន់ពេញបរិបូរណ៍នោះទេ។ នៅឆ្នាំ១៩៨០ រូបិយវត្ថុជាតិត្រូវបានដាក់ឱ្យចរាចរឡើងវិញ ក៏ប៉ុន្តែទោះជាយ៉ាងណាក្តី ប្រព័ន្ធធនាគារនៅតែមិនទាន់មានភាពរឹងមាំនៅឡើយ ជំនឿទុកចិត្តរបស់សាធារណជនមកលើប្រាក់រៀលក៏នៅមានកម្រិតទាប និងស្តួចស្តើងផងដែរ។ បញ្ហាអតិផរណានិងអស្ថិរភាពរូបិយវត្ថុជាតិ បានធ្វើឱ្យមានការប្រើប្រាស់រូបិយប័ណ្ណបរទេសជំនួសឱ្យរូបិយវត្ថុនៅក្នុងស្រុក នៅក្នុងប្រតិបត្តិការសេដ្ឋកិច្ចនៅកម្ពុជា។

សេដ្ឋកិច្ចកម្ពុជាបានប្រឈមមុខនឹងបញ្ហាដុល្លារូបនីយកម្មដ៏ខ្ពស់ចាប់តាំងពីរបបខ្មែរក្រហមបានដួលរលំមកម្ល៉េះ។ យោងតាមមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) នៅកម្ពុជា ប្រាក់ដុល្លារត្រូវបានប្រើប្រាស់រហូតមកដល់បច្ចុប្បន្នដល់ទៅប្រមាណជាង ៨០% នៃបរិមាណសាច់ប្រាក់សរុបដែលចរាចរនៅលើទីផ្សារ ហើយខុសពីប្រទេសជិតខាង ដូចជាប្រទេសឡាវជាដើម ដែលការប្រើប្រាស់ប្រាក់ដុល្លារមានការថយចុះធៀបនឹងរូបិយវត្ថុជាតិ។ ក្រឡេកមកមើលពីនិន្នាការនៃការប្រើប្រាស់ប្រាក់ដុល្លារនៅកម្ពុជាវិញ ហាក់មិនទាន់មានការថយចុះទាល់តែសោះ បើទោះបីជាកម្ពុជារក្សាបានស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ហើយមានអត្រាអតិផរណាមិនខ្ពស់ហួសហេតុក៏ដោយ។ សេដ្ឋកិច្ចរបស់កម្ពុជាត្រូវពឹងផ្អែកមួយភាគធំទៅលើសហរដ្ឋអាមេរិក ពីព្រោះសហរដ្ឋអាមេរិកគឺជាទីផ្សារមួយដ៏សំខាន់របស់វិស័យឧស្សាហកម្មមួយចំនួនធំនៅកម្ពុជា។ ហេតុដូច្នេះហើយទើបបានជារូបិយវត្ថុអាមេរិកត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយនៅក្នុងប្រទេសកម្ពុជា សម្រាប់ការទូទាត់ដែលមានចំនួនធំ ហើយសូម្បីតែការចំណាយប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋនៅលើទីផ្សារក្នុងស្រុក ក៏អាស្រ័យលើក្រដាសប្រាក់នេះផងដែរ។ ប្រសិនបើសេដ្ឋកិច្ចរបស់សហរដ្ឋអាមេរិកជួបប្រទះនឹងវិបត្តិ នោះសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាក៏នឹងទទួលរងនូវផលប៉ះពាល់ពីវិបត្តិនេះផងដែរ ដោយសារតែបរិមាណនៃប្រាក់ដុល្លារអាមេរិកនៅកម្ពុជាមានចំនួនច្រើនជាងរូបិយវត្ថុក្នុងស្រុក។

ហេតុនេះហើយ រាជរដ្ឋាភិបាលចាំបាច់ត្រូវខិតខំរិះរកវិធានការទប់ស្កាត់ និងកាត់បន្ថយកម្រិតនៃដុល្លារូបនីយកម្ម ដើម្បីលើកស្ទួយប្រាក់រៀលខ្មែរ ក្នុងគោលបំណងរក្សាស្ថិរភាពរូបិយវត្ថុ បន្តកំណើនសេដ្ឋកិច្ច លើកស្ទួយអត្តសញ្ញាណជាតិ បង្កើនជំនឿទុកចិត្តលើរូបិយវត្ថុជាតិ និងបណ្តុះស្មារតីជាតិនិយមនៅក្នុងប្រទេស។ យុទ្ធសាស្ត្រលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល គឺជាយន្តការ

ដ៏សំខាន់ដែលត្រូវទទួលបានការយកចិត្តទុកដាក់ខ្ពស់ និងអនុវត្តប្រកបដោយភាពប្រុងប្រយ័ត្នពីសំណាក់ភាគីពាក់ព័ន្ធនានា ជាពិសេសធនាគារជាតិនៃកម្ពុជា និងរាជរដ្ឋាភិបាល។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

វត្តមាននៃដុល្លាររូបនីយកម្មនៅកម្ពុជា បានបណ្តាលឱ្យសេដ្ឋកិច្ចប្រទេសនេះពោរពេញទៅដោយលំហូរចរាចរនៃប្រាក់ដុល្លារដ៏ច្រើនលើសលប់។ ធនាគារជាតិនៃកម្ពុជាបានបាត់បង់តួនាទីសំខាន់ៗមួយចំនួនក្នុងនាមជាអាជ្ញាធររូបិយវត្ថុរបស់ប្រទេស ដោយសារតែបរិមាណប្រាក់ដុល្លារនៅក្នុងចរាចរមានចំនួនច្រើនសន្ធឹកសន្ធាប់ ហើយបរិមាណនៃប្រាក់រៀលមានចំនួនតិចតួចនៅឡើយ ដែលបណ្តាលឱ្យប្រសិទ្ធភាពនៃការអនុវត្តគោលនយោបាយរូបិយវត្ថុត្រូវបានកាត់បន្ថយ។ ភាពមិនច្បាស់លាស់នៃបរិមាណប្រាក់ដុល្លារកំពុងចរាចរនៅក្រៅប្រព័ន្ធធនាគារ គឺជាឧបសគ្គចម្បង ដែលរារាំងដល់ប្រសិទ្ធភាពនៃការអនុវត្តវិធានការលើកកម្ពស់ការប្រើប្រាស់ប្រាស់រៀល ដោយសារតែធនាគារជាតិនៃកម្ពុជាមិនអាចកំណត់ជាក់លាក់នូវកម្រិតដុល្លាររូបនីយកម្មបាន។

ហេតុដូចនេះហើយ តើធនាគារជាតិនៃកម្ពុជាមានវិធានការ និងយុទ្ធសាស្ត្របែបណាខ្លះនៅក្នុងការបង្កើនការប្រើប្រាស់រូបិយវត្ថុជាតិនៅកម្ពុជាឲ្យកាន់តែច្រើន?

តើមានភាគីពាក់ព័ន្ធណាខ្លះដែលត្រូវចូលរួមអនុវត្តនូវវិធានការ និងយុទ្ធសាស្ត្រលើកកម្ពស់ការប្រើប្រាស់រូបិយវត្ថុជាតិ?

ដើម្បីឱ្យការអនុវត្តយុទ្ធសាស្ត្រខាងលើទទួលបានប្រសិទ្ធភាពខ្ពស់ និងធានាឱ្យបាននូវស្ថិរ-ភាពម៉ាក្រូសេដ្ឋកិច្ច តើធនាគារជាតិនៃកម្ពុជា គួរដាក់ចេញនូវគោលនយោបាយគាំទ្រអ្វីខ្លះ?

## ៣. គោលបំណងនៃការស្រាវជ្រាវ

គោលបំណងសំខាន់នៅក្នុងការស្រាវជ្រាវលើប្រធានបទ គឺចង់ពង្រឹងឱ្យកាន់តែច្បាស់នូវការយល់ដឹងអំពីបញ្ហាដុល្លាររូបនីយកម្មនៅកម្ពុជា និងវិធានក្នុងការលើកកម្ពស់រូបិយវត្ថុជាតិ ដោយផ្តោតលើការសិក្សាពីចំណុចសំខាន់ៗមួយចំនួនដូចជា៖

- ស្ថានភាពទូទៅរបស់ធនាគារជាតិនៃកម្ពុជា
- ប្រវត្តិ និងស្ថានភាពដុល្លាររូបនីយកម្មនៅកម្ពុជា
- វិធានការទប់ស្កាត់និងកាត់បន្ថយការប្រើប្រាស់ប្រាក់ដុល្លារ របស់ធនាគារជាតិនៃកម្ពុជា
- ការវិភាគចំណុចវិជ្ជមាន និងអវិជ្ជមាននៃបញ្ហាដុល្លាររូបនីយកម្ម
- ប្រសិទ្ធភាពនៃការលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលកន្លងមក និងពេលបច្ចុប្បន្ន
- ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

### ក. ទំហំនៃការស្រាវជ្រាវ

ក្នុងការសិក្សាស្រាវជ្រាវប្រធានបទខាងលើនេះឱ្យបានជោគជ័យ និងមានប្រសិទ្ធភាពខ្ពស់ ក្រុមយើងខ្ញុំបានសម្រេចសិក្សា និងធ្វើការស្រាវជ្រាវផ្តោតសំខាន់ទៅលើទិន្នន័យនិងព័ត៌មានចម្បងនានារបស់ធនាគារជាតិនៃកម្ពុជា ហើយធ្វើការវិភាគទៅលើរបាយការណ៍ផ្សេងៗដែលបានធ្វើឡើងសម្រាប់ប្រធានបទនេះតែប៉ុណ្ណោះ។ ដោយសារតែធនាគារជាតិនៃកម្ពុជាមានទីតាំង និងសាខាច្រើនកន្លែងនៅទូទាំងប្រទេស ទើបក្រុមយើងខ្ញុំសម្រេចធ្វើការសិក្សាលើឯកសាររបាយការណ៍ និងប្រមូលរាល់ទិន្នន័យសំខាន់ៗ នៅក្នុងស្នាក់ការកណ្តាលបណ្តោះអាសន្នរបស់ធនាគារជាតិនៃកម្ពុជា ដែលមានអាសយដ្ឋាន អគារលេខ៦៩-៧០ មហាវិថីហាណូយ លេខ(១០១៩) ភូមិប៉ាយាប សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ តែប៉ុណ្ណោះ។

### ខ. ដែនកំណត់នៃការសិក្សាស្រាវជ្រាវ

ដោយសារតែពេលវេលានៃការសិក្សាស្រាវជ្រាវនេះមានកំណត់ ដូច្នេះក្រុមយើងខ្ញុំបានសម្រេចកំណត់យកឯកសារ និងទិន្នន័យពាក់ព័ន្ធនានាដែលផ្តោតទៅលើការលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលរបស់ធនាគារជាតិនៃកម្ពុជានៅក្នុងចន្លោះឆ្នាំ២០១៥ ដល់ឆ្នាំ ២០១៨ ដើម្បីយកមកធ្វើការសិក្សាស្រាវជ្រាវតែប៉ុណ្ណោះ។

## ៥. វិធីសាស្ត្រក្នុងការស្រាវជ្រាវ

សម្រាប់ការស្រាវជ្រាវនេះដែរ គឺត្រូវបានសង្កត់ធ្ងន់ទៅលើយុទ្ធសាស្ត្រនានារបស់ធនាគារជាតិនៃកម្ពុជានៅក្នុងការលើកកម្ពស់ការប្រើប្រាស់រូបិយវត្ថុជាតិ។

### ក. ប្រភពទិន្នន័យ

**-ការសិក្សាស្រាវជ្រាវតាមរយៈឯកសារ និងគំនិតយោបល់ ដែលបានផ្តល់ដោយសាស្ត្រាចារ្យ ៖** គឺតាមរយៈចំណេះដឹង និងឯកសារនានាដែលទទួលបាន ពីសាស្ត្រាចារ្យតាមមុខវិជ្ជាទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានផ្តល់ និងបង្រៀនក្នុងរយៈពេលសិក្សាកន្លងមក។

**-ស្រាវជ្រាវតាមរយៈការអានគោលនយោបាយ និងឯកសារនានារបស់ធនាគារជាតិនៃកម្ពុជា ៖** រួមមានការសិក្សាស្វែងយល់ទៅលើកម្រងច្បាប់ ព្រឹត្តបត្រប្រចាំត្រីមាស របាយការណ៍ប្រចាំឆ្នាំ ព្រមទាំងអត្ថបទស្រាវជ្រាវនិងបោះផ្សាយទាក់ទងនឹងប្រធានបទរបស់ធនាគារជាតិនៃកម្ពុជា។

**-សិក្សាស្រាវជ្រាវនៅបណ្ណាល័យ ៖** ក្នុងនោះមានការអានលើនិក្ខេបបទ និងរបាយការណ៍កម្មសិក្សា ដែលជាស្នាដៃរបស់រៀមច្បង ដោយធ្វើការដកស្រង់គំនិត និងស្វែងយល់បន្ថែមតាមរយៈឯកសារស្រាវជ្រាវចាស់ៗដែលមានកន្លងមក នៅបណ្ណាល័យនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

**-សិក្សាស្រាវជ្រាវតាមរយៈប្រព័ន្ធអ៊ីនធើណែត(Internet) ៖** ធ្វើការស្រាវជ្រាវតាមរយៈគេហទំព័រជាខេមរភាសា និងភាសាបរទេសនានា ដែលបានចុះផ្សាយជាឯកសារ និងព័ត៌មាន ដែលមានការពាក់ព័ន្ធទៅប្រធានបទ។

### ខ. វិធីសាស្ត្រប្រមូលទិន្នន័យ

ការសិក្សាស្រាវជ្រាវនេះធ្វើឡើងដោយផ្តោតសំខាន់ទៅលើទិន្នន័យ ២ ប្រភេទគឺ ទិន្នន័យគោល និងទិន្នន័យបន្ថែម។

**-ទិន្នន័យគោល (Primary Data) ៖** រួមមានការចុះកម្មសិក្សាផ្ទាល់នៅធនាគារជាតិនៃកម្ពុជា ទិន្នន័យប្រចាំឆ្នាំ និងឯកសារដែលទទួលបានពីការពន្យល់ណែនាំ តាមរយៈការសំភាសន៍ផ្ទាល់មាត់តាមកម្រងសំណួរដែលបានរៀបចំទុក និងការទាក់ទងតាមទូរស័ព្ទជាមួយមន្ត្រីបុគ្គលិកនៅតាមបណ្តានាយកដ្ឋានជំនាញមួយចំនួនរបស់ធនាគារជាតិនៃកម្ពុជា ហើយរាល់ព័ត៌មានទាំងអស់សុទ្ធសឹងតែជាព័ត៌មានជាក់លាក់ និងមានប្រភពច្បាស់លាស់។

**-ទិន្នន័យបន្ថែម (Secondary Data) ៖** គឺជាទិន្នន័យ និងរបាយការណ៍នានាដែលទទួលបានមកពីគេហទំព័ររបស់ធនាគារជាតិនៃកម្ពុជានិងគេហទំព័របរទេស ការស្រាវជ្រាវនៅបណ្ណាល័យ សៀវភៅនិងអត្ថបទសិក្សាដែលជាប់ទាក់ទងទៅនឹងបញ្ហាដុល្លារូបនីយកម្មនៅកម្ពុជា និងឯកសារបោះផ្សាយបន្ទាប់បន្សំដែលទទួលបានពីធនាគារជាតិនៃកម្ពុជានិងបណ្តាញសង្គម។

### គ. វិធីសាស្ត្រវិភាគទិន្នន័យ

នៅក្នុងការវិភាគទិន្នន័យ និងព័ត៌មានដែលទទួលបាន ក្រុមយើងខ្ញុំបានជ្រើសយកការវិភាគតាមបែបគុណវិស័យ និងបរិមាណវិស័យ ដែលការវិភាគនេះគឺផ្តោតសំខាន់ទៅលើគុណភាពនៃព័ត៌មាន ការវិភាគលើលេខនព្វន្ត និងការសិក្សាពីក្រាហ្វិក ដើម្បីធ្វើការសន្និដ្ឋានលើលទ្ធផលនៃការស្រាវជ្រាវនេះ។

## ៦. សារសំខាន់នៃការស្រាវជ្រាវ

### ក. សារសំខាន់សម្រាប់អ្នកសិក្សាស្រាវជ្រាវ និងអ្នកសិក្សាជំនាន់ក្រោយ

- បំពេញកាតព្វកិច្ចក្នុងការបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រធនាគារ និងហិរញ្ញវត្ថុ

- ទទួលបានជាព័ត៌មានអំពីការអនុវត្តការងារជាក់ស្តែងនៅធនាគារជាតិនៃកម្ពុជា
- យល់ដឹងអំពីបញ្ហាដុល្លាវូបនីយកម្មនៅកម្ពុជា
- ទទួលបានចំណេះដឹងថ្មី និងល្អៗបន្ថែមអំពីការអនុវត្តវិធានការលើកកម្ពស់រូបិយវត្ថុជាតិ។
- យល់ដឹងអំពីទំនាក់ទំនងរវាងទ្រឹស្តី និងកាងារជាក់ស្តែងនៅក្នុងវិស័យធនាគារ
- ទុកជាឯកសារជំនួយដល់និស្សិតជំនាន់ក្រោយដើម្បីយកទៅសិក្សា និងធ្វើការស្រាវជ្រាវបន្ថែម
- ផ្តល់ជាចំណេះដឹងដល់ជនានុជនដែលជាអ្នកអាន និងអ្នកសិក្សា
- ផ្តល់ជាព័ត៌មានសម្រាប់ប្អូនៗនិស្សិតជំនាន់ក្រោយ ដែលចង់យល់ដឹងអំពីគោលនយោបាយរបស់ធនាគារជាតិនៃកម្ពុជា
- ផ្តល់ជាគំនិតនិងគំរូដល់ការសរសេរសារណារបស់មិត្តអ្នកសិក្សាឱ្យបានជោគជ័យ។

**ខ. សារសំខាន់សម្រាប់វិស័យធនាគារ**

- បានយល់ដឹងពីសារសំខាន់នៃរូបិយវត្ថុជាតិ នៅក្នុងវិស័យហិរញ្ញវត្ថុនៅកម្ពុជា
- ឱ្យវិស័យធនាគារនៅកម្ពុជាបានយល់ដឹងពីអត្ថប្រយោជន៍ និងសារសំខាន់នៃការលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលនៅកម្ពុជា
- ឱ្យបានដឹងពីគុណសម្បត្តិ និង គុណវិបត្តិនៃដុល្លាវូបនីយកម្មចំពោះវិស័យធនាគារនៅកម្ពុជា
- ឱ្យវិស័យធនាគារ បានទទួលព័ត៌មានបន្ថែមអំពីបញ្ហាដុល្លាវូបនីយកម្ម
- យល់ដឹងច្បាស់ពីតួនាទីរបស់ខ្លួននៅក្នុងការចូលរួមអនុវត្តវិធានលើកកម្ពស់រូបិយវត្ថុជាតិ។

**គ. សារសំខាន់ចំពោះសង្គមជាតិ**

- ផ្តល់ជាសារឱ្យមហាជនទូទៅយល់ដឹងពីអត្ថប្រយោជន៍នៃការបង្កើនការប្រើប្រាស់ប្រាក់រៀលឱ្យបានទូលំទូលាយនៅកម្ពុជា
- បង្កើនទំនុកចិត្តរបស់សាធារណជនទៅលើរូបិយវត្ថុជាតិ
- ចំណេះដឹងបន្ថែមចំពោះមហាជនអំពីការអនុវត្តវិធានការលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលនៅកម្ពុជា
- បណ្តុះគំនិតស្រលាញ់ និងចូលរួមថែរក្សាប្រាក់រៀលខ្មែរឱ្យមានភាពល្បីល្បាញ។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

កិច្ចការស្រាវជ្រាវនេះ ក្រុមយើងខ្ញុំបានធ្វើការបែងចែកជា ៥ ផ្នែកគឺ៖

- **សេចក្តីផ្តើម** រួមមាន ៖ លំនាំបញ្ហានៃការស្រាវជ្រាវ ចំណោទបញ្ហានៃការស្រាវជ្រាវ គោលបំណងនៃការស្រាវជ្រាវ ទំហំនិងដែនកំណត់នៃការស្រាវជ្រាវ វិធីសាស្ត្រក្នុងការស្រាវជ្រាវ សារសំខាន់នៃការស្រាវជ្រាវ និងរចនាសម្ព័ន្ធនៃការស្រាវជ្រាវ។
- **ជំពូកទី១ ៖ រំលឹកទ្រឹស្តី** រួមមាន ៖ និយមន័យនិងប្រតិបត្តិការរបស់ធនាគារកណ្តាលនិងរូបិយវត្ថុ ព្រមទាំងនិយមន័យនិងទម្រង់នៃដុល្លារូបនីយកម្ម។
- **ជំពូកទី២ ៖ ស្ថានភាពទូទៅរបស់ធនាគារជាតិនៃកម្ពុជា** រួមមាន ៖ ប្រវត្តិនៃការកើតធនាគារជាតិនៃកម្ពុជា ទីតាំងភូមិសាស្ត្រ អត្តសញ្ញាណ បេសកកម្ម មុខងារ និងតួនាទី និងរចនាសម្ព័ន្ធរបស់ធនាគារជាតិនៃកម្ពុជា។
- **ជំពូកទី៣ ៖ លទ្ធផលនៃការស្រាវជ្រាវ** លើកឡើងអំពីមូលហេតុនៃដុល្លារូបនីយកម្មនៅកម្ពុជា ស្ថានភាពនៃដុល្លារូបនីយកម្មនៅកម្ពុជា គុណសម្បត្តិនិងគុណវិបត្តិដុល្លារូបនីយកម្ម ចក្ខុវិស័យនិងក្របខ័ណ្ឌគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា និងយុទ្ធសាស្ត្រលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលរបស់ធនាគារជាតិនៃកម្ពុជា។
- **សេចក្តីសន្និដ្ឋាន និងអនុសាសន៍**

រូបភាពទី១៖ ម៉ូដែលនៃការស្រាវជ្រាវ



# ជំពូកទី១

# រំលឹកទ្រឹស្តី

## ១.១. និយមន័យ និងប្រតិបត្តិការរបស់ធនាគារកណ្តាល[1]

ធនាគារកណ្តាល គឺជាស្ថាប័នឯករាជ្យរបស់ប្រទេសមួយ ដែលមានសិទ្ធិដាក់ចេញនូវគោលនយោបាយរូបិយវត្ថុ និងបទបញ្ញត្តិនានាសម្រាប់ត្រួតពិនិត្យលើបណ្តាធនាគារពាណិជ្ជ។ ធនាគារកណ្តាល ឬធនាគារជាតិ ដើរតួជាអ្នកផ្តល់នូវសេវាកម្មហិរញ្ញវត្ថុ និងធនាគារសម្រាប់រដ្ឋាភិបាល និងប្រព័ន្ធធនាគារនៅក្នុងប្រទេសរបស់ខ្លួន។ គោលដៅចម្បងៗរបស់ធនាគារកណ្តាល គឺធ្វើយ៉ាងណាដើម្បីរក្សាស្ថានភាពរូបិយវត្ថុឱ្យមានស្ថិរភាព កាត់បន្ថយកម្រិតនិកម្មភាពនិងការកើនឡើងនៃអត្រាអតិផរណា។

ធនាគារកណ្តាល មានប្រតិបត្តិការសំខាន់ៗដូចខាងក្រោម៖

- **ធនាគារិកសម្រាប់រដ្ឋ** (Banker for the state) ៖ មានការទទួលខុសត្រូវដល់ការចេញផ្សាយនូវរូបិយវត្ថុរបស់ប្រទេស និងការគ្រប់គ្រងហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាល។
- **ធនាគារិកចំពោះធនាគារពាណិជ្ជកម្ម** (Banker for the commercial bank) ៖ ទទួលប្រាក់បញ្ញើរបស់ធនាគារពាណិជ្ជនានា និងមានឥទ្ធិពលជាបន្តបន្ទាប់ដល់ប្រាក់បម្រុងរបស់ធនាគារ ហើយមានតួនាទីពិសេសនៃសកម្មភាពជាអ្នកឱ្យខ្ចីដល់ធនាគារពាណិជ្ជណា ដែលមានតម្រូវការសម្រាប់ដោះស្រាយបញ្ហាម្តងម្កាល (Lender of last resort)។
- **គោលនយោបាយរូបិយវត្ថុមានលក្ខណៈប្រុងប្រយ័ត្ន** (Discretion monetary policy) ៖ ទទួលខុសត្រូវជាពិសេសចំពោះការធ្វើឱ្យមានស្ថិរភាពរូបិយវត្ថុ។ ធនាគារកណ្តាល បានអនុវត្តវិធីសាស្ត្រដោយប្រើឥទ្ធិពលរបស់ខ្លួន ទៅលើកម្រិតនៃប្រាក់បម្រុងកំណត់ដោយធនាគារពាណិជ្ជនានា និងដាក់ឱ្យប្រើប្រាស់នូវគោលនយោបាយអត្រាការប្រាក់របស់ខ្លួន ព្រមទាំងការត្រួតពិនិត្យឥណទាន និងការធ្វើអន្តរាគមន៍លើចរន្តនៃអត្រាប្តូរប្រាក់ខាងក្នុង និងក្រៅប្រទេសផងដែរ។
- **អ្នកត្រួតពិនិត្យប្រព័ន្ធហិរញ្ញវត្ថុ** (Supervisor of the financial system) ៖ មុខងារទាំងនេះរួមបញ្ចូលទាំងការធ្វើនិយ័តកម្មនៃប្រព័ន្ធហិរញ្ញវត្ថុ។ នៅពេលដែលខ្លួនដើរតួជាអ្នកឱ្យខ្ចីចុងក្រោយ ធនាគារកណ្តាលធ្វើសកម្មភាពជាអ្នកធានាដល់ស្ថិរភាពប្រព័ន្ធធនាគារ បើទោះបីជាការធានារបស់ខ្លួនមិនមានលក្ខណៈផ្តាច់មុខក៏ដោយ។

[1] សាស្ត្រាចារ្យ ឌុន ថាវី ធនាគារកណ្តាល(ឯកសារបង្រៀន) ឆ្នាំ២០១៨ ទំព័រទី៤

## ១.២. រូបិយវត្ថុ[2]

ពាក្យរូបិយវត្ថុ ឬលុយ គឺសំដៅទៅលើវត្ថុផ្សេងៗដែលអាចត្រូវបានគេប្រើដើម្បីធ្វើប្រតិបត្តិការសេដ្ឋកិច្ច។ ការឱ្យនិយមន័យជាផ្លូវការរូបិយវត្ថុ គឺជាទ្រព្យសកម្មមួយដែលគេទទួលយកជាទូទៅនៅក្នុងការទូទាត់ទំនិញនិងសេវាកម្ម ឬការសងបំណុល។

### ១.២.១. មុខងារនៃរូបិយវត្ថុ

#### ១.២.១.១. មធ្យោបាយនៃការទូទាត់

មធ្យោបាយនៃការទូទាត់ គឺជាការទទួលស្គាល់ជាទូទៅរវាងអ្នកលក់ និងអ្នកទិញនៅក្នុងការដោះដូរទំនិញ និងសេវាកម្មគ្នាទៅវិញទៅមក។ វាអាចធ្វើការដោះដូរដោយផ្ទាល់ ដែលគេហៅថាពាណិជ្ជកម្មតាមរូបភាពនៃការផ្លាស់ប្តូរទំនិញដោយមិនចាំបាច់ប្រើក្រដាសប្រាក់។ មធ្យោបាយទូទាត់មានលក្ខណៈពិសេសរបស់ខ្លួនមួយ គឺវាអាចប្រព្រឹត្តទៅដោយសារតែមានភាពត្រូវគ្នានៃតម្រូវការ មានន័យថា រាល់ស្ថានភាពដែលអ្នកទិញនិងអ្នកលក់មានសេចក្តីត្រូវការដូចគ្នានៅក្នុងការដោះដូរទំនិញ ឬផលិតផល ឬមធ្យោបាយនៃការទូទាត់ផ្សេងៗ។

#### ១.២.១.២. ឯកតាគណនី

រូបិយវត្ថុ គឺជាឯកតាគណនីដែលគេអាចប្រើប្រាស់ដើម្បីស្រង់ថ្លៃទំនិញ និងកត់ត្រាបំណុលទាំងឡាយ ហើយគេចាត់ទុករូបិយវត្ថុគឺជាស្តង់ដាររបស់តម្លៃ។ ឯកតាគណនី គឺជាការវាស់វែងនូវស្ថានភាពថ្លៃនៅពេលដែលអ្នកប្រើប្រាស់បានគិតគូរអំពីតម្លៃសមស្របរបស់ទំនិញ និងសេវាកម្មដែលពួកគេចង់បាន។ អ្នកប្រើប្រាស់តែងតែធ្វើការប្រៀបធៀបផងដែរ រវាងតម្លៃទំនិញនិងសេវាកម្មដែលពួកគេមានតម្រូវការ។

#### ១.២.១.៣. ការរក្សាតម្លៃ

ការរក្សាតម្លៃសំដៅទៅលើផលិតផលឬទំនិញទាំងឡាយ ឬវត្ថុតាងនានាដែលអាចយកទៅប្រើប្រាស់ជាថ្នូរក្នុងការដោះដូរទំនិញ និងសេវាកម្មផ្សេងៗក្រោយពីការកាន់កាប់ទុកអស់មួយរយៈ។ ឧទាហរណ៍ ការរក្សាទុកមាស ពេជ្រ ឬទ្រព្យសម្បត្តិផ្សេងៗទៀត មួយរយៈ ក្រោយមកយកទៅលក់ដើម្បីទិញទំនិញសម្រាប់ប្រើប្រាស់។ សូមបញ្ជាក់ថា ការរក្សាទុកនូវទ្រព្យសម្បត្តិផ្សេងៗអាចផ្តល់នូវផលចំនេញ ឬការខាតបង់អាស្រ័យទៅតាមការប្រែប្រួលទីផ្សារ និងហានិភ័យ។

[2] សាស្ត្រាចារ្យ ខឹម សារិទ្ធ ហិរញ្ញវត្ថុ១(ឯកសារបង្រៀន) ឆ្នាំ២០១៧ ទំព័រទី២៥

**១.២.១.៤. ស្តង់ដារនៃការទូទាត់ពន្យាពេល**

ការសន្មត់នូវរូបិយវត្ថុដែលអនុញ្ញាតឱ្យគេប្រើប្រាស់មួយរយៈ និងមធ្យោបាយដែលគេវាយតម្លៃទទួលបានពីកម្ចីនាពេលអនាគត តាមរយៈការយល់ព្រមលើកិច្ចសន្យា ត្រូវបានគេហៅថាស្តង់ដារនៃការទូទាត់ពន្យាពេល។ ឧទាហរណ៍ថា ប្រសិនបើពលរដ្ឋយល់ព្រមលើកិច្ចសន្យាឥណទាននោះគេនឹងសងត្រឡប់មកវិញនាពេលអនាគតជាចំនួនទឹកប្រាក់ទៅតាមកិច្ចព្រមព្រៀង។

**១.២.២. ទម្រង់នៃរូបិយវត្ថុ**[3]

ដោយយោងទៅលើប្រវត្តិសាស្ត្រដើមរហូតមកដល់បច្ចុប្បន្ន យើងអាចបែងចែករូបិយវត្ថុជាបីសណ្ឋានដូចខាងក្រោមនេះ៖

- **ប្រភេទទំនិញផ្សេងៗ (Goods)៖** នៅដំណាក់កាលដំបូង មានវត្ថុជាច្រើនប្រភេទត្រូវបានគេប្រើជារូបិយវត្ថុសម្រាប់ធ្វើការទូទាត់ ដូចជាសំបកខ្យង ក្រណាត់ បារី ឬថ្នាំជក់ អង្ករ សំណ ស្ពាន់ មាស ប្រាក់ជាដើម។ល។
- **រូបិយវត្ថុជាលោហធាតុមានតម្លៃ (Precious metals)៖** រូបិយវត្ថុត្រូវមានតម្លៃពិតប្រាកដរបស់វា គឺមាន មាស និងប្រាក់ ដែលត្រូវបានប្រើប្រាស់ជាមធ្យោបាយសម្រាប់ទូទាត់។
- **រូបិយវត្ថុជាក្រដាសប្រាក់ (Note/paper money)៖** មាស និងប្រាក់ បានជួបប្រទះនឹងការលំបាកក្នុងការទូទាត់ (នៅពេលដឹកជញ្ជូន)។ ហេតុដូចនេះ គេយកវិក្កយបត្រដែលដាក់បញ្ចាំមាស ឬប្រាក់ទាំងនោះនៅទីដែលមានសុវត្ថិភាពមកធ្វើជាមធ្យោបាយនៃការទូទាត់វិញ ហើយការបោះផ្សាយវិក្កយបត្រ ដែលមានលក្ខណៈជាឥណទានក៏បានកើតឡើង។

**១.២.៣. លក្ខណៈពិសេសនៃរូបិយវត្ថុ**

រូបិយវត្ថុត្រូវមានលក្ខណៈពិសេសដូចតទៅ៖

- បរិមាណតិច មានតម្លៃខ្ពស់ និងងាយស្រួលយកតាមខ្លួន
- ជាវត្ថុដែលអាចកាត់បាន ជ្រៀកបាន ដោយមិនបាត់បង់តម្លៃ
- តម្លៃរបស់វាមានស្ថិរភាព
- អាចរក្សាទុកបានយូរ មិនខូច ឧទាហរណ៍ មាស និងប្រាក់ជារូបិយវត្ថុ ត្រូវបានគេប្រើប្រាស់យ៉ាងទូលំទូលាយ។

[3] សាស្ត្រាចារ្យ ឌុន ថាវី ទស្សនៈស្តីពីរូបិយវត្ថុ(ឯកសារបង្រៀន) ទំព័រទី៩

## ១.៣. និយមន័យដុល្លាររូបនីយកម្ម

ដុល្លាររូបនីយកម្មត្រូវបានទទួលស្គាល់ជាទូទៅថា ជាការកាន់កាប់ទ្រព្យសកម្ម ឬប្រើប្រាស់រូបិយប័ណ្ណដោយនិវេសជននៅក្នុងអធិបតេយ្យភាពនៃប្រទេសមួយ។ ដុល្លាររូបនីយកម្ម មិនសំដៅតែទៅលើការប្រើប្រាស់ប្រាក់ដុល្លារអាមេរិកជំនួសឱ្យ ឬស្របពេលជាមួយរូបិយវត្ថុនៅក្នុងប្រទេសមួយនោះទេ តែទៅលើការប្រើប្រាស់រូបិយប័ណ្ណនានាផងដែរ ដូចជា ប្រាក់អឺរ៉ូ ប្រាក់ផោនអង់គ្លេស ប្រាក់យ៉េនជប៉ុនជាដើម[4]។

ដុល្លាររូបនីយកម្មអាចកើតឡើងក្នុងរូបភាពផ្សេងៗពីគ្នា ទៅតាមស្ថានភាពរបស់សេដ្ឋកិច្ច។ ជាមួយគ្នានេះដែរ យើងសង្កេតឃើញមានអត្ថបទនិងឯកសារសេដ្ឋកិច្ចជាភាសាបរទេសជាច្រើនបានបង្ហាញពីទស្សនទានផ្សេងៗគ្នាពីដុល្លាររូបនីយកម្ម។ អត្ថបទសេដ្ឋកិច្ចអំពីដុល្លាររូបនីយកម្មប្រើពាក្យពេចន៍ខុសៗគ្នា ដើម្បីពិពណ៌នាពីបាតុភូតនេះ ដូចជាវាក្យស័ព្ទ **ដុល្លាររូបនីយកម្មផ្លូវការ ដុល្លាររូបនីយកម្មក្រៅផ្លូវការ ដុល្លាររូបនីយកម្មពាក់កណ្ដាលផ្លូវការ ដុល្លាររូបនីយកម្មពេញទំហឹង ការជំនួសរូបិយវត្ថុ ការជំនួសទ្រព្យសកម្មជាដើម។ល**[5]។

លោក Ortiz (១៩៨៣) បានឱ្យនិយមន័យដុល្លាររូបនីយកម្ម ថាជាកម្រិតផលធៀបរវាងប្រតិបត្តិការជាក់ស្ដែង និងហិរញ្ញវត្ថុធ្វើឡើងជាប្រាក់ដុល្លារ ដោយប្រៀបធៀបទៅនឹងរូបិយវត្ថុក្នុងស្រុក។ និយមន័យដុល្លាររូបនីយកម្មនេះ បង្ហាញអំពីការទទួលស្គាល់នូវការប្រើប្រាស់ប្រាក់ដុល្លារអាមេរិកជាមធ្យោបាយដោះដូរ និងទូទាត់នៅក្នុងសេដ្ឋកិច្ចមួយក្រៅពីព្រំដែនសហរដ្ឋអាមេរិក។ ដោយយោងទៅតាម Cuddington (១៩៨៩), Calvo និង Vegh (១៩៩២) បានបង្ហាញថា ការជំនួសរូបិយវត្ថុ គឺជាការប្រើប្រាស់រូបិយប័ណ្ណបរទេស និងប្រាក់បញ្ញើជារូបិយប័ណ្ណបរទេស ធ្វើជាមធ្យោបាយនៃការលក់ដូរនៅក្នុងសេដ្ឋកិច្ចក្នុងស្រុក។ McKinnon (១៩៩៦) វិភាគបន្ថែមកាន់តែច្បាស់លាស់ទៀត ដោយបែងចែកដាច់ពីគ្នារវាង ការជំនួសរូបិយវត្ថុ និងការជំនួសទ្រព្យសម្បត្តិ ដោយបានបញ្ចូលទាំងពីរនេះ ជាមូលហេតុនាំឱ្យមានតម្រូវការទ្រព្យសកម្មជារូបិយប័ណ្ណបរទេស ដោយបានសង្កត់ធ្ងន់ទៅលើការប្រើប្រាស់ប្រាក់ដុល្លារជាមធ្យោបាយដោះដូរ **(ការជំនួសរូបិយវត្ថុ)** និងសម្រាប់រក្សាតម្លៃ **(ការជំនួសទ្រព្យសកម្ម)**[6]។

[4] ធនាគារជាតិនៃកម្ពុជា យុទ្ធសាស្ត្រលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល បោះពុម្ពលើកទី១ ឆ្នាំ២០១៧ ទំព័រទី៨

[5] បណ្ឌិត ហង់ ជួន ណារ៉ុន ម៉ាក្រូសេដ្ឋកិច្ច ឆ្នាំ២០០៩ ទំព័រទី១៦៦

[6] បណ្ឌិត ហង់ ជួន ណារ៉ុន សេដ្ឋកិច្ចកម្ពុជា មាគ៌ាឆ្ពោះទៅរកអនាគតដ៏ភ្លឺស្វាង ឆ្នាំ២០១៥ ទំព័រទី១០១

ដុល្លាវូបនីយកម្មក្រៅផ្លូវការ (Unofficial Dollarization) មានន័យថា ប្រជាពលរដ្ឋមានការពេញចិត្តក្នុងការប្រើប្រាស់រូបិយប័ណ្ណបរទេស ជាជាងរូបិយប័ណ្ណជាតិសម្រាប់ធ្វើប្រតិបត្តិការទូទាត់មួយចំនួនទោះបីជាវាមិនអាចជាការទូទាត់ដែលមានលក្ខណៈផ្លូវការក៏ដោយ។ គេតែងប្រើប្រាស់រូបិយប័ណ្ណក្នុងស្រុកដើម្បីបើកប្រាក់បៀវត្ស បង់ពន្ធ និងទូទាត់ចំណាយប្រចាំថ្ងៃ ក៏ប៉ុន្តែចំពោះប្រតិបត្តិការដែលមានទំហំធំ ជាញឹកញាប់គេតែងតែប្រើរូបិយប័ណ្ណបរទេសដើម្បីទូទាត់។ ដុល្លាវូបនីយកម្មដោយអន្លើ កើតឡើងនៅពេលដែលប្រជាជនរក្សាទុកនៃផ្នែកខ្លះនៃទ្រព្យសម្បត្តិហិរញ្ញវត្ថុរបស់ខ្លួន ក្នុងរូបភាពជាទ្រព្យសកម្មបរទេស ដែលមានលក្ខណៈដូចគ្នាទៅនឹងការជំនួសទ្រព្យសកម្មដែរ។ ដុល្លាវូបនីយកម្មពាក់កណ្ដាលផ្លូវការ (Partial Dollarization) កើតឡើងនៅពេលដែលសេដ្ឋកិច្ចជាក់ស្ដែងមានប្រព័ន្ធរូបិយវត្ថុប្រើប្រាស់នូវរូបិយវត្ថុពីរ។ នៅក្នុងប្រព័ន្ធនេះ រូបិយប័ណ្ណបរទេសបានដើរតួជារូបិយវត្ថុស្របច្បាប់ និងត្រូវបានប្រើប្រាស់យ៉ាងពេញនិយមតែម្តងជាប្រាក់បញ្ញើធនាគារ។ ទោះជាយ៉ាងណាក៏ដោយ រូបិយប័ណ្ណបរទេសមិនមានតួនាទីសំខាន់ដូចរូបិយប័ណ្ណជាតិ ក្នុងការបើកប្រាក់បៀវត្ស និងការបង់ពន្ធនោះទេ។ រីឯដុល្លាវូបនីយកម្មជាផ្លូវការ ឬហៅថាដុល្លាវូបនីយកម្មពេញទំហឹង (Official Dollarization ឬ Full Dollarization) មានន័យថារូបិយប័ណ្ណបរទេសក្លាយជាការទូទាត់ដ៏ពេញចិត្តនៅក្នុងប្រទេស ខណៈដែលរូបិយប័ណ្ណក្នុងស្រុកឬរូបិយប័ណ្ណជាតិក៏ត្រូវបានទទួលយកផងដែរ។ យើងអាចនិយាយបានថា រូបិយប័ណ្ណបរទេសមិនត្រឹមតែមានតួនាទីស្របច្បាប់ សម្រាប់ប្រើប្រាស់នៅក្នុងកិច្ចសន្យារវាងភាគីឯកជនតែប៉ុណ្ណោះទេ តែរដ្ឋាភិបាលក៏ប្រើប្រាស់រូបិយប័ណ្ណបរទេសសម្រាប់រាល់ប្រតិបត្តិការក្នុងស្រុកផងដែរ។ រូបិយប័ណ្ណក្នុងស្រុកនៅតែមានវត្តមាន ប៉ុន្តែមានមុខងារ និងតួនាទីបន្ទាប់បន្សំតែប៉ុណ្ណោះ[7]។

ការជំនួសរូបិយប័ណ្ណ តែងកើតមានឡើងនៅពេលដែល ប្រទេសមានអត្រាអតិផរណាខ្ពស់ និងមានការប្រែប្រួលឥតឈប់ឈរ ជាហេតុធ្វើឱ្យប្រជាពលរដ្ឋមិនមានទំនុកចិត្ត និងមិនចង់ប្រើប្រាស់រូបិយប័ណ្ណជាតិ។ ការជំនួសទ្រព្យសកម្ម អាចបណ្ដាលមកពីការគេចចេញពីរូបិយប័ណ្ណក្នុងស្រុក ដោយងាកទៅរកទ្រព្យសកម្មជារូបិយប័ណ្ណបរទេសជាមធ្យោបាយរក្សាទុកតម្លៃ។ នៅក្នុងរយៈពេលថ្មីៗនេះ ដុល្លាវូបនីយកម្មកាន់តែរីកដុះដាលឡើងនៅក្នុងប្រទេសមួយចំនួនដោយសារតែមានបម្រែបម្រួលស្ថាប័ន ជាពិសេសសេរីភាវូបនីយកម្មរបស់គណនីមូលធន ដែលបានសម្រួលដល់ដំណើរការនេះ។

[7] បណ្ឌិត ហង់ ជួន ណារ៉ុន ម៉ាក្រូសេដ្ឋកិច្ច ឆ្នាំ២០០៩ ទំព័រទី១៦៦

ដូចនេះ ការកើនឡើងនៃទ្រព្យសកម្មចារឹកជារូបិយប័ណ្ណបរទេសនៅក្នុងពេលប៉ុន្មានឆ្នាំចុងក្រោយនេះ គឺជាលទ្ធផលនៃការសម្រេចចិត្តទិញភាគហ៊ុននៅកំឡុងពេលដែលស្ថានភាពម៉ាក្រូសេដ្ឋកិច្ចកំពុងមានស្ថិរភាព ហើយមិនមែនជាការគេចចេញពីរូបិយប័ណ្ណក្នុងស្រុកនោះទេ។

## ១.៤. ទម្រង់នៃដុល្លាររូបនីយកម្ម[8]

### ១.៤.១. ដុល្លាររូបនីយកម្មរូបវ័ន្ត

ដុល្លាររូបនីយកម្មរូបវ័ន្ត (Real Dollarization) គឺសំដៅទៅលើការប្រើប្រាស់រូបិយប័ណ្ណដើម្បីកំណត់ថ្លៃទំនិញ និងសេវា ដែលត្រូវដោះដូរក្នុងប្រទេស។ ដុល្លាររូបនីយកម្មប្រភេទនេះ ជាទូទៅកើតឡើងនៅពេលដែលទំនិញប្រើប្រាស់ភាគច្រើនជាទំនិញនាំចូលពីបរទេស អត្រាអតិផរណាក្នុងស្រុកខ្ពស់ ដែលធ្វើឱ្យមានការបាត់បង់ទំនុកចិត្តលើការប្រើប្រាស់រូបិយវត្ថុជាតិ ឬដោយសារការបញ្ចៀសហានិភ័យអត្រាប្តូរប្រាក់ជាដើម។

### ១.៤.២. ដុល្លាររូបនីយកម្មប្រតិបត្តិការ

ដុល្លាររូបនីយកម្មប្រតិបត្តិការ (Transaction Dollarization) គឺជាស្ថានភាពដុល្លាររូបនីយកម្មដែលនៅក្នុងនោះវិស័យឯកជនប្រើប្រាស់រូបិយប័ណ្ណបរទេស ដើម្បីធ្វើការទូទាត់រាល់ប្រតិបត្តិការដោះដូរក្នុងស្រុកទៅលើទំនិញ និងសេវា។ ដុល្លាររូបនីយកម្មប្រភេទនេះ ក៏ត្រូវបានឱ្យឈ្មោះថាការជំនួសរូបិយវត្ថុ (Currency Substitution) ។ ភាពងាយស្រួល ការចំណេញពីការទូទាត់ និងការរក្សា ឬទទួលបានចំណូលជារូបិយប័ណ្ណ គឺជាមូលហេតុចម្បងនៃដុល្លាររូបនីយកម្មប្រតិបត្តិការ។

### ១.៤.៣. ដុល្លាររូបនីយកម្មហិរញ្ញវត្ថុ

ដុល្លាររូបនីយកម្មហិរញ្ញវត្ថុ (Financial Dollarization) ឬហៅថាការជំនួសទ្រព្យសកម្ម (Assets Substitution) គឺជាស្ថានភាពដុល្លាររូបនីយកម្មដែលកើតឡើងដោយសារវិស័យឯកជនក្នុងប្រទេសមួយរក្សាទុកនូវទ្រព្យសកម្ម និងបំណុលហិរញ្ញវត្ថុចារឹកជារូបិយប័ណ្ណបរទេស។ មូលហេតុចម្បងដែលនាំឱ្យកើតមានដុល្លាររូបនីយកម្មហិរញ្ញវត្ថុ រួមមាន ភាពទន់ខ្សោយនៃប្រព័ន្ធហិរញ្ញវត្ថុ អស្ថិរភាពនៃអត្រាប្តូរប្រាក់ និងការបាត់បង់ជំនឿទុកចិត្តរបស់វិនិយោគិនមកលើឧបករណ៍ហិរញ្ញវត្ថុចារឹកជារូបិយប័ណ្ណក្នុងស្រុក ឬរូបិយប័ណ្ណជាតិ។

[8] ធនាគារជាតិនៃកម្ពុជា យុទ្ធសាស្ត្រលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល បោះពុម្ពលើកទី១ ឆ្នាំ២០១៧ ទំព័រទី៨

# ជំពូកទី២

# ស្ថានភាពទូទៅរបស់ធនាគារជាតិ នៃ កម្ពុជា

## ២.១. ប្រវត្តិនៃការកកើត និងការវិវឌ្ឍរបស់ធនាគារជាតិនៃកម្ពុជា

ធនាគារជាតិនៃកម្ពុជា ដែលជាធនាគារកណ្តាលរបស់ប្រទេសកម្ពុជា គឺជាអាជ្ញាធររូបិយវត្ថុ និងត្រួតពិនិត្យប្រព័ន្ធធនាគារនៅកម្ពុជា។ ធនាគារជាតិនៃកម្ពុជាមានប្រវត្តិជាយូរអង្វែងណាស់មក ហើយ ដែលយើងអាចបែងចែកជាបួនដំណាក់កាលសំខាន់ៗដូចខាងក្រោមនេះ[9] ៖

- **ឆ្នាំ១៩៥៤ ដល់ឆ្នាំ១៩៦៤ ៖** បន្ទាប់ពីប្រទេសកម្ពុជាទទួលបានឯករាជ្យពីអាណានិគមនិយមបារាំង ក្នុងឆ្នាំ១៩៥៤ ធនាគារជាតិនៃកម្ពុជាក៏ត្រូវបានបង្កើតឡើង។ ធនាគារជាតិនៃកម្ពុជាទទួលភារៈផ្តាច់មុខជាអ្នកបោះពុម្ពប្រាក់រៀល ដែលជារូបិយវត្ថុជាតិ និងគ្រប់គ្រងលើប្រព័ន្ធធនាគារនៅកម្ពុជា។
- **ឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ៖** ធនាគារជាតិនៃកម្ពុជាត្រូវបានបិទទ្វារដោយសារតែការកើតឡើងនៃរបបកម្ពុជាប្រជាធិបតេយ្យ (ខ្មែរក្រហម)។ អគារស្នាក់ការត្រូវបានកម្ទេច រូបិយវត្ថុជាតិត្រូវបានឈប់ប្រើប្រាស់ ហើយប្រព័ន្ធធនាគារត្រូវបានលុបបំបាត់ចោលទាំងស្រុងនាពេលនោះ។
- **ឆ្នាំ១៩៧៩ ដល់ឆ្នាំ១៩៩៣ ៖** ធនាគារជាតិនៃកម្ពុជាត្រូវបានកសាងឡើងវិញពីចំណុចសូន្យ។ ទន្ទឹមនេះ រូបិយវត្ថុជាតិក៏ត្រូវបានបោះផ្សាយឡើងវិញផងដែរ។ កម្ពុជាបានប្តូរពីសេដ្ឋកិច្ចផែនការទៅជាសេដ្ឋកិច្ចទីផ្សារសេរី។
- **ឆ្នាំ១៩៩៣ ដល់បច្ចុប្បន្ន ៖** ប្រព័ន្ធធនាគារត្រូវបានពង្រឹង និងធ្វើទំនើបភាវូបនីយកម្មជាលំដាប់ ហើយកម្ពុជាបានក្លាយជាប្រទេសមួយ ក្នុងចំណោមប្រទេសដែលមានកំណើនសេដ្ឋកិច្ចខ្លាំងជាងគេនៅលើពិភពលោក។

### ២.១.១. ដំណាក់កាលឯករាជ្យភាពនិងការបង្កើតឡើងវិញ (១៩៥៤ - ១៩៦៤)

ធនាគារជាតិនៃកម្ពុជាត្រូវបានបង្កើតឡើងនៅខែធ្នូ ឆ្នាំ១៩៥៤ បន្ទាប់ពីប្រទេសកម្ពុជាទទួលបានឯករាជ្យពីអាណានិគមនិយមបារាំង និងបន្ទាប់ពីវិទ្យាស្ថានបោះប្រាក់ឥណ្ឌូចិនត្រូវបានបិទទ្វារ។ មុនពេលទទួលបានឯករាជ្យពីបារាំង វិទ្យាស្ថានបោះប្រាក់ដែលមានទីតាំងនៅប្រទេសកម្ពុជា បានបោះពុម្ពរូបិយវត្ថុរួមគ្នាមួយសម្រាប់ប្រើប្រាស់បីប្រទេសនៅឥណ្ឌូចិនគឺ ប្រទេសកម្ពុជា ប្រទេសឡាវ និងប្រទេសវៀតណាម។ បន្ទាប់ពីកម្ពុជាទទួលបានឯករាជ្យពីបារាំងវិញ ធនាគារជាតិនៃកម្ពុជាបានបោះផ្សាយនូវរូបិយវត្ថុជាតិ (ប្រាក់រៀល) ដើម្បីបំពេញអធិបតេយ្យភាពក្នុងការរក្សា

[9] ប្រភព៖ គេហទំព័រធនាគារជាតិនៃកម្ពុជា ឆ្នាំ២០១៩

ស្ថិរភាពរូបិយវត្ថុ និង ជួយកសាងអត្តសញ្ញាណជាតិជាថ្មី។ ស្របពេលជាមួយគ្នានោះដែរ ប្រព័ន្ធធនាគារនៅក្នុងស្រុកក៏ត្រូវបានកសាងឡើងវិញ ដែលមានទាំងធនាគាររដ្ឋ និងឯកជនធ្វើប្រតិបត្តិការរួមគ្នា។

មកដល់សម័យសង្គមរាស្ត្រនិយមនាកំឡុងទសវត្សរ៍ឆ្នាំ១៩៦០ នៅក្រោមការដឹកនាំរបស់ព្រះបាទ នរោត្តមសីហនុ ព្រះរាជាណាចក្រកម្ពុជាមានការអភិវឌ្ឍរីកចម្រើនទូទាំងផ្ទៃប្រទេស។ នៅក្នុងឆ្នាំ១៩៦៤ ប្រព័ន្ធធនាគារត្រូវបានធ្វើកំណែទម្រង់ ដើម្បីឱ្យត្រូវតាមតម្រូវការសេដ្ឋកិច្ច និងការអភិវឌ្ឍនាសម័យនោះ ដោយបានធ្វើការប្រែក្លាយធនាគារជាតិនៃកម្ពុជា ពីទម្រង់ស្ថាប័នពាក់កណ្តាលស្វយ័ត ទៅជាធនាគាររដ្ឋក្រោមទម្រង់ជាស្ថាប័នសាធារណៈ ដែលមានលក្ខណៈឧស្សាហកម្ម និងពាណិជ្ជកម្ម។ ទន្ទឹមនឹងនេះដែរ ធនាគារសាធារណៈនិងឯកជនជាច្រើនត្រូវបានបិទទ្វារ ហើយរាជរដ្ឋាភិបាលបានកសាងធនាគារដែលគ្រប់គ្រងដោយរដ្ឋមួយចំនួនដូចជា ធនាគារឥណទានសម្រាប់ការអភិវឌ្ឍ និងធនាគារកសិកម្មជនបទ។

រូបភាពទី២.១៖ អគារធនាគារជាតិនៃកម្ពុជា នាសម័យសង្គមរាស្ត្រនិយម



### ២.១.២. ដំណាក់កាលរបបខ្មែរក្រហម (១៩៧៥-១៩៧៩)

មកដល់ថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ នៅពេលដែលរបបកម្ពុជាប្រជាធិបតេយ្យ (ខ្មែរក្រហម) កាន់អំណាច ធនាគារជាតិនៃកម្ពុជាត្រូវបានបិទទ្វារ ក្នុងពេលនោះដែរ អគារស្នាក់ការត្រូវបានកម្ទេច រូបិយវត្ថុជាតិត្រូវបានឈប់ឱ្យប្រើប្រាស់ ហើយប្រព័ន្ធធនាគារត្រូវបានលុបបំបាត់ចោលទាំងស្រុង។ នាថ្ងៃទី០៧ ខែមករា ឆ្នាំ១៩៧៩ របបខ្មែរក្រហមត្រូវបានគេផ្តួលរំលំ ហើយធនាគារ

ជាតិនៃកម្ពុជាត្រូវបានបង្កើតឡើងវិញនៅថ្ងៃទី១០ ខែតុលា ឆ្នាំ១៩៧៩ តាងនាមជាធនាគារកណ្តាលរបស់ប្រទេស និងត្រូវបានប្តូរឈ្មោះជា "ធនាគារជាតិនៃប្រជាជនកម្ពុជា" ដោយក្រុមប្រឹក្សាប្រជាជនបដិវត្តន៍កម្ពុជា។ ទោះជាយ៉ាងនេះក្តី ការកសាងធនាគារជាតិនៃកម្ពុជា និងការស្តារប្រទេសជាតិបន្ទាប់ពីសង្គ្រាមទើបនឹងបញ្ចប់ភ្លាមៗនោះ គឺពិតជាមានការលំបាកខ្លាំងណាស់។ ជាមួយនឹងការខិតខំប្រឹងប្រែងជម្នះគ្រប់ឧបសគ្គ ដើម្បីកសាងប្រព័ន្ធធនាគារសាជាថ្មីឡើងវិញ ដោយផ្តើមចេញពីចំណុចសូន្យនោះ ឯកឧត្តម ជា ចាន់តូ ទេសរដ្ឋមន្ត្រីនិងជាអភិបាលធនាគារជាតិនៃកម្ពុជា ដែលជាអ្នកចូលរួមផ្តួចផ្តើមម្នាក់ក្នុងចំណោមអ្នកផ្តួចផ្តើមកសាងធនាគារជាតិនៃកម្ពុជាដទៃទៀត ព្រមទាំងបុគ្គលិកមួយចំនួនតូច ដែលនៅរស់រានមានជីវិតបន្ទាប់ពីរបបខ្មែរក្រហម បានប្តេជ្ញាចិត្តយ៉ាងមុះមុតក្នុងការកសាងធនាគារជាតិនៃកម្ពុជាឡើងវិញឱ្យបានរីកចម្រើន។

រូបភាពទី២.២៖ អគារធនាគារជាតិនៃកម្ពុជាត្រូវបានបំផ្លាញដោយរបបខ្មែរក្រហម



របបកម្ពុជាប្រជាធិបតេយ្យ បានបន្សល់ទុកនូវផលវិបាក និងបញ្ហាប្រឈមជាច្រើនដល់អ្នកជំនាន់ក្រោយ។ ដោយសារបញ្ញវ័ន្ត រួមទាំងអ្នកចេះដឹងជាច្រើនរូប ត្រូវបានសម្លាប់ចោលដោយពួកខ្មែរក្រហម និងខ្លះទៀតបានភៀសខ្លួនចេញពីប្រទេស បន្ទាប់ពីសង្គ្រាម ចំនួនអ្នកចេះដឹង អ្នកជំនាញ និងអ្នកមានបទពិសោធន៍មានចំនួនតិចតួចបំផុត។ គ្រានោះអ្នកដែលនៅរស់រានមានជីវិត និងមានសមត្ថភាពមួយចំនួនដែលនៅសេសសល់ក្នុងប្រទេស មានការភ័យខ្លាចក្នុងការធ្វើការងារ ដោយសារពួកគេនៅមានការបារម្ភថារបបខ្មែរក្រហមអាចនឹងវិលត្រឡប់មកវិញ។ លើសពីនេះទៀត គឺមានកង្វះខាតយ៉ាងធ្ងន់ធ្ងរនៃធនធានហិរញ្ញវត្ថុ។ ក្នុងពេលដែលសេដ្ឋកិច្ចនៅទន់ខ្សោយនៅឡើយ ហើយការផ្គត់ផ្គង់សាច់ប្រាក់ស្ទើរតែមិនមានទាល់តែសោះ ដោយសារតែគោលនយោបាយ

របស់ខ្មែរក្រហម សកម្មភាពសេដ្ឋកិច្ចនៅតែត្រូវបានធ្វើឡើងជាលក្ខណៈដោះដូរទំនិញនឹងទំនិញ ចំណែកឯប្រាក់ខែមន្ត្រីរាជការស៊ីវិលត្រូវបានទូទាត់ដោយប្រើអង្ករ ត្រី ប្រេង ជាដើម។ រហូតដល់ថ្ងៃទី ២០ ខែមីនា ឆ្នាំ១៩៨០ ធនាគារនៃប្រជាជនកម្ពុជាបានបោះផ្សាយប្រាក់រៀលដែលជារូបិយវត្ថុជាតិឡើងវិញ ដើម្បីសម្រួលដល់ការដោះដូរទំនិញ និងការទូទាត់ប្រាក់បៀវត្សជូនមន្ត្រីរាជការ។ បើទោះបីជាជួបប្រទះនូវបញ្ហាប្រឈមទាំងនេះជារៀងរាល់ថ្ងៃ ខែ ឆ្នាំក៏ដោយ ក៏មន្ត្រី បុគ្គលិកធនាគារជាតិនៃកម្ពុជានៅតែបន្តជម្នះពុះពារគ្រប់ឧបសគ្គឆ្ពោះទៅមុខជានិច្ច ដើម្បីកសាងធនាគារជាតិឡើងវិញបន្តិចម្តងៗ។

### ២.១.៣. ដំណាក់កាលកសាងធនាគារជាតិនៃកម្ពុជាឡើងវិញ (១៩៧៩-១៩៩៣)

ក្នុងអំឡុងទសវត្សឆ្នាំ១៩៨០ ធនាគារនៃប្រជាជនកម្ពុជាមានតួនាទីចម្បងៗបីគឺ ជាអាជ្ញាធររូបិយវត្ថុ ជារតនាគារជាតិ និងជាអ្នកផ្តល់សេវាកម្មធនាគារ ដែលរួមមាន សេវាឥណទាន សេវាទទួលប្រាក់បញ្ញើ និងសេវាទូទាត់។ ចាប់តាំងពីអគារស្នាក់ការធនាគារជាតិនៃកម្ពុជាត្រូវបានកម្ទេចចោលដោយពួកខ្មែរក្រហម ស្នាក់ការកណ្តាលបណ្តោះអាសន្នរបស់ធនាគារ ត្រូវបានបើកនៅជាន់លើនៃធនាគារខ្មែរពាណិជ្ជ។ ធនាគារប្រជាជននៃកម្ពុជា បានបង្កើតរចនាសម្ព័ន្ធដឹកនាំ ក៏ដូចជាសកម្មភាពប្រតិបត្តិការជាច្រើនទៀត និងបានពង្រីកបណ្តាញសាខារបស់ខ្លួនដល់ ២៤ ខេត្ត-ក្រុងទូទាំងប្រទេសកម្ពុជា។ ចាប់តាំងពីឆ្នាំ១៩៨៩មក ប្រព័ន្ធធនាគារបានធ្វើកំណែទម្រង់បន្តិចម្តងៗតាមរយៈការផ្លាស់ប្តូរធនាគារខេត្ត-ក្រុងចំនួន២០ ទៅជាធនាគារឯកទេសខេត្ត-ក្រុង ហើយធ្វើប្រតិបត្តិការជាមួយនឹងស្វ័យភាពហិរញ្ញវត្ថុនិងសេដ្ឋកិច្ចនៅក្នុងដែនដីរបស់ពួកគេ។ ក្នុងនាមជាអាជ្ញាធររូបិយវត្ថុ ធនាគារនៃប្រជាជនកម្ពុជាបានត្រួតពិនិត្យលើដំណើរការរបស់ធនាគារពាណិជ្ជទាំងអស់នោះ។ សូមបញ្ជាក់ថាអគារស្នាក់ការធនាគារជាតិនៃកម្ពុជាត្រូវបានកសាងឡើងវិញនៅឆ្នាំ១៩៩០។ នៅក្នុងឆ្នាំ១៩៩១ ធនាគារពាណិជ្ជដំបូងគេ (ធនាគារពាណិជ្ជកម្ពុជា"CCB") ត្រូវបានបង្កើតឡើងក្រោមទម្រង់ជាធនាគារវិនិយោគរួមគ្នារបស់រដ្ឋ ដើម្បីទាក់ទាញវិនិយោគិន និងបម្រើឱ្យសកម្មភាពអាជ្ញាធរអ៊ុនតាក់ប្រចាំនៅកម្ពុជា។ នៅក្រោមសន្ធិសញ្ញាសន្តិភាពទីក្រុងប៉ារីសថ្ងៃទី ២៣ ខែតុលា ឆ្នាំ១៩៩១ កម្ពុជាបានផ្លាស់ប្តូររបបសេដ្ឋកិច្ចរបស់ខ្លួន ពីសេដ្ឋកិច្ចផែនការមកជាសេដ្ឋកិច្ចទីផ្សារសេរីវិញ។

នៅថ្ងៃទី៣០ ខែមករា ឆ្នាំ១៩៩២ រដ្ឋសភាជាតិបានអនុម័តច្បាប់ស្តីពីការប្តូរឈ្មោះ និងកាតព្វកិច្ចរបស់ធនាគារជាតិនៃកម្ពុជាពី "ធនាគារនៃប្រជាជនកម្ពុជា" មកជា "ធនាគារជាតិ នៃកម្ពុជា" វិញ ដែលត្រូវបានប្រកាសឱ្យប្រើដោយក្រុមប្រឹក្សារដ្ឋនាថ្ងៃទី០៨ ខែមីនា ឆ្នាំ១៩៩២។

បន្ទាប់ពីនោះធនាគារជាតិនៃកម្ពុជា បានចងក្រង និងរៀបចំជាផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០០១-២០១០។ ឯកសារនេះមានមុខងារជាមូលដ្ឋានគ្រឹះសម្រាប់យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ដើម្បីបង្កើនទំនុកចិត្តរបស់សាធារណជនចំពោះប្រព័ន្ធធនាគារ និងវិធីសាស្ត្រដែលកម្ពុជាអាចធ្វើសមាហរណកម្មទៅក្នុងប្រព័ន្ធហិរញ្ញវត្ថុសកល។ តាងនាមជាធនាគារកណ្តាលរបស់ជាតិ ធនាគារជាតិនៃកម្ពុជាបានធ្វើការកែលម្អអគារស្នាក់ការនៅឆ្នាំ២០០៣ ដើម្បីស្តារមុខមាត់ និងកិត្យានុភាពរបស់ខ្លួនឱ្យបានប្រសើរ ។

គេសង្កេតឃើញថាប្រព័ន្ធធនាគារនៅកម្ពុជាមានការរីកចម្រើនយ៉ាងគួរឱ្យកត់សម្គាល់ ជាពិសេសគឺចាប់តាំងពីពាក់កណ្តាលទសវត្សឆ្នាំ១៩៩០ នៅពេលដែលច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា ច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងបទប្បញ្ញត្តិនានាក៏ដូចជាគន្លឹះនៃការធ្វើកំណែទម្រង់វិស័យធនាគារសំខាន់ផ្សេងទៀតត្រូវបានអនុវត្តន៍ ។

### ២.១.៤. ដំណាក់កាលទំនើបភាវូនីយកម្មប្រព័ន្ធធនាគារ (១៩៩៣ ដល់បច្ចុប្បន្ន)

នៅពេលបច្ចុប្បន្ន ប្រព័ន្ធធនាគារនៅកម្ពុជា រួមមានធនាគារពាណិជ្ជចំនួន៣៦ ធនាគារឯកទេសចំនួន១១ តំណាងធនាគារបរទេសចំនួន៧ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំនួន៣៩ (ក្នុងនោះរួមបញ្ចូលទាំងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើចំនួន៧) ប្រតិបត្តិករឥណទានជនបទចំនួន៣៨ ក្រុមហ៊ុនជួលចំនួន៦ ការិយាល័យឥណទានចំនួន១ ដំណើរការតតីយភាគី ចំនួន៦ និងអាជីវករប្តូរប្រាក់ចំនួន១៧៧០។ គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុបាននិងកំពុងបន្តពង្រីក បណ្តាញប្រតិបត្តិការរបស់ខ្លួន តាមរយៈការបើកសាខា និងការិយាល័យតំណាងជាច្រើនកន្លែងក្នុងរាជធានីខេត្ត និងបន្តតម្លើងម៉ាស៊ីនដកប្រាក់ដោយស្វ័យប្រវត្តិបន្ថែមលើការផ្តល់សេវាទូទាត់អេឡិចត្រូនិក។

ប្រព័ន្ធធនាគារនៅកម្ពុជាមានដំណើរយ៉ាងវែងឆ្ងាយ ពោលគឺចាប់តាំងពីការកសាងមូលដ្ឋានគ្រឹះប្រព័ន្ធធនាគារបន្ទាប់ពីបានទទួលឯករាជ្យមក ការបំផ្លិចបំផ្លាញនៃប្រព័ន្ធរូបិយវត្ថុក្នុងរបបខ្មែរក្រហម បន្ទាប់មកការទូទាត់ប្រាក់បៀវត្សជូនមន្ត្រីរាជការស៊ីវិលដោយអង្ករនិងត្រី រហូតមកដល់ការកសាងវិស័យធនាគារនិងហិរញ្ញវត្ថុ ដែលប្រកបដោយការគ្រប់គ្រងយ៉ាងល្អ និងចាក់ស្រេះចាប់តាំងពីបាតដៃទទេស្អាត។

## ២.២. ទីតាំងភូមិសាស្ត្រ និងសាខារបស់ធនាគារជាតិនៃកម្ពុជា

ធនាគារជាតិនៃកម្ពុជាមានស្នាក់ការកណ្តាលនៅ អគារលេខ២២-២៤ មហាវិថីព្រះនរោត្តម ក្រុងភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា និងលេខទូរស័ព្ទទំនាក់ទំនង (៨៥៥-២៣) ៧២២ ៥៦៣,

(៨៥៥-២៣) ៧២២ ២២១ និង(៨៥៥-២៣) ៧២២ ១៨៩ (ការិយាល័យឯកឧត្តមទេសាភិបាល) ឬ ទំនាក់ទំនងតាមរយៈអ៊ីមែល: info@nbc.org.kh និងគេហទំព័រ: http://www.nbc.org.kh។

ដោយសារតែអគារស្នាក់ការកណ្តាលរបស់ធនាគារជាតិនៃកម្ពុជា ត្រូវធ្វើការសាងសង់ជាថ្មីឡើងវិញជំនួសឱ្យអគារស្នាក់ការចាស់ ដូចនេះស្នាក់ការកណ្តាលធនាគារជាតិនៃកម្ពុជាបានផ្លាស់ប្តូរបណ្តោះអាសន្នទៅកាន់អគារលេខ៦៩-៧០ មហាវិថីហាណូយ (លេខ១០១៩) ភូមិបាយ៉ាប សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ។

រូបភាពទី២.៣៖ អគារស្នាក់ការកណ្តាលធនាគារជាតិនៃកម្ពុជា



ធនាគារជាតិនៃកម្ពុជាមានសាខានៅទូទាំង២១ខេត្ត-ក្រុង[10] ក្នុងព្រះរាជាណាចក្រកម្ពុជា ដែលរួមមាន៖

- **សាខាធនាគារជាតិនៃកម្ពុជា រាជធានីភ្នំពេញ**
  មានអាសយដ្ឋាន៖ អគារលេខ២៧៣ ផ្លូវលេខ១១០ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ ក្រុងភ្នំពេញ
  ទូរស័ព្ទ៖ (៨៥៥-៥៣) ២២៣ ៧៤១ ទូរសារ៖ (៨៥៥-២៣) ២២៣ ៧៤៥
- **សាខាធនាគារជាតិនៃកម្ពុជា សៀមរាប**
  មានអាសយដ្ឋាន៖ ផ្លូវកែង៩-១០ មណ្ឌល១ ឃុំស្វាយដង្គុំ ស្រុកសៀមរាប ខេត្តសៀមរាប
  ទូរស័ព្ទ៖ (៨៥៥-៦៣) ៩៦៣ ៥៣៤ ទូរសារ៖ (៨៥៥-៦៣) ៩៦៣ ៥៣៤

[10] ប្រភព៖ គេហទំព័រធនាគារជាតិនៃកម្ពុជា ឆ្នាំ២០១៩

- **សាខាធនាគារជាតិនៃកម្ពុជា កំពង់ចាម**
  មានអាសយដ្ឋាន៖ ផ្លូវព្រះមុនីវង្ស ឃុំកំពង់ចាម ស្រុកកំពង់ចាម ខេត្តកំពង់ចាម
  ទូរស័ព្ទ៖ (៨៥៥-៤២) ៩៤១ ៩៥៨ ទូរសារ៖ (៨៥៥-៤២) ៩៤១ ៩៥៨
- **សាខាធនាគារជាតិនៃកម្ពុជា កំពង់ឆ្នាំង**
  មានអាសយដ្ឋាន៖ ផ្លូវនរោត្តម ភូមិឃ្លាំងប្រាក់ ឃុំប្អេរ ស្រុកកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង
  ទូរស័ព្ទ៖ (៨៥៥-២៦) ៩៨៨ ៦៧៤ ទូរសារ៖ (៨៥៥-២៦) ៩៨៨ ៦៧៤
- **សាខាធនាគារជាតិនៃកម្ពុជា បាត់ដំបង**
  មានអាសយដ្ឋាន៖ ផ្ទះលេខ៧០-៧១ ផ្លូវលេខ១ ភូមិ២០ឧសភា សង្កាត់ស្វាយប៉ោ បាត់ដំបង
  ទូរស័ព្ទ៖ (៨៥៥-៥៣) ៩៤១ ៩៥៨ ទូរសារ៖ (៨៥៥-២៣) ៧៣០ ១៦៦
- **សាខាធនាគារជាតិនៃកម្ពុជា កំពង់ស្ពឺ**
  មានអាសយដ្ឋាន៖ ផ្លូវជាតិលេខ៤ ភូមិពាណិជ្ជកម្ម ឃុំរកាធំ ស្រុកច្បារមន ខេត្តកំពង់ស្ពឺ
  ទូរស័ព្ទ៖ (៨៥៥-២៥) ៩៨៧ ២១៤ ទូរសារ៖ (៨៥៥-២៥) ៩៨៧ ២១៤
- **សាខាធនាគារជាតិនៃកម្ពុជា កោះកុង**
  មានអាសយដ្ឋាន៖ ផ្លូវមាត់ព្រែក ភូមិ១ ឃុំស្មាច់មានជ័យ ស្រុកស្មាច់មានជ័យ ខេត្តកោះកុង
  ទូរស័ព្ទ៖ (៨៥៥-៣៥) ៩៣៦ ២១០ ទូរសារ៖ (៨៥៥-៣៥) ៩៣៦ ២១០
- **សាខាធនាគារជាតិនៃកម្ពុជា ក្រចេះ**
  មានអាសយដ្ឋាន៖ ផ្លូវកុសុមៈ ភូមិក្រចេះ ស្រុកក្រចេះ ខេត្តក្រចេះ
  ទូរស័ព្ទ៖ (៨៥៥-៧២) ៩៧១ ៦៩៥ ទូរសារ៖ (៨៥៥-៧២) ៩៧១ ៦៩៥
- **សាខាធនាគារជាតិនៃកម្ពុជា រតនគិរី**
  មានអាសយដ្ឋាន៖ ផ្លូវ៧៨ ភូមិ១ ឃុំឡាបានសៀក ស្រុកបានលុង ខេត្តរតនគិរី
  ទូរស័ព្ទ៖ (៨៥៥-៧៥) ៩៧៤ ១៧៣ ទូរសារ៖ (៨៥៥-៧៥) ៩៧៤ ១៧៣
- **សាខាធនាគារជាតិនៃកម្ពុជា មណ្ឌលគិរី**
  មានអាសយដ្ឋាន៖ ភូមិស្វាយចេក ឃុំសុខដុម ស្រុកសែនមនោរម្យ ខេត្តមណ្ឌលគិរី
  ទូរស័ព្ទ៖ (៨៥៥-១២) ៦៥៦ ០៧០ ទូរសារ៖ មិនមាន
- **សាខាធនាគារជាតិនៃកម្ពុជា ស្វាយរៀង**
  មានអាសយដ្ឋាន៖ ភូមិសួនថ្មី ឃុំព្រៃឆ្លាក់ ស្រុកស្វាយរៀង ខេត្តស្វាយរៀង
  ទូរស័ព្ទ៖ (៨៥៥-៤៤) ៩៤៥ ៩៨៩ ទូរសារ៖ (៨៥៥-៤៤) ៩៤៥ ៩៨៩

- **សាខាធនាគារជាតិនៃកម្ពុជា បន្ទាយមានជ័យ**
  មានអាសយដ្ឋាន៖ ប្លុកអ៊ុយ ភូមិ៣ ឃុំព្រះពន្លា ស្រុកសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ
  ទូរស័ព្ទ៖ (៨៥៥-៥៤) ៧១០ ១៦៩ ទូរសារ៖ (៨៥៥-៥៤) ៧១០ ១៦៩
- **សាខាធនាគារជាតិនៃកម្ពុជា ស្ទឹងត្រែង**
  មានអាសយដ្ឋាន៖ ផ្លូវលេខ២ ភូមិព្រែក ឃុំស្ទឹងត្រែង ស្រុកស្ទឹងត្រែង ខេត្តស្ទឹងត្រែង
  ទូរស័ព្ទ៖ (៨៥៥-៧៤) ៩៧៣ ៩០៦ ទូរសារ៖ (៨៥៥-៧៤) ៩៧៣ ៩០៦
- **សាខាធនាគារជាតិនៃកម្ពុជា កំពង់ធំ**
  មានអាសយដ្ឋាន៖ ផ្លូវស្ទឹងសែន ភូមិលេខ១ ឃុំកំពង់ធំ ស្រុកស្ទឹងសែន ខេត្តកំពង់ធំ
  ទូរស័ព្ទ៖ (៨៥៥-៦២) ៩៦១ ៣០៩ ទូរសារ៖ (៨៥៥-៦២) ៩៦១ ៣០៩
- **សាខាធនាគារជាតិនៃកម្ពុជា ពោធិ៍សាត់**
  មានអាសយដ្ឋាន៖ ផ្លូវលេខ១ ភូមិពាលញែក សង្កាត់ផ្ទះព្រៃ ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់
  ទូរស័ព្ទ៖ (៨៥៥-៥២) ៩៥១ ៥៨១ ទូរសារ៖ (៨៥៥-៥២) ៩៥១ ៥៨១
- **សាខាធនាគារជាតិនៃកម្ពុជា តាកែវ**
  មានអាសយដ្ឋាន៖ ផ្លូវលេខ១១ ភូមិ១ ឃុំរកាក្នុង ស្រុកដូនកែវ ខេត្តតាកែវ
  ទូរស័ព្ទ៖ (៨៥៥-៣២) ៩៣១ ៣២៧ ទូរសារ៖ (៨៥៥-៣២) ៩៣១ ៣២៧
- **សាខាធនាគារជាតិនៃកម្ពុជា កំពត**
  មានអាសយដ្ឋាននៅ៖ ផ្លូវមាត់ព្រែក ភូមិ១ឧសភា ឃុំកំពង់កណ្តាល ស្រុកកំពង់បាយ ខេត្តកំពត
  ទូរស័ព្ទ៖ (៨៥៥-៣៣) ៩៣២ ៨៣០ ទូរសារ៖ (៨៥៥-៣៣) ៩៣២ ៨៣០
- **សាខាធនាគារជាតិនៃកម្ពុជា ព្រៃវែង**
  មានអាសយដ្ឋាន៖ ផ្លូវមាត់ទន្លេ ភូមិ៣ ឃុំកំពង់លាវ ស្រុកកំពង់លាវ ខេត្តព្រៃវែង
  ទូរស័ព្ទ៖ (៨៥៥-៤៣) ៩៤៤ ៥៥៦ ទូរសារ៖ (៨៥៥-៤៣) ៩៤៤ ៥៥៦
- **សាខាធនាគារជាតិនៃកម្ពុជា កណ្តាល**
  មានអាសយដ្ឋាន៖ ផ្លូវ១០៤ ភូមិតាខ្មៅ ឃុំតាខ្មៅ ស្រុកតាខ្មៅ ខេត្តកណ្តាល
  ទូរស័ព្ទ៖ (៨៥៥-២៣) ៤២៥ ៦៦៤ ទូរសារ៖ (៨៥៥-២៣) ៤២៥ ៦៦៤
- **សាខាធនាគារជាតិនៃកម្ពុជា ខេត្តព្រះសីហនុ**
  មានអាសយដ្ឋាន៖ ផ្លូវពោកំបោរ សង្កាត់លេខ៣ ខណ្ឌមិត្តភាព ខេត្តព្រះសីហនុ
  ទូរស័ព្ទ៖ (៨៥៥-៣៤) ៩៣៣ ៦៤៩ ទូរសារ៖ (៨៥៥-៣៤) ៩៣៣ ៦៤៩

- **សាខាធនាគារជាតិនៃកម្ពុជា ព្រះវិហារ**
  មានអាសយដ្ឋាន៖ ផ្លូវលេខ២ ភូមិកណ្តាល ឃុំកំពង់ប្រណាក ស្រុកត្បែងមានជ័យ ព្រះវិហារ ទូរស័ព្ទ៖ (៨៥៥-១២) ៩៥២ ០៣៥ ទូរសារ៖ មិនមាន។

## ២.៣. អត្តសញ្ញាណរបស់ធនាគារជាតិនៃកម្ពុជា

អត្តសញ្ញាណរបស់ធនាគារជាតិនៃកម្ពុជាគឺ **ប្រាក់រៀល**។

ធនាគារជាតិនៃកម្ពុជា មានរូបសញ្ញា (LOGO) ដែលមានអក្សរ ៛ ពណ៌ប្រាក់ជាតំណាង និងរង្វង់កួរស្រូវពណ៌មាសព័ទ្ធជុំវិញផងដែរ។

រូបនីមួយមានអត្ថន័យបង្ហាញអំពី៖

- ៛ តំណាងឱ្យប្រាក់រៀលដែលបោះផ្សាយ
- **កួរស្រូវ** តំណាងឱ្យវិស័យកសិកម្មដែលមានកួរស្រូវបីជួរអមសងខាងអក្សរ ៛ ហើយក្នុងកួរស្រូវមួយជួរ មានគ្រាប់ស្រូវចំនួនប្រាំពីរគ្រាប់ ដែលតំណាងឱ្យថ្ងៃ៧មករា។

រូបភាពទី២.៤៖ និមិត្តសញ្ញារបស់ធនាគារជាតិនៃកម្ពុជា

## ២.៤. បេសកកម្ម មុខងារ និងតួនាទីរបស់ធនាគារជាតិនៃកម្ពុជា

បេសកកម្មចម្បងរបស់ធនាគារជាតិនៃកម្ពុជា ដែលជាធនាគារកណ្តាលរបស់ប្រទេសកម្ពុជា គឺការកំណត់ និងដឹកនាំគោលនយោបាយរូបិយវត្ថុ ក្នុងគោលដៅរក្សាស្ថិរភាពថ្លៃ សំដៅរួមចំណែកជំរុញការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ។ ធនាគារជាតិនៃកម្ពុជាមានមុខងារ និងតួនាទីដូចតទៅ៖

- ដើរតួជាអ្នកកំណត់គោលនយោបាយរូបិយវត្ថុដោយពិគ្រោះជាមួយរាជរដ្ឋាភិបាល នៅក្នុងក្របខ័ណ្ឌនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៃព្រះរាជាណាចក្រកម្ពុជា ។

- ស្វែងរកវិធីអនុវត្តន៍ ត្រួតពិនិត្យ នយោបាយរូបិយវត្ថុ និងប្តូរប្រាក់ ឱ្យសម្រេចទៅតាមគោលដៅដែលបានកំណត់។
- ធ្វើការតាមដាន និងវិភាគស្ថានភាពសេដ្ឋកិច្ច និងរូបិយវត្ថុជាប្រក្រតី រួចចេញផ្សាយលទ្ធផល ហើយលើកសំណើ និងវិធានការជូនរាជរដ្ឋាភិបាលដើម្បីធ្វើការសម្រេច។
- ផ្តល់ ឬ ដកហូតអាជ្ញាប័ណ្ណអាជីវកម្មចំពោះគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ និងគ្រឹះស្ថានឯទៀតដែលពាក់ព័ន្ធដូចជា ស្នងការគណនី គ្រឹះស្ថានជម្រះបញ្ជីជាដើម ព្រមទាំងចេញបទបញ្ជា និងធ្វើការត្រួតពិនិត្យគ្រឹះស្ថានទាំងនោះ។
- ត្រួតពិនិត្យលើប្រព័ន្ធទូទាត់នៅក្នុងព្រះរាជាណាចក្រកម្ពុជា និងកែលម្អប្រសិទ្ធភាពនៃការទូទាត់អន្តរធនាគារ ។
- ទទួលភារៈផ្តាច់មុខជាអ្នកបោះផ្សាយរូបិយវត្ថុជាតិ (ប្រាក់រៀល) នៃព្រះរាជាណាចក្រកម្ពុជា ។
- ជាអ្នកទទួលខុសត្រូវ និងអនុវត្តន៍ក្នុងនាមនៃព្រះរាជាណាចក្រកម្ពុជានូវកិច្ចការទាំងឡាយដែលជាលទ្ធផលនៃការចូលរួមរបស់ព្រះរាជាណាចក្រកម្ពុជាជាមួយស្ថាប័នអន្តរជាតិ ស្ថាប័នសាធារណៈ ក្នុងកិច្ចការធនាគារ ឥណទានរូបិយវត្ថុ។
- តាមដាន និងតម្លើងតារាងជញ្ជីងទូទាត់។
- ចូលរួមក្នុងការគ្រប់គ្រងបំណុល និងឥណទេយ្យជាមួយប្រទេសក្រៅ។
- ចូលរួមក្នុងការបង្កើត និងការត្រួតពិនិត្យទីផ្សាររូបិយវត្ថុ និងទីផ្សារហិរញ្ញវត្ថុ។
- ផ្តល់ ឬដកហូតអាជ្ញាប័ណ្ណចំពោះគ្រឹះស្ថានដែលចូលរួមក្នុងអាជីវកម្មទីផ្សារប្តូរប្រាក់ សង្ហារឹម ត្បូងថ្ម និង លោហធាតុមានតម្លៃព្រមទាំងចេញបទបញ្ជា និងត្រួតពិនិត្យលើសកម្មភាពគ្រឹះស្ថានទាំងនោះ។
- ចុងក្រោយធនាគារជាតិនៃកម្ពុជា គឺដើរតួជាអ្នកកំណត់អត្រាការប្រាក់ ៕

## ២.៥. រចនាសម្ព័ន្ធរបស់ធនាគារជាតិនៃកម្ពុជា

### ២.៥.១. រចនាសម្ព័ន្ធភារៈងារ

ក្រុមប្រឹក្សាភិបាលជាគណៈគ្រប់គ្រង ដែលមានសិទ្ធិក្នុងការធ្វើសេចក្តីសម្រេចលើផែនការ និងគោលនយោបាយរបស់ធនាគារជាតិនៃកម្ពុជា នៅធនាគារជាតិនៃកម្ពុជា និងមានសមាសភាពចំនួន ៧ រូបគឺ ទេសាភិបាល ទេសាភិបាលរង តំណាងប្រមុខរដ្ឋាភិបាល តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តំណាងមជ្ឈដ្ឋានឧត្តមសិក្សា តំណាងមជ្ឈដ្ឋានធ្វើសកម្មភាពសេដ្ឋកិច្ច និងតំណាងមន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជា។ ទេសាភិបាលជាប្រធានក្រុមប្រឹក្សាភិបាល និងមានតួនាទីជា

នាយកប្រតិបត្តិនៃធនាគារជាតិនៃកម្ពុជា ជាអ្នករាយការណ៍ជូនក្រុមប្រឹក្សាភិបាល និងទទួលខុសត្រូវចំពោះកិច្ចការអនុវត្តគោលនយោបាយនិងប្រតិបត្តិការប្រចាំថ្ងៃ។ ទេសាភិបាលត្រូវបានតែងតាំង ដាក់ជំនួស និងបញ្ឈប់ពីតំណែងដោយព្រះរាជក្រឹត្យ ដែលយោងតាមទៅសំណើរបស់រាជរដ្ឋាភិបាល។

ក្នុងកម្រិតបច្ចេកទេស ធនាគារជាតិនៃកម្ពុជាមានប្រាំអគ្គនាយកដ្ឋានគឺ អគ្គលេខាធិការ-ដ្ឋាន អគ្គនាយកដ្ឋានបច្ចេកទេស អគ្គនាយកដ្ឋានត្រួតពិនិត្យ អគ្គបេឡា និងអគ្គាធិការដ្ឋាន ដែលក្នុងនោះរួមមាន២១ នាយកដ្ឋាន ដឹកនាំដោយប្រធាននាយកដ្ឋាន ។ នាយកដ្ឋាន និងអគ្គនាយក-ដ្ឋាននីមួយៗ មានតួនាទី ទទួលខុសត្រូវចំពោះការអនុវត្តមុខងារប្រចាំថ្ងៃនៃប្រតិបត្តិការធនាគារកណ្តាល និងគោលនយោបាយរបស់ធនាគារជាតិនៃកម្ពុជា ។

តារាងទី២.១៖ រចនាសម្ព័ន្ធការងាររបស់ធនាគារជាតិនៃកម្ពុជា




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## ២.៥.២. ក្រុមប្រឹក្សាភិបាល

អង្គការគ្រប់គ្រងរបស់ធនាគារកណ្ដាលគឺ ក្រុមប្រឹក្សាភិបាល។ ក្រុមប្រឹក្សាភិបាល នេះត្រូវដឹកនាំដោយទេសាភិបាល។ ក្រុមប្រឹក្សាភិបាលនេះមានសមាជិកចំនួន ៧រូប គឺទេសាភិបាល ទេសាភិបាលរង និង សមាជិក៥រូបទៀត ដែល១រូបតំណាងប្រមុខរដ្ឋាភិបាល ១រូបតំណាងឱ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ១រូបតំណាងឱ្យមជ្ឈដ្ឋានធ្វើសកម្មភាពសេដ្ឋកិច្ច ១រូបតំណាងឱ្យមជ្ឈដ្ឋានឧត្តមសិក្សា និង១រូបទៀតតំណាងឱ្យបុគ្គលិកធនាគារកណ្ដាល។

រូបភាពទី២.៥៖ ក្រុមប្រឹក្សាភិបាលធនាគារជាតិនៃកម្ពុជា (ប្រភពធនាគារជាតិនៃកម្ពុជា)



ប្រធាន

**ឯកឧត្តម ជាចាន់តូ**

អគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា



**លោកជំទាវ នាវ ច័ន្ទថាណា**

ទេសាភិបាលរងនៃធនាគារជាតិនៃកម្ពុជា



**ឯកឧត្តម ជូ គឹមឡេង**

តំណាងប្រមុខរាជរដ្ឋាភិបាល



**ឯកឧត្តម រស់ សីលវ៉ា**

តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ



**ឯកឧត្តម អ៊ីវ ចុង**

តំណាងមជ្ឈដ្ឋានឧត្តមសិក្សា



**លោក ឡាយ ម៉េងស៊ុន**

តំណាងមជ្ឈដ្ឋានធ្វើសកម្មភាពសេដ្ឋកិច្ច



**អ្នកស្រី ម៉ៅ សុន**

តំណាងបុគ្គលិកធនាគារជាតិនៃកម្ពុជា

### ២.៥.៣. ស្ថិតិមន្ត្រីបុគ្គលិក

នៅចុងឆ្នាំ២០១៨នេះ សរុបក្រុបខ័ណ្ឌមន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជាទូទាំងប្រទេសមានចំនួន១៦៦៣រូប (ប្រុស៨៧២រូប ស្រី៧៩១រូប) ដែលក្នុងនោះទីស្នាក់ការកណ្តាលមានចំនួន ១១៩០រូប (ប្រុស៦៤០រូប ស្រី៥៥០រូប) និងសាខារាជធានីខេត្ត មានចំនួន៤៧៣រូប (ប្រុស២៣២រូប និងស្រី២៤១រូប)។

តារាងទី២.២៖ ស្ថិតិមន្ត្រី-បុគ្គលិកធនាគារជាតិនៃកម្ពុជាប្រចាំឆ្នាំ២០១៨

| | | **ឆ្នាំ២០១៦** | **ឆ្នាំ២០១៧** | **ឆ្នាំ២០១៨** | **ប្រែប្រួល** |
|---|---|---|---|---|---|
| **ទីស្នាក់ការកណ្តាល** | ប្រុស | ៥៨២ | ៦២២ | ៦៤០ | ១៨ |
| | ស្រី | ៤៦៩ | ៥៥៣ | ៥៥០ | -៣ |
| | សរុប | ១០៥១ | ១១៧៥ | ១១៩០ | ១៥ |
| **សាខា** | ប្រុស | ២២៨ | ២៣៥ | ២៣២ | -៣ |
| | ស្រី | ២៣៥ | ២៤៤ | ២៤១ | -៣ |
| | សរុប | ៤៦៣ | ៤៧៩ | ៤៧៣ | -៦ |
| **សរុបទូទាំងប្រទេស** | ប្រុស | ៨១០ | ៨៥៧ | ៨៧២ | ១៥ |
| | ស្រី | ៧០៤ | ៧៩៧ | ៧៩១ | -៦ |
| | សរុប | **១៥១៨** | **១៦៥៤** | **១៦៦៣** | **៩** |

ប្រភព៖ ធនាគារជាតិនៃកម្ពុជា

សរុបកម្រិតវប្បធម៌មន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជានៅចុងឆ្នាំ២០១៨ មានបណ្ឌិតចំនួន ១០រូប អនុបណ្ឌិតចំនួន៣៥៦រូប បរិញ្ញាបត្រចំនួន៥៦៨រូប បរិញ្ញាបត្ររងចំនួន៣១២រូប និងផ្សេងៗ ចំនួន៤១៧រូប។

ក្រាហ្វទី២.១៖ ស្ថិតិមន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជា តាមកម្រិតវប្បធម៌




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

# ជំពូកទី៣

# លទ្ធផលនៃការស្រាវជ្រាវ

## ៣.១. មូលហេតុ និងឫសគល់នៃការបាត់បង់ទំនុកចិត្តមកលើប្រាក់រៀល

សារតារនៃការបង្កើតរូបិយវត្ថុជាតិនៅកម្ពុជាមានរយៈពេលខ្លី បើប្រៀបធៀបនឹងប្រទេសជិតខាងនានានៅក្នុងតំបន់ និងពិភពលោក។ ធនាគារកណ្តាល ឬធនាគារជាតិនៃកម្ពុជាត្រូវបានបង្កើតឡើងជាលើកដំបូងនៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ១៩៥៤ ហើយរូបិយវត្ថុជាតិ "ប្រាក់រៀល" ក៏ត្រូវបានបង្កើតឡើងព្រមគ្នាផងដែរ។ នាពេលនោះប្រជាពលរដ្ឋកម្ពុជាបានទទួលស្គាល់យ៉ាងទូលំទូលាយលើប្រាក់រៀល ក្រោយពីការដាក់ឱ្យចរាចរជាផ្លូវការ។ ជាអកុសល ទំនុកចិត្តលើការប្រើប្រាស់ប្រាក់រៀលខ្មែរត្រូវបានបំផ្លាញទាំងស្រុង នៅក្នុងកំឡុងពេលសង្គ្រាមស៊ីវិល ដែលអូសបន្លាយអស់រយៈពេលជិត៣០ឆ្នាំ។

រដ្ឋប្រហារ លន់ នល់ នៅឆ្នាំ១៩៧០ បានរុញច្រានប្រទេសកម្ពុជាឱ្យធ្លាក់ក្នុងអស្ថិរភាពនយោបាយ និងសេដ្ឋកិច្ច ដែលធ្វើឱ្យសាធារណជនបាត់បង់ជំនឿទុកចិត្តទៅលើរដ្ឋាភិបាល សេដ្ឋកិច្ច និងរូបិយវត្ថុជាតិ។ សង្គ្រាមបានកើតឡើងនៅស្ទើរគ្រប់ទីកន្លែង ប្រទេសត្រូវបានកាត់ផ្តាច់ជាបំណែកៗ ហើយផលិតកម្មក្នុងស្រុកបានថមថយជាលំដាប់។ ប្រព័ន្ធសេដ្ឋកិច្ចកម្ពុជាបានធ្លាក់ចុះដុនដាបជាខ្លាំង ហើយប្រទេសទាំងមូលត្រូវពឹងផ្អែកទៅលើជំនួយពីបរទេស។ អត្រាអតិផរណាបានកើនឡើងកាន់តែខ្លាំងឡើងៗ ដោយសារកង្វះការផ្គត់ផ្គង់ក្នុងស្រុក ហើយថវិការដ្ឋត្រូវបំពេញបន្ថែមដោយបុរេប្រទានពីធនាគារកណ្តាល។ ធនាគារជាតិនៃកម្ពុជានាពេលនោះបានបោះពុម្ពប្រាក់បន្ថែមជាច្រើន ដើម្បីបំពេញឱនភាពថវិការដ្ឋ ជាពិសេសសម្រាប់បើកប្រាក់បៀវត្សឱ្យមន្ត្រីរាជការ។ តាមរយៈការសិក្សាលើអតិផរណានាសម័យនោះបានបង្ហាញថា ថ្លៃទំនិញនានាបានឡើងថ្លៃជាបន្តបន្ទាប់យ៉ាងឆាប់រហ័ស ឧទាហរណ៍ដូចជា ថ្លៃគុយទាវមួយចាន ដែលធ្លាប់មានតម្លៃ៥០រៀល បានឡើងដល់៥០០រៀល រួចឡើងដល់ទៅ១.០០០រៀល ចំណែកឯថ្លៃមេជ្រូកមួយក្បាលបានកើនថ្លៃដល់១លានរៀល គឺស្មើនឹងបៀវត្សមន្ត្រីថ្នាក់មធ្យមម្នាក់ក្នុងពេលពីរឆ្នាំ។ ដោយសារតែភាពមិនច្បាស់លាស់នៃស្ថានភាពនយោបាយ និងអស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចទាំងក្នុង និងក្រៅប្រទេស (កំណើនអត្រាអតិផរណា ឱនភាពថវិការដ្ឋ កំណើនការនាំចូល និងការធ្លាក់ចុះខ្លាំងនៃផលិតកម្មក្នុងស្រុក។ល។) បានធ្វើឱ្យប្រជាពលរដ្ឋបាត់បង់ជំនឿទុកចិត្តយ៉ាងខ្លាំងទៅលើរូបិយវត្ថុជាតិ។ មានការសម្គាល់ឃើញថា នៅក្នុងសម័យ លន់ នល់ ប្រាក់ដុល្លារបានហូរចូលប្រទេសកម្ពុជាកាន់តែច្រើនតាមរូបភាពជាជំនួយពីសហរដ្ឋអាមេរិក ហើយការរក្សាទុក និងប្រើប្រាស់ប្រាក់ដុល្លារ

អាមេរិក ត្រូវបានសង្កេតឃើញថាមាននៅក្នុងមជ្ឈដ្ឋានអ្នកមានបុព្វសិទ្ធិដែលស្ថិតនៅក្បែរអ្នកកាន់អំណាច អ្នករកស៊ីលួចលាក់ក្នុងសង្គ្រាម និងអ្នកទទួលផលពីជំនួយរបស់ប្រទេសអាមេរិក។ ជាងនេះទៅទៀត រូបិយវត្ថុជាតិត្រូវបានបាត់បង់ទាំងស្រុងក្នុងរបបប្រល័យពូជសាសន៍ ប៉ុល ពត (១៩៧៥-១៩៧៩)។ សង្គមជាតិទាំងមូលត្រូវបានប្រែក្លាយទៅជាសង្គមទាសភាព គ្មានកម្មសិទ្ធិឯកជន គ្មានទីផ្សារ គ្មានរូបិយវត្ថុ និងគ្មានសិទ្ធិសេរីភាពអ្វីទាំងអស់។ ប្រវត្តិសាស្ត្រ និងបទពិសោធន៍ដ៏ខ្លោចផ្សារទាំងនេះ គឺជាឫសគល់ចម្បងនៃការបាត់បង់ជំនឿទុកចិត្តរបស់ប្រជាជនមកលើរូបិយវត្ថុជាតិមកដល់សព្វថ្ងៃ។

ក្រោយពីថ្ងៃរំដោះ៧ មករា ឆ្នាំ១៩៧៩ ប្រទេសជាតិនិងប្រជាជនកម្ពុជាទាំងមូលបានរួចផុតពីសង្គមខ្មៅងងឹតនៃរបប ប៉ុល ពត ហើយសេដ្ឋកិច្ចជាតិក៏បានចាប់ផ្តើមមានសកម្មភាពឡើងវិញបន្តិចម្តងៗពីបាតដៃទទេស្អាត។ នៅថ្ងៃទី១០ ខែតុលា ឆ្នាំ១៩៧៩ ធនាគារកណ្តាលត្រូវបានបង្កើតឡើង ហើយនៅថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៨០ ប្រាក់រៀលក៏ត្រូវបានដាក់ឱ្យចរាចរឡើងវិញ។ ក្នុងពេលនោះ ការដោះដូរភាគច្រើនត្រូវបានធ្វើឡើងដោយទំនិញនឹងទំនិញនៅឡើយ ហើយវត្ថុមានតម្លៃដូចជាមាស ប្រាក់ ចលនវត្ថុមួយចំនួនដូចជាកង់ និងស្បៀងអាហារមួយចំនួនដូចជាអង្ករ ត្រី សាច់ ថ្នាំជក់ ត្រូវបានប្រើប្រាស់ជាមធ្យោបាយសម្រាប់ដោះដូរ។ នៅក្នុងស្ថានភាពដែលសេដ្ឋកិច្ចជាតិនិងថវិការដ្ឋនៅទន់ខ្សោយ ផលិតកម្មក្នុងស្រុកនៅមានកម្រិតទាប និងការពឹងផ្អែកលើជំនួយពីប្រទេសជាមិត្ត ការពង្រឹងជំនឿទុកចិត្តមកលើរូបិយវត្ថុជាតិគឺជារឿងដ៏លំបាកបំផុត។ ទោះបីជាយ៉ាងណាក៏ដោយ នាដើមទសវត្សរ៍ឆ្នាំ១៩៨០ រដ្ឋបានធ្វើយុទ្ធនាការលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលជាបន្តបន្ទាប់ តាមរយៈការបើកប្រាក់បៀវត្សជូនមន្ត្រីរដ្ឋជាប្រាក់រៀល ហើយនៅពេលនោះ ប្រជាជនក៏ចាប់ផ្តើមប្រើប្រាស់ប្រាក់រៀលទទឹមនឹងវត្ថុមានតម្លៃនានាផងដែរ។

នៅក្នុងពាក់កណ្តាលទី២ នៃទសវត្សរ៍ឆ្នាំ១៩៨០ រដ្ឋបានចាប់ផ្តើមធ្វើកំណែទម្រង់ពីសេដ្ឋកិច្ចមជ្ឈការទៅរកសេដ្ឋកិច្ចបែបទីផ្សារជាងមុន និងបានអនុញ្ញាតបន្តិចម្តងៗឱ្យមានវត្ថុមានជំនួយផ្នែកមនុស្សធម៌របស់អង្គការសហប្រជាជាតិ និងអង្គការក្រៅរដ្ឋាភិបាលផ្សេងៗ និងជំនួយហិរញ្ញវត្ថុពីគ្រួសារខ្មែរនៅបរទេស។ ការបើកលទ្ធភាពបែបនេះ បានធ្វើឱ្យប្រាក់ដុល្លារអាមេរិកហូរចូលទៅក្នុងសេដ្ឋកិច្ចកម្ពុជាដោយសន្សឹមៗ។ លើសពីនេះ កត្តាដែលធ្វើឱ្យប្រជាជនកម្ពុជាបាត់បង់ជំនឿទុកចិត្តមកលើប្រាក់រៀលជាថ្មីម្តងទៀតនោះ គឺនៅចុងទសវត្សរ៍ឆ្នាំ១៩៨០ និងដើមទសវត្សរ៍១៩៩០ រដ្ឋបានជួបប្រទះនឹងឱនភាពថវិកាយ៉ាងខ្លាំង ដែលតម្រូវឱ្យធនាគារកណ្តាលបោះពុម្ពរូបិយវត្ថុបន្ថែមដើម្បីបំពេញនូវការចំណាយរបស់រដ្ឋ ហើយតម្លៃប្រាក់រៀលត្រូវបានធ្លាក់ចុះយ៉ាងខ្លាំង។ វិបត្តិ

ថវិកា និងវិបត្តិរូបិយវត្ថុ គួបផ្សំជាមួយនឹងការហូរចូលយ៉ាងច្រើនសន្ធឹកសន្ធាប់របស់ប្រាក់ដុល្លារនៅក្នុងឆ្នាំ១៩៩១ និង ១៩៩២ ដោយសារការចំណាយរបស់អាជ្ញាធរបណ្ដោះអាសន្នរបស់អង្គការសហប្រជាជាតិនៅកម្ពុជា (UNTAC) បានធ្វើឱ្យប្រជាជនកម្ពុជាទទួលយក ប្រើប្រាស់ និងរក្សាទុកប្រាក់ដុល្លារកាន់តែទូលំទូលាយនៅទូទាំងប្រទេស។ កងរក្សាសន្តិសុខ ជំនាញការ មន្ត្រី និងក្រុមការងាររបស់ UNTAC មានវត្តមានស្ទើរគ្រប់ទីកន្លែងនៃប្រទេស ហើយត្រូវបានប្រើប្រាស់ប្រាក់ដុល្លារនៅក្នុងប្រតិបត្តិការរបស់ខ្លួនរាប់ចាប់តាំងពីការបើកប្រាក់ខែ ការជួលកន្លែងស្នាក់នៅ រហូតដល់ការចំណាយលើម្ហូបអាហារប្រចាំថ្ងៃ។ វត្តមាននៃអាជ្ញាធរបណ្ដោះអាសន្នរបស់អង្គការសហប្រជាជាតិព្រមទាំងប្រតិបត្តិការរបស់អាជ្ញាធរនេះនៅកម្ពុជា ក្នុងរយៈពេលពីខែធ្នូឆ្នាំ១៩៩២ ដល់ខែកញ្ញាឆ្នាំ១៩៩៣ បានចំណាយប្រាក់អស់ប្រមាណ ជា២ពាន់លានដុល្លារអាមេរិក។ នាខណៈនោះ វិស័យធនាគារនៅកម្ពុជាទើបនឹងចាប់កំណើតប៉ុណ្ណោះ។ ប្រព័ន្ធធនាគារមានទំហំតូចជាខ្លាំង ក្រៅពីធនាគារជាតិនៃប្រជាជនកម្ពុជា ដែលជាធនាគារកណ្ដាល គឺមានធនាគារពាណិជ្ជចំនួនពីរប៉ុណ្ណោះ (ធនាគារពាណិជ្ជកម្មក្រៅប្រទេសនៃកម្ពុជា និងធនាគារកម្ពុជាពាណិជ្ជចំកាត់) ដែលមានសកម្មភាពបម្រើសេវាធនាគារ ហើយនៅពេលនោះលទ្ធភាព និងមធ្យោបាយដើម្បីចេញផ្សាយរូបិយវត្ថុជាតិក្នុងបរិមាណច្រើនក៏នៅមានកម្រិត។ អាស្រ័យហេតុនេះ ប្រាក់ដុល្លារដែលហូរចូលមកយ៉ាងគំហុកនាពេលនោះ បានចរាចរទន្ទឹមគ្នានឹងរូបិយវត្ថុជាតិដែលទើបនឹងមានកំណើតថ្មីៗ ហើយបន្ទាប់មក គ្រឹះស្ថានធនាគារពាណិជ្ជក៏អាចមានប្រតិបត្តិការរបស់ខ្លួនជារូបិយប័ណ្ណបរទេស។

ក្រោយពីពេលនោះមកប្រជាជនកម្ពុជា និងវិនិយោគិនក្នុងស្រុក និងបរទេសបានចាប់ផ្ដើមផ្លាស់ប្ដូរពីការប្រើប្រាស់លោហធាតុមានតម្លៃ ទៅជាការប្រើប្រាស់ក្រដាសប្រាក់ដុល្លារដែលជាកត្តាវាស់តម្លៃ រួមទាំងក្នុងប្រតិបត្តិការទូទាត់ វិនិយោគ និងសន្សំ។ សកម្មភាពនៃការប្រើប្រាស់នេះកាន់តែមានទំហំច្រើនឡើងៗ ដោយសារតែប្រាក់ដុល្លារអាមេរិកត្រូវបានចាត់ទុកថាជារូបិយ-ប័ណ្ណខ្លាំង និងទទួលស្គាល់ជាមធ្យោបាយទូទាត់អន្តរជាតិ គ្មានហានិភ័យប្ដូរប្រាក់ គួបផ្សំនឹងកត្តាក្នុងស្រុកមួយចំនួនទៀត ជាពិសេសគឺអស្ថិរភាពនយោបាយនៅក្នុងប្រទេសនាពេលនោះ រួមជាមួយនឹងកម្រិតខ្ពស់នៃអតិផរណា ហើយជំនឿទុកចិត្តរបស់សាធារណជនមកលើប្រាក់រៀលនៅមានកម្រិតទាប។ ដូច្នេះ ដុល្លាររូបនីយកម្មនៅកម្ពុជាគឺជាកត្តាប្រវត្តិសាស្ត្រ និងមិនមែនជាជម្រើសនយោបាយដោយផ្ទាល់របស់រាជរដ្ឋាភិបាលកម្ពុជាឡើយ។ ផ្ទុយទៅវិញ ដុល្លាររូបនីយកម្មនឹងចោទជាបញ្ហា នៅពេលដែលប្រទេសកម្ពុជាកាន់តែពង្រឹងសមាហរណកម្មសេដ្ឋកិច្ចទៅក្នុងក្របខ័ណ្ឌសេដ្ឋកិច្ចក្នុងតំបន់។

## ៣.២. គុណសម្បត្តិ និងគុណវិបត្តិនៃដុល្លារូបនីយកម្ម

ដុល្លារូបនីយកម្មពិតជាបានផ្តល់ទាំងផលវិជ្ជមាន និងអវិជ្ជមានដល់ស្ថានភាពសេដ្ឋកិច្ចរបស់ប្រទេស ហើយមានការពិភាក្សាជាច្រើនបានជជែកវែកញែកអំពីផលប្រយោជន៍ និងផលវិបាកពាក់ព័ន្ធនឹងវត្តមាននៃដុល្លារូបនីយកម្មនៅក្នុងសេដ្ឋកិច្ចផងដែរ។ ខាងក្រោមនេះគឺជាការពិចារណាលើគុណសម្បត្តិ និងគុណវិបត្តិមួយចំនួននៃដុល្លារូបនីយកម្មនៅកម្ពុជា។

### ក. គុណសម្បត្តិ

- ដុល្លារូបនីយកម្មអាចជួយទប់ស្កាត់នូវលំហូរចេញនៃដើមទុន និងជំរុញការលើកទឹកចិត្តដល់សាធារណជនក្នុងការសន្សំប្រាក់នៅក្នុងប្រទេស ដោយសារតែពួកគេនឹងមិនប្រឈមជាមួយនឹងហានិភ័យនៃអត្រាប្តូរប្រាក់។
- ដុល្លារូបនីយកម្មបានជំរុញឱ្យប្រជាជនងាកពីការនិយមប្រើប្រាស់មាស ទៅប្រើប្រាស់ប្រាក់ដុល្លារអាមេរិកក្នុងការទូទាត់ ឬមធ្យោបាយរក្សាទ្រព្យសម្បត្តិនៅដើមទស្សវត្សន៍ទី៩០។ ការប្រើប្រាស់ប្រាក់ដុល្លារអាមេរិកបានធ្វើឱ្យមានភាពប្រសើរឡើងនៃសេដ្ឋកិច្ចទីផ្សារ ដែលពឹងផ្អែកលើទីផ្សារូបិយវត្ថុ។
- ដុល្លារូបនីយកម្ម អាចសម្រួលដល់សមាហរណកម្មពាណិជ្ជកម្ពុជាទៅក្នុងសេដ្ឋកិច្ចពិភពលោក ដោយមិនបានធ្វើឱ្យវិនិយោគិនបរទេសមានការព្រួយបារម្ភពីហានិភ័យផ្សេងៗ ជាពិសេសអត្រាប្តូរប្រាក់ដែលនឹងជួយកាត់បន្ថយចំណាយពីការប្តូររូបិយប័ណ្ណ ។ វាផ្តល់ភាពងាយស្រួលដល់វិនិ-យោគិនបរទេស ដោយសារពួកគេត្រូវធ្វើការនាំចូលនូវ សម្ភារៈ គ្រឿងម៉ាស៊ីន ព្រមទាំងបរិក្ខារផ្សេងៗពីបរទេសមកគាំទ្រប្រតិបត្តិការវិនិយោគរបស់ខ្លួន។ ដូច្នេះវិនិយោគិនអាចទទួលបានផលចំណេញកាន់តែច្រើន ពីព្រោះពួកគេអាចធ្វើការទូទាត់រាល់ទំនិញទាំងនោះជាប្រាក់ដុល្លារបាន ដោយមិនមានការបារម្ភពីការប្រែប្រួលនៃអត្រាប្តូរប្រាក់ប្រចាំថ្ងៃនោះឡើយ។
- ដុល្លារូបនីយកម្ម អាចជាកត្តាជួយការពារប្រទេសកម្ពុជាពីការរីករាលដាលនៃវិបត្តិរូបិយវត្ថុនៅអាស៊ីនាឆ្នាំ១៩៩៧ ហើយបានជួយរក្សាជំនឿទុកចិត្តអ្នកវិនិយោគក្នុងប្រតិបត្តិការរបស់ពួកគេនៅប្រទេសកម្ពុជា ខណៈដែលប្រទេសអាស៊ីជាច្រើនបានទទួលរងផលប៉ះពាល់ពីវិបត្តិនេះ ។ នេះក៏ព្រោះតែការប្រើប្រាស់ប្រាក់រៀលនៅមានកម្រិតទាប អាជ្ញាធររូបិយវត្ថុអាចគ្រប់គ្រងលើចរាចររូបិយវត្ថុជាតិ និងអត្រាប្តូរប្រាក់បានប្រសើរ ហើយអ្នកកេងចំណេញលើទីផ្សារប្តូរប្រាក់ក៏មិនអាចទាញចំណេញច្រើនពីការធ្វើឱ្យប្រែប្រួលលើអត្រាប្តូរប្រាក់បានដែរ។

- ដុល្លារូបនីយកម្មបានរួមចំណែករក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច តាមរយៈការរក្សាស្ថិរភាពថ្លៃនៃការពង្រឹងការគោរពវិន័យសារពើពន្ធ (Fiscal discipline) ជាពិសេស ក្នុងដំណាក់កាលដែលសេដ្ឋកិច្ចកម្ពុជាបានជួបប្រទះនឹងអស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច។ ប្រាក់ដុល្លារ (Hard currency) ត្រូវបានចាត់ទុកជារូបិយប័ណ្ណដែលមានស្ថិរភាពថ្លៃបើធៀបនឹងរូបិយប័ណ្ណនានា ដូច្នេះការប្រើប្រាស់ដុល្លារក៏បានកាត់បន្ថយឥទ្ធិពលអត្រាប្តូរប្រាក់លើអត្រាអតិផរណាផងដែរ (Pass-through effect of exchange rate on in inflation)។

**ខ. គុណវិបត្តិ**

- គុណវិបត្តិដ៏ធំបំផុតនៃដុល្លារូបនីយកម្ម គឺបានធ្វើឱ្យកម្ពុជាបាត់បង់អាវុធដ៏សំខាន់មួយនៅក្នុងគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច នោះគឺគោលនយោបាយរូបិយវត្ថុ។ ការប្រើប្រាស់ប្រាក់ដុល្លារអាមេរិកយ៉ាងទូលំទូលាយដូចជាពេលបច្ចុប្បន្ននេះ បានតម្រូវឱ្យការងារមួយផ្នែកធំនៃគោលនយោបាយរូបិយវត្ថុរបស់កម្ពុជា ត្រូវបានផ្ទេរទៅឱ្យធនាគារកណ្តាលរបស់សហរដ្ឋអាមេរិកជាអ្នកចាត់ចែង និងត្រួតពិនិត្យជំនួសធនាគារជាតិនៃកម្ពុជាវិញ។
- ដុល្លារូបនីយកម្ម បានរារាំងដល់ការអនុវត្តប្រកបដោយប្រសិទ្ធភាពនៃគោលនយោបាយរូបិយវត្ថុរបស់ធនាគារជាតិនៃកម្ពុជា។ ធនាគារជាតិនៃកម្ពុជាពុំអាចមានឧបករណ៍គោលនយោបាយរូបិយវត្ថុគ្រប់គ្រាន់ និងសមស្របសម្រាប់សម្រួលបរិមាណរូបិយវត្ថុក្នុងសេដ្ឋកិច្ច និងគ្រប់គ្រងបរិមាណឥណទាននោះទេ ដោយសារភាគច្រើននៃរូបិយវត្ថុក្នុងចរាចរគឺជារូបិយប័ណ្ណបរទេស។
- វត្តមាននៃដុល្លារូបនីយកម្មអាចបណ្តាលឱ្យមានការបាត់បង់និមិត្តរូបនៃអធិបតេយ្យភាពប្រទេស ព្រោះរូបិយវត្ថុជាតិនៃប្រទេសនីមួយៗ គឺជានិមិត្តសញ្ញានៃអធិបតេយ្យភាពរបស់ប្រទេសនោះ ។ រូបិយវត្ថុដើរតួនាទីជាអត្តសញ្ញាណតំណាងឱ្យប្រជាជន និងប្រទេសជាតិមួយ ដូចនេះការប្រើប្រាស់រូបិយវត្ថុជាតិតែមួយ គឺជាមោទនភាពជាតិ និងជាការលើកកម្ពស់ស្មារតីជាតិនិយម ភាពជឿជាក់លើរដ្ឋាភិបាល និងសាមគ្គីភាពក្នុងចំណោមប្រជាជនក្នុងសង្គមមួយ។ តាមរយៈរូបភាពលើរូបិយវត្ថុជាតិ ប្រជាជននឹងមើលឃើញជារៀងរាល់ពេលពីទិដ្ឋភាពទាំងផ្នែកប្រវត្តិសាស្ត្រ និងសេដ្ឋកិច្ច ដូចជាវីរៈបុរសជាតិរបស់ខ្លួន ហេតុការណ៍សំខាន់ៗដែលបានកើតឡើងនៅក្នុងប្រទេស ក៏ដូចជាភាពរីកចម្រើននៃសង្គមជាតិ ហើយរូបភាពទាំងនេះនឹងរំលឹកជារៀងរាល់ពេលថាប្រជាជនដែលកាន់រូបិយវត្ថុនោះស្ថិតនៅក្នុងសង្គមតែមួយ មានភាពទាក់ទងគ្នាយ៉ាងជិតស្និទ្ធ និងមានជោគវាសនាតែមួយ។ បន្ថែមពីនេះ វត្តមានរូបិយវត្ថុជាតិបានបង្ហាញពីអធិបតេយ្យភាពនៃប្រទេសមួយ ទាំងផ្នែកសេដ្ឋកិច្ច ហិរញ្ញវត្ថុ សង្គម និងនយោបាយ។

- ដុល្លារូបនីយកម្មបានធ្វើឱ្យប្រទេសដែលប្រើប្រាស់ប្រាក់ដុល្លារនៅក្នុងសេដ្ឋកិច្ចបាត់បង់ចំណូលពីការបោះពុម្ពក្រដាសប្រាក់ ( Seigniorage )។ ចំណូល Seigniorage គឺជាភាពខុសគ្នារវាងតម្លៃនៃរូបិយវត្ថុ និងចំណាយនៅក្នុងការបោះពុម្ព។ នៅពេលដែលរូបិយវត្ថុជាតិត្រូវបានប្រើប្រាស់កាន់តែច្រើននោះ រដ្ឋាភិបាលនឹងទទួលបានប្រាក់ចំណូល Seigniorage កាន់តែច្រើនដែរ ដែលនឹងអាចអនុញ្ញាតឱ្យរដ្ឋាភិបាលគរពូនទ្រព្យសម្បត្តិជាតិ ដើម្បីយកទៅប្រើប្រាស់សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។
- ដុល្លារូបនីយកម្ម បានធ្វើឱ្យប្រព័ន្ធធនាគារនៅកម្ពុជាប្រឈមទៅនឹងហានិភ័យតារាងតុល្យការ។ ដោយសារតែដុល្លារូបនីយកម្មមានលក្ខណៈមិនទាំងស្រុង គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុនៅកម្ពុជានឹងទទួលនូវភាពងាយរងគ្រោះ ដែលបណ្តាលមកពីការកាន់កាប់ទ្រព្យសកម្ម និងអកម្មជារូបិយវត្ថុខុសគ្នា។ ការប្រើប្រាស់រូបិយវត្ថុតែមួយនៅក្នុងប្រព័ន្ធហិរញ្ញវត្ថុនឹងជួយកាត់បន្ថយរាល់បញ្ហាទាំងនេះ និងពង្រឹងភាពធន់នឹងវិបត្តិរបស់ប្រព័ន្ធហិរញ្ញវត្ថុ។
- លើសពីនេះ ដុល្លារូបនីយកម្មក៏បានបណ្តាលឱ្យវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុប្រឈមទៅនឹងហានិភ័យចម្បងនានា ជាពិសេសហានិភ័យសន្ទនីយភាព និងហានិភ័យប្តូរប្រាក់ដែលអាចនាំទៅដល់អស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។
- ដុល្លារូបនីយកម្ម បណ្តាលឱ្យមានការប្រើប្រាស់រូបិយប័ណ្ណច្រើនប្រភេទនៅក្នុងសេដ្ឋកិច្ចកម្ពុជាដែលជាហេតុធ្វើឱ្យមានការខាតបង់នៅក្នុងប្រព័ន្ធដោះដូរ។ ការប្រើប្រាស់រូបិយវត្ថុតែមួយនឹងរួមចំណែកកាត់បន្ថយចំណាយប្រតិបត្តិការ (Transaction Costs) ជាពិសេសការខាតបង់ពីការប្តូរប្រាក់នៅក្នុងវិស័យសេដ្ឋកិច្ច និងវិស័យហិរញ្ញវត្ថុ។
- ដោយសារប្រាក់ដុល្លារអាមេរិកមានគុណភាពជារូបិយវត្ថុបម្រុង ហើយត្រូវបានសាធារណជនពេញចិត្តជាងប្រាក់រៀល វាបានផ្តល់ផលអវិជ្ជមានដល់ការខិតខំប្រឹងប្រែងរបស់ធនាគារជាតិនៃកម្ពុជាដើម្បីបង្កើនជំនឿទុកចិត្តរបស់សាធារណជនមកលើប្រាក់រៀល។
- ដុល្លារូបនីយកម្ម បានធ្វើឱ្យធនាគារកណ្តាលបាត់បង់ ឬដើរតួនាទីបានតិចតួចជាអ្នកឱ្យខ្ចីចុងក្រោយ (Lender of Last Resort) ហើយប្រឈមនឹងហានិភ័យសន្ទនីយភាព។ ការប្រើប្រាស់រូបិយវត្ថុជាតិកាន់តែទូលំទូលាយ នឹងអនុញ្ញាតឱ្យធនាគារជាតិនៃកម្ពុជាដើរតួនាទីជាឱ្យខ្ចីចុងក្រោយ និងកំណត់អត្រាការប្រាក់ជារៀលកាន់តែមានប្រសិទ្ធភាព។ ការពង្រឹងតួនាទីនេះនឹងបង្កើនជំនឿទុកចិត្តរបស់ភ្នាក់ងារសេដ្ឋកិច្ចមកលើវិស័យហិរញ្ញវត្ថុជាតិ និងបង្កើនការលើកកម្ពស់សមត្ថភាពបង្ការវិបត្តិផ្សេងៗរបស់ធនាគារកណ្តាល។

## ៣.៣. ស្ថានភាពដុល្លារូបនីយកម្មនៅកម្ពុជា

វត្តមាននៃដុល្លារូបនីយកម្មនៅក្នុងសេដ្ឋកិច្ចកម្ពុជា គឺចាប់ផ្តើមតាំងពីដើមទសវត្សរ៍ឆ្នាំ ១៩៩០មកម្ល៉េះ។ បញ្ហាដុល្លារូបនីយកម្មនេះ មិនបានកើតឡើងដោយសារជម្រើសគោលនយោបាយរបស់រដ្ឋាភិបាលនោះទេ ប៉ុន្តែដោយសារយ៉ាងហោចណាស់កត្តាចម្បងពីរគឺៈ ១),ការបាត់បង់ទំនុកចិត្តទៅលើរូបិយវត្ថុជាតិ និង ២),លំហូរចូលនៃរូបិយប័ណ្ណក្នុងសេដ្ឋកិច្ចជាបន្តបន្ទាប់។

វិបត្តិសង្គ្រាមស៊ីវិលដែលបានអូសបន្លាយអស់រយៈពេលប្រមាណជា៣០ឆ្នាំ (ដើមទសវត្សរ៍ឆ្នាំ១៩៧០ ចុងទសវត្សរ៍ឆ្នាំ១៩៩០) បានធ្វើឱ្យមានផលប៉ះពាល់យ៉ាងខ្លាំងទៅលើជំនឿទុកចិត្តរបស់ភ្នាក់ងារសេដ្ឋកិច្ចមកលើការរក្សាទុក និងប្រើប្រាស់រូបិយវត្ថុជាតិ ជាពិសេសសម័យ ប៉ុល ពត ដែលបានលុបបំបាត់ការប្រើប្រាស់រូបិយវត្ថុ ទីផ្សារ និងរាល់សកម្មភាពសេដ្ឋកិច្ចទាំងអស់។ បទពិសោធន៍នៃការលុបបំបាត់រូបិយវត្ថុជាតិ និងការប្រើប្រាស់វត្ថុមានតម្លៃផ្សេងៗ (ដូចជា មាស ប្រាក់ អង្ករ ជាដើម) ដើម្បីរក្សាទ្រព្យសម្បត្តិ និងការដោះដូរក្នុងរយៈពេលអស្ថិរភាពនយោបាយនាសម័យសង្គ្រាម បានដក់ជាប់នៅក្នុងផ្នត់គំនិតរបស់ប្រជាជនយ៉ាងជ្រៅ ហើយបានដាក់កំហិតលើការប្រើប្រាស់រូបិយវត្ថុជាតិ ទោះបីជាសុខសន្តិភាព ស្ថិរភាពនយោបាយ ស្ថិរភាពសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវរក្សាបានអស់រយៈពេលប្រមាណ ២ ទសវត្សរ៍ចុងក្រោយនេះក៏ដោយ។

លំហូរចូលនៃរូបិយប័ណ្ណ (ប្រាក់ដុល្លារ) ជាបន្តបន្ទាប់មកក្នុងសេដ្ឋកិច្ចកម្ពុជាបានធ្វើឱ្យកម្រិតនៃដុល្លារូបនីយកម្មកើនឡើងជាលំដាប់គឺប្រមាណ ៦០% នៅក្នុងទសវត្សរ៍ឆ្នាំ១៩៩០ មក ៨០%ក្នុងទសវត្សរ៍ឆ្នាំ២០០០ និងបានរក្សាក្នុងរង្វង់កម្រិតនេះរហូតដល់បច្ចុប្បន្ន។ បរិមាណនៃប្រាក់ដុល្លារបានហូរចូលមកកម្ពុជាយ៉ាងច្រើនសន្ធឹកសន្ធាប់នៅក្នុងកំឡុងឆ្នាំ ១៩៩១ ដល់ ១៩៩២ (ប្រមាណ១,៧ពាន់លានដុល្លារស្មើនឹងប្រមាណ ២/៣ នៃផ.ស.ស. ឆ្នាំ១៩៩៣) សម្រាប់ប្រើប្រាស់ក្នុងប្រតិបត្តិការរក្សាសន្តិសុខ និងរៀបចំការបោះឆ្នោតនៅកម្ពុជាដោយអាជ្ញាធរបណ្តោះអាសន្នរបស់អង្គការសហប្រជាជាតិនៅកម្ពុជា (UNTAC)។ តាមរយៈភាពរីកចម្រើននៃសេដ្ឋកិច្ច កំណើនជំនឿទុកចិត្តមកលើសេដ្ឋកិច្ចកម្ពុជា និងគោលនយោបាយបើកចំហសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លំហូររូបិយប័ណ្ណតាមវិស័យចម្បងៗនៃសេដ្ឋកិច្ច បានគាំទ្រដល់ដុល្លារូបនីយកម្មនៅកម្ពុជា។

ចាប់តាំងពីមានវត្តមាននៅក្នុងសេដ្ឋកិច្ចកម្ពុជាមក ប្រាក់ដុល្លារត្រូវបានទទួលស្គាល់កាន់តែទូលំទូលាយ ហើយបានដើរតួនាទីយ៉ាងសំខាន់ទាំងបីរបស់រូបិយវត្ថុគឺជា ឯកតាតម្លៃ មធ្យោបាយដោះដូរ និងរក្សាតម្លៃ។ ជាក់ស្តែង នៅតាមមជ្ឈមណ្ឌលពាណិជ្ជកម្ម ទីផ្សារនិងហាងទំនើប និងទីផ្សារទំនិញនិងសេវាកម្មមួយចំនួន ប្រាក់ដុល្លារអាមេរិកត្រូវបានប្រើប្រាស់សម្រាប់កំណត់ថ្លៃ និង

ទូទាត់ ហើយការប្រើប្រាស់ប្រាក់រៀលនៅលើទីផ្សារទាំងនោះបែរជាទទួលរងការខាត ដោយសារទីផ្សារទាំងនេះបានកំណត់អត្រាប្តូរប្រាក់ដោយខ្លួនឯងខ្ពស់ជាងអត្រាទីផ្សារ។ នៅក្នុងទីផ្សារកាងារក៏បានប្រើប្រាស់ប្រាក់ដុល្លារច្រើនផងដែរ ជាពិសេសក្នុងវិស័យឧស្សាហកម្ម និងទេសចរណ៍។ ជាក់ស្តែង លទ្ធផលអង្កេតរបស់ការិយាល័យស្រាវជ្រាវម៉ាក្រូសេដ្ឋកិច្ចអាស៊ាន+៣ (AMRO) ក៏បានបង្ហាញថាប្រមាណ៧០% នៃក្រុមហ៊ុន សហគ្រាសនៅកម្ពុជា ផ្តល់ប្រាក់បៀវត្សជាប្រាក់ដុល្លារ។ នៅក្នុងវិស័យហិរញ្ញវត្ថុ ប្រាក់បញ្ញើវិស័យធនាគារនិងហិរញ្ញវត្ថុប្រមាណ៨៥% គឺជាប្រាក់ដុល្លារ ហើយឥណទានជាប្រាក់ដុល្លារមានសមាមាត្ររហូតដល់៨១% នៃឥណទានសរុប។ លើសពីនេះ ដុល្លារូបនីយកម្មមិនត្រឹមតែគ្រប់ដណ្តប់ក្នុងវិស័យរូបវន្ត និងហិរញ្ញវត្ថុតែប៉ុណ្ណោះទេ ប៉ុន្តែបានចាក់ឫសគល់យ៉ាងជ្រៅទៅក្នុងផ្នត់គំនិតរបស់ប្រជាជន។ ការប្រើប្រាស់ប្រាក់ដុល្លារបានផ្សារភ្ជាប់នឹងជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាជន ដោយសារភាពងាយស្រួលក្នុងការប្រើប្រាស់ ការកំណត់ថ្លៃ និងការសន្សំជាប្រាក់ដុល្លារធៀបនឹងរូបិយវត្ថុជាតិ។

ក្រាហ្វទី៣.១៖ សមាសធាតុនិងកំណើនរូបិយវត្ថុទូទៅ (គិតជាទ្រីលានរៀល ២០០៨-២០១៨)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

ដុល្លារូបនីយកម្មនៅកម្ពុជាមានលក្ខណៈពហុរូបិយវត្ថុ (Monetary plurality) ដោយសារក្រៅពីប្រាក់ដុល្លារអាមេរិក និងប្រាក់រៀល រូបិយប័ណ្ណរបស់ប្រទេសជិតខាង (ប្រាក់បាតថៃនិងប្រាក់ដុងវៀតណាម) ក៏មានចរាចរណ៍ផងដែរ នៅតាមតំបន់ជាប់ព្រំប្រទល់ប្រទេសថៃនិងវៀតណាម និង

ក្នុងចំណោមពាណិជ្ជករមួយចំនួនដែលមានការទូទាត់ដោយផ្ទាល់ ឬប្រយោលទៅលើទំនិញនាំចូលពីប្រទេសទាំងនោះ។ ទោះជាយ៉ាងណាក៏ដោយ ការប្រើប្រាស់ប្រាក់បាតថៃ និងដុងវៀតណាមនៅមានកម្រិតទាបទាំងបរិមាណ និងវិសាលភាពធៀបនឹងប្រាក់រៀលនិងដុល្លារ។

បន្ថែមពីនេះ ស្ថានភាពដុល្លាវូបនីយកម្មនៅកម្ពុជាត្រូវបានចាត់ទុកជាប្រភេទដុល្លាវូបនីយ-កម្មមិនទាំងស្រុង ដោយសាររូបិយវត្ថុជាតិនៅតែមានវត្តមានក្នុងចរាចរណ៍។ គួរកត់សម្គាល់ផងដែរថា ស្របពេលដែលកម្រិតដុល្លាវូបនីយកម្មបានកើនឡើង និងស្ថិតនៅក្នុងអត្រាខ្ពស់ក្នុងរយៈពេល ២ទសវត្សរ៍ចុងក្រោយនេះ កំណើនរូបិយវត្ថុជាតិក្នុងចរាចរណ៍ និងប្រាក់បញ្ញើជារូបិយវត្ថុជាតិក៏បានកើនឡើង គឺក្នុងអត្រាមធ្យមប្រមាណ១៧% និង២៥% ក្នុងមួយឆ្នាំ។ កំណើននេះបញ្ជាក់ថា ដុល្លាវូបនីយកម្មនៅកម្ពុជាមិនមែនបណ្តាលមកពីបាតុភូតជំនួសរូបិយវត្ថុ (Currency substitution) ឬជំនួសទ្រព្យសកម្មនោះទេ (Asset substitution) ដែលជាមូលហេតុនាំឱ្យមានដុល្លាវូបនីយកម្មនៅប្រទេសដទៃ។ ហេតុដូចនេះ ប្រាក់ដុល្លារមិនបានជំនួសទាំងស្រុងលើតួនាទីរបស់រូបិយវត្ថុជាតិទេ។ ឆ្លងកាត់តាមការសិក្សា និងអង្កេតនានាកន្លងមកបានបង្ហាញថា ប្រាក់រៀលត្រូវបានប្រើប្រាស់ និងពេញនិយមខ្លាំងនៅក្នុងវិស័យកសិកម្ម ការទូទាត់តូចៗ ការប្រើប្រាស់នៅក្នុងជីវភាពប្រចាំថ្ងៃ ដូចជា ចំណាយលើម្ហូបអាហារជាដើម។ សរុបជារួម នៅតាមទីជនបទ ប្រាក់រៀលមានតួនាទីសំខាន់ណាស់សម្រាប់សកម្មភាពសេដ្ឋកិច្ចរបស់ប្រជាជន ចំណែកឯប្រាក់ដុល្លារត្រូវបានប្រើប្រាស់ច្រើននៅក្នុងតំបន់សេដ្ឋកិច្ចសំខាន់ៗ និងលើការទូទាត់ទំនិញ និងសេវាកម្មណាដែលមានតម្លៃធំៗ។ សកម្មភាពនៃការបន្តការប្រើប្រាស់ និងសារសំខាន់មិនអាចជំនួសបានរបស់ប្រាក់រៀល គឺជាកត្តាដ៏ចម្បង និងជាកាលានុវត្តភាពមួយក្នុងការគាំទ្រការលើកកម្ពស់ប្រាក់រៀលនៅកម្ពុជា។

អត្រាប្តូរប្រាក់រៀលធៀបនឹងដុល្លារអាមេរិកបន្តមានស្ថិរភាពក្នុងរង្វង់ប្រមាណ៤០៥០ រៀលក្នុង១ដុល្លារអាមេរិក។ ស្ថិរភាពនេះសម្រេចបានដោយសារការធ្វើអន្តរាគមន៍លើទីផ្សារប្តូរប្រាក់នៅក្នុងបរិការណ៍ដែលរូបិយប័ណ្ណនៅក្នុងប្រទេសមួយចំនួន កំពុងទទួលរងសម្ពាធពីការដំឡើងអត្រាការប្រាក់គោលរបស់ធនាគារកណ្តាលសហរដ្ឋអាមេរិក។ អត្រាប្តូរប្រាក់រៀលធៀបនឹងដុល្លារអាមេ-រិកគិតជាមធ្យមប្រចាំឆ្នាំមានកម្រិតប្រហាក់ប្រហែលនឹងឆ្នាំមុនៗដែរ ដោយសារការផ្គត់ផ្គង់ប្រាក់រៀលរបស់ធនាគារជាតិនៃកម្ពុជាមានកម្រិតស្របនឹងការកើនឡើងតម្រូវការប្រាក់រៀល ជាពិសេសសម្រាប់ការទិញកសិផលនិងការបង់ពន្ធ។ ស្ថិរភាពអត្រាប្តូរប្រាក់នេះបានរួមចំណែកធ្វើឱ្យទំនិញ និងសេវាស្ថិតនៅក្នុងកម្រិតទាបសមស្រប។

ក្រាហ្វទី៣.២ ៖ អត្រាប្តូរប្រាក់រៀលធៀបនឹងដុល្លារអាមេរិក (ឆ្នាំ២០១៦-២០១៨)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

ចំណុចដែលគួរឱ្យកត់សម្គាល់នោះគឺ បើទោះបីជាស្ថិតនៅក្នុងបរិការណ៍ដុល្លារូបនីយកម្មកម្រិតខ្ពស់ក៏ដោយ កម្ពុជាទទួលបានកំណើនសេដ្ឋកិច្ចក្នុងអត្រាខ្ពស់ប្រមាណ៧,៧% ក្នុងរយៈពេល២ទសវត្សរ៍ចុងក្រោយនេះដែលធ្វើឱ្យកម្ពុជាជាប់ចំណាត់ថ្នាក់ទី៦ ក្នុងចំណោមបណ្តាប្រទេសដែលមានកំណើនសេដ្ឋកិច្ចខ្ពស់ជាងគេនៅលើពិភពលោក។ ស្ថានភាពនេះបានបង្ហាញថា ដុល្លារូបនីយកម្មមិនបានរំខានដល់ការអភិវឌ្ឍសេដ្ឋកិច្ចនោះទេ ប៉ុន្តែបានជួយរួមចំណែកមួយផ្នែកក្នុងដំណើរការអភិវឌ្ឍនេះទៀតផង។ ចំពោះការរួមចំណែកនេះអាចពិនិត្យឃើញតាមរយៈការរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ការបង្កើសមាហរណកម្មសេដ្ឋកិច្ចកម្ពុជាទៅក្នុងសេដ្ឋកិច្ចសកលនៅក្នុងពេលដែលកម្រិតសមាហរណកម្មកម្ពុជានៅមានកម្រិតដ៏ទាបនៅឡើយ ការជួយអភិវឌ្ឍវិស័យហិរញ្ញវត្ថុក្នុងពេលដែលប្រជាជនកម្ពុជាបានបាត់បង់ទំនុកចិត្តមកលើប្រព័ន្ធហិរញ្ញវត្ថុ និងរូបិយវត្ថុនាដំណាក់កាលដំបូង និងការទាក់ទាញការវិនិយោគនិងមូលធនចូលមកសេដ្ឋកិច្ចជាតិ។ល។ ក្រឡេកមើលពីភាពស៊ីជម្រៅផ្នែកហិរញ្ញវត្ថុ (M2/GDP) បានកើនឡើងពី២៨% នៅឆ្នាំ២០០៨ ដល់៧៨,៥% នៅឆ្នាំ២០១៨ ហើយបរិយាប័ន្នហិរញ្ញវត្ថុត្រូវបានលើកកម្ពស់ជាលំដាប់ ដែលនាំឱ្យប្រជាជនកាន់តែច្រើនទទួលបានការប្រើប្រាស់សេវាកម្មហិរញ្ញវត្ថុផ្លូវការ។ គួរកត់សម្គាល់ថា អនុបាតនៃប្រាក់បញ្ញើជារូបិយប័ណ្ណធៀបនឹងរូបិយវត្ថុទូទៅ (FCD/M2) និងធៀបប្រាក់បញ្ញើសរុបដែលឆ្លុះបញ្ចាំងពីស្ថានភាពដុល្លារូបនីយកម្មនៅបន្តមានកម្រិតខ្ពស់ក្នុងអត្រា៨៤% និង៩៥% រៀងគ្នាក្នុងរយៈពេល១០ឆ្នាំចុងក្រោយនេះ។

ក្រាហ្វទី៣.៣ ៖ ភាពស៊ីជម្រៅផ្នែកហិរញ្ញវត្ថុ និងដុល្លារូបនីយកម្ម (២០០៨-២០១៨)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

នៅក្នុងរយៈពេល១០ឆ្នាំចុងក្រោយនេះ ដោយមានការដាក់ចេញនូវវិធានការលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលជាបន្តបន្ទាប់ រូបិយវត្ថុក្នុងចរាចរណ៍បានកើនឡើងជាមធ្យម១៦,៣% និងប្រាក់បញ្ញើជារៀលកើនឡើងជាមធ្យម៣១,២% ក្នុងមួយឆ្នាំៗ។

ក្រាហ្វទី៣.៤៖ ប្រាក់បញ្ញើជារៀលនិងរូបិយវត្ថុក្នុងចរាចរណ៍(គិតជាទ្រីលានរៀល,ឆ្នាំ២០០៨-២០១៨)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

បើទោះជាយ៉ាងនេះក្តី ដុល្លាវូបនីយកម្មក៏បានដាក់កំហិតលើប្រសិទ្ធភាពគោលនយោបាយរូបិយវត្ថុធ្វើឱ្យកម្ពុជាខាតបង់ប្រាក់ចំណូលពីការបោះពុម្ពរូបិយវត្ថុ បាត់បង់តួនាទីជាអ្នកឱ្យខ្ចីចុងក្រោយ និងគោលនយោបាយប្តូរប្រាក់ដែលជាតួនាទីសំខាន់ក្នុងការបង្ការវិបត្តិ។ ជាក់ស្តែង នាបច្ចុប្បន្ននេះ ធនាគារជាតិនៃកម្ពុជាមានឧបករណ៍គោលនយោបាយចម្បងតែពីរប៉ុណ្ណោះ គឺការអន្តរាគមន៍នៅក្នុងទីផ្សារប្តូរប្រាក់ និងការកំណត់អត្រាប្រាក់បម្រុងកាតព្វកិច្ច។ ការធ្វើអន្តរគមន៍លើទីផ្សារប្តូរប្រាក់មិនមានភាពឯករាជ្យទាំងស្រុងនោះទេ ដោយសារធនាគារជាតិនៃកម្ពុជាចាំបាច់ត្រូវរក្សាស្ថិរភាពនៃអត្រាប្តូរប្រាក់រៀលធៀបជាមួយដុល្លារអាមេរិក ហើយការផ្លាស់ប្តូរអត្រាប្រាក់បម្រុងកាតព្វកិច្ចញឹកញាប់ក៏មិនមែនជាការងារងាយស្រួលដែរ។ ធនាគារជាតិនៃកម្ពុជាមិនទាន់អាចកំណត់អត្រាការប្រាក់គោលដែលអាចមានឥទ្ធិពលដល់អត្រាការប្រាក់លើទីផ្សារបានទេ ដែលបញ្ហានេះ មិនអាចឱ្យការអនុវត្តគោលនយោបាយរូបិយវត្ថុមានភាពសកម្មបានទេ។ មួយវិញទៀតយោងទៅតាមការប៉ាន់ស្មានរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) កម្ពុជាបានបាត់បង់ចំណូលសេញ៉រ៉េច (ប្រាក់ចំណេញពីការបោះពុម្ពក្រដាសប្រាក់) ជាមធ្យមក្នុងចន្លោះពី០,៤% ទៅ២,៤% នៃផ.ស.ស ក្នុង១ឆ្នាំ នៅកំឡុងឆ្នាំ១៩៩៤-២០០១ និងបានកើនឡើងដល់ប្រមាណ៥% នៃផ.ស.ស នាឆ្នាំ២០១០។

តារាងទី៣.១៖ ការប៉ាន់ស្មានការខាតបង់ចំណូលពីការបោះពុម្ពក្រដាសប្រាក់រៀល(១៩៩៤-២០០១)

| | 1994 | 1995 | 1996 | 1997 | 1998 | 1999 | 2000 | 2001 |
|---|---|---|---|---|---|---|---|---|
| **Reserve-Money Method** | | | | | | | | |
| Change in reserve money(CR billion) | 57.8 | 28.6 | 135.3 | 95.5 | 257.3 | 127.3 | 231.1 | 198.6 |
| in percent of GDP | 0.9 | 0.4 | 1.6 | 1 | 2.4 | 1.1 | 1.9 | 1.5 |
| in percent of government revenue | 19.9 | 4.8 | 21 | 12.7 | 29.2 | 13.5 | 17.3 | 13 |
| **Central-Bank-Profit Method** | | | | | | | | |
| Interest income (CR billion) | ... | 18.6 | 28.9 | 47.4 | 58.7 | 67.6 | 114.7 | 88.4 |
| in percent of GDP | ... | 0.3 | 0.3 | 0.4 | 0.6 | 0.6 | 0.9 | 0.7 |
| in percent of government revenue | ... | 2.9 | 3.9 | 5.4 | 6.2 | 5.1 | 8 | 5.8 |

ប្រភព៖ IMF working paper: wp0292

ដោយផ្អែកទៅលើអត្ថប្រយោជន៍ ការខាតបង់និងហានិភ័យនៃបញ្ហាដុល្លារូបនីយកម្ម ការធ្វើបដិដុល្លារូបនីយកម្មដោយគំហុក ឬវិធានការរដ្ឋបាលអាចជះឥទ្ធិពលដល់ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំងការអភិវឌ្ឍសេដ្ឋកិច្ចទាំងមូល។ ដូច្នេះ ការលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលដោយសន្សឹមៗ ផ្អែកតាមយន្តការទីផ្សារជាវិធានការដ៏ប្រសើរបំផុត ក្នុងការជម្នះបញ្ហាដុល្លារូបនីយកម្មនៅកម្ពុជា។

នៅក្នុងពេលថ្មីៗនេះដែរ ធនាគារជាតិនៃកម្ពុជាបានសហការជាមួយវិទ្យាស្ថានស្រាវជ្រាវនៃភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន ដើម្បីធ្វើអង្កេតអំពីឥរិយាបថនៃការប្រើប្រាស់ប្រាក់រៀល និងរូបិយប័ណ្ណនៅកម្ពុជា ក្នុងរាជធានីខេត្តទាំង២៥ ក្នុងគោលដៅទទួលបានទិន្នន័យក្នុងកម្រិតមីក្រូបន្ថែមលើទិន្នន័យម៉ាក្រូដែលមានស្រាប់ ចំពោះស្ថានភាពដុល្លារូបនីយកម្មនៅកម្ពុជា និងសម្រាប់ការរៀបចំយុទ្ធសាស្ត្រលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលឱ្យកាន់តែត្រឹមត្រូវ និងបានគ្រប់ជ្រុងជ្រោយ។ ការអង្កេតលើកទី១ត្រូវបានធ្វើឡើងចាប់ពីខែតុលា ឆ្នាំ២០១៤ ដល់ខែមករា ឆ្នាំ២០១៥ ទៅលើអង្គភាពគ្រួសារចំនួន២២៧៣ សហគ្រាស៨៥៦ គ្រឹះស្ថានធនាគារ១០ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំនួន៥។ ក្រោយពីនេះ ក៏មានការអង្កេតលើកទី២ក្នុងកំឡុងឆ្នាំ២០១៧ ដល់ឆ្នាំ២០១៨ ដែលធ្វើការអង្កេតលើអង្គភាពគ្រួសារ និងសហគ្រាសដដែល ប៉ុន្តែបន្ថែមការអង្កេតទៅលើគ្រប់សាខានៃគ្រឹះស្ថានធនាគារទាំង១៥ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទាំង១២។

**ក. លទ្ធផលអង្កេតលើអង្គភាពគ្រួសារ**

រូបិយវត្ថុជាតិ (ប្រាក់រៀល) មានវិសាលភាពចរាចរណ៍ នៅគ្រប់ទីតំបន់នៃព្រះរាជាណាចក្រកម្ពុជា ជាពិសេសនៅតំបន់ជនបទ ខណៈដែលប្រាក់ដុល្លារមានវត្តមានច្រើននៅតំបន់ប្រជុំជន ដូចជាភ្នំពេញ និងសៀមរាប។ នៅក្នុងចំណោមប្រភពចំណូលទាំងអស់របស់អង្គភាពគ្រួសារ ចំណូលដែលទទួលបានពីប្រាក់បៀវត្សភាគច្រើនជាដុល្លារអាមេរិក ដែលមានកម្រិតរូបិយប័ណ្ណបរទេសមធ្យមប្រមាណ៣៨,៣% ខណៈដែលចំណូលពីអាជីវកម្ម និងចំណូលពីកសិកម្មមានកម្រិតត្រឹមតែ ១៦,៩% និង៥% រៀងគ្នា។

ក្រាហ្វទី៣.៥ ៖កម្រិតដុល្លារូបនីយកម្មតាមប្រភពនិងកម្រិតចំណូល(អង្គភាពគ្រួសារ)




ដោយឡែក ការចំណាយរបស់អង្គភាពគ្រួសារមានតែមួយភាគតូចប៉ុណ្ណោះជាប្រាក់ដុល្លារអាមេរិក ជាពិសេសការចំណាយទៅលើសេវាទូរស័ព្ទ និងការជួលកន្លែងស្នាក់នៅ។ បញ្ហានេះទាំងបានធ្វើឱ្យអង្គភាពគ្រួសារ ត្រូវធ្វើការប្តូរប្រាក់ដុល្លារអាមេរិកដើម្បីយកប្រាក់រៀលសម្រាប់ទូទាត់ចំណាយផ្សេងៗជាញឹកញាប់។ អង្គភាពគ្រួសារភាគច្រើន នៅតែធ្វើការសន្សំទុកខ្លួនឯងជាសាច់ប្រាក់ ជាជាងការសន្សំនៅក្នុងស្ថាប័នហិរញ្ញវត្ថុ ជាពិសេសការសន្សំទុកជាប្រាក់រៀល។ កម្ចីរបស់អង្គភាពគ្រួសារមានការកើនឡើង ហើយកម្ចីមួយចំនួនបានធ្វើឡើងជារូបិយប័ណ្ណបរទេសក្រៅពីប្រាក់រៀល។ ក្រឡេកមកមើលប្រជាពលរដ្ឋមួយចំនួនដែលមានការយល់ដឹងពីផ្នែកហិរញ្ញវត្ថុ ពួកគេតែងតែព្យាយាមគេចវេសពីហានិភ័យនៃអត្រាប្តូរប្រាក់តាមរយៈការស្នើសុំកម្ចីជារូបិយវត្ថុ ឬរូបិយប័ណ្ណដែលត្រូវគ្នាទៅនឹងប្រភពចំណូលរបស់ពួកគេ។

ក្រាហ្វទី៣.៦ ៖ សមាសធាតុរូបិយវត្ថុក្នុងចំណូលតាមតំបន់ (អង្គភាពគ្រួសារ)




ក្រាហ្វទី៣.៧ ៖ សមាសធាតុរូបិយវត្ថុក្នុងចំណាយតាមតំបន់ (អង្គភាពគ្រួសារ)



ក្រាហ្វទី៣.៨ ៖ ប្តូរប្រាក់ (អង្គភាពគ្រួសារ)




ក្រាហ្វទី៣.៩ ៖ សមាសធាតុរូបិយវត្ថុក្នុងឥណទានតាមតំបន់




### ខ. លទ្ធផលអង្កេតលើសហគ្រាស

សម្រាប់ការប្រើប្រាស់រូបិយវត្ថុរបស់សហគ្រាស កម្រិតដុល្លារូបនីយកម្មត្រូវបានរកឃើញថា មានការប្រែប្រួលទៅតាមតំបន់ ទំហំនៃសហគ្រាស និងតាមវិស័យនីមួយៗ។ គេសង្កេតឃើញតំបន់ដែលមានសកម្មភាពសេដ្ឋកិច្ចរស់រវើកដូចជា រាជធានីភ្នំពេញ សៀមរាប និងតំបន់ពាយ័ព្យ

មានកម្រិតដុល្លារូបនីយកម្មខ្ពស់ប្រមាណ៦៥% ទាំងចំណូល និងចំណាយ ខណៈដែលនៅតំបន់កណ្តាលមានគម្លាតរវាងសមាមាត្ររូបិយប័ណ្ណខ្ពស់ (ចំណូល៣៥% ស្របពេលដែលចំណាយមានរហូតដល់៥៦%)។

## ការប្រើប្រាស់ការប្តូរប្រាក់តាមតំបន់

ក្រាហ្វទី៣.១០ ៖ សមាសធាតុរូបិយវត្ថុក្នុងចំណូល (សហគ្រាស)




ក្រាហ្វទី៣.១១ ៖ សមាសធាតុរូបិយវត្ថុក្នុងចំណាយ (សហគ្រាស)



សរុបជារួម ចំណាយរបស់សហគ្រាសគ្រប់តំបន់ដែលបានសិក្សាមានសមាមាត្ររូបិយប័ណ្ណខ្ពស់ជាងចំណូល។ សហគ្រាសដែលមានទំហំកាន់តែធំ មានសមាមាត្ររូបិយប័ណ្ណកាន់តែខ្ពស់។ ចំពោះសមាមាត្ររូបិយប័ណ្ណនៃចំណូលរបស់សហគ្រាសធុនធំមានកម្រិត៧០% ខណៈដែលសហគ្រាសធុនតូចបំផុតមានកម្រិតត្រឹមតែ៣៩%។ ចំណែកឯសមាមាត្ររូបិយប័ណ្ណនៃចំណាយរបស់សហគ្រាសធុនធំ និងធុនតូចបំផុតវិញ មានកម្រិត៦៧% និង ៥៥% រៀងគ្នា។ វិស័យលក់ដុំ និងរាយមានគម្លាតរវាងលំហូររូបិយប័ណ្ណខ្ពស់ (ចំណូល ៤៦% ស្របពេលដែលចំណាយមានរហូតដល់៧១%) ដែលតម្រូវឱ្យមានការប្តូរប្រាក់ពីរៀលទៅដុល្លារអាមេរិកសម្រាប់ចំណាយប្រតិបត្តិការ។ បញ្ហាទាំងនេះបានធ្វើឱ្យសហគ្រាសភាគច្រើនបានប្រឈមនឹងហានិភ័យភាពមិនស៊ីគ្នាផ្នែករូបិយវត្ថុ (Currency mismatch) ជាពិសេស សហគ្រាសនៅតំបន់ជនបទ សហគ្រាសធំៗ និងសហគ្រាសដែលស្ថិតនៅក្នុងវិស័យអាជីវកម្មលក់ដុំនិងរាយ។ ការសិក្សាបានបង្ហាញថា កម្រិតដុល្លារូបនីយកម្មនៅក្នុងសហគ្រាសមានកំណើនខ្ពស់ជាងបើធៀបទៅនឹងអង្គភាពគ្រួសារ ក៏ប៉ុន្តែចំណែកនៃរូបិយវត្ថុជាតិនៅក្នុងចំណូល និងចំណាយរបស់សហគ្រាស នៅតែមានការកើនឡើងនៅចន្លោះឆ្នាំ២០១៤ ដល់ឆ្នាំ២០១៧។ ថ្មីៗនេះ មានសហគ្រាសមួយចំនួនបានស្នើសុំកម្ចីជាប្រាក់រៀល ពីធនាគារពាណិជ្ជនានា ខណៈដែលនៅមុនឆ្នាំ២០១៤ គ្មានសហគ្រាសដែលបានស្នើសុំកម្ចីជាប្រាក់រៀលពីធនាគារពាណិជ្ជនោះទេ។

**គ. លទ្ធផលអង្កេតលើសាខាគ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុ**

គ្រឹះស្ថានធនាគារ និងមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ មាននិន្នាការបែងចែកមូលធនដែលលើសទៅតាមសាខាដែលខ្វះខាតមូលធន ប៉ុន្តែចំពោះគ្រឹះស្ថានធនាគារវិញ ការបែងចែកមូលធនជាប្រាក់រៀលទៅតាមសាខាមានកម្រិតតិចតួចនៅឡើយ បើទោះបីជានៅស្នាក់ការកណ្តាលមានមូលធនលើសជារៀលក៏ដោយ។

**ការប្រើប្រាស់ការប្តូរប្រាក់តាមទំហំ**

ក្រាហ្វទី៣.១២ ៖ សមាសធាតុរូបិយវត្ថុក្នុងចំណូល




ក្រាហ្វទី៣.១៣ ៖ សមាសធាតុរូបិយវត្ថុក្នុងចំណាយ




ភាគរយនៃរូបិយប័ណ្ណក្នុងប្រាក់បញ្ញើ និងឥណទានមានកម្រិតទាបនៅតាមជនបទជាងនៅរាជធានីភ្នំពេញ ទោះបីជាភាគរយនៃរូបិយប័ណ្ណនៅក្នុងការផ្តល់ឥណទាននៅតាមជនបទមានការកើនឡើងជាបន្តបន្ទាប់ក៏ដោយ ភាគរយនៃប្រាក់បញ្ញើរូបិយប័ណ្ណនៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួល

ប្រាក់បញ្ញើបានថយចុះទាំងនៅជនបទនិងជាយក្រុង។ គ្រឹះស្ថានធនាគារ និងមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើអាចបង្ការហានិភ័យអត្រាប្តូរប្រាក់ តាមរយៈការយកអត្រាការប្រាក់ឥណទានជារៀលខ្ពស់ពីអ្នកខ្ចី។

## ការប្រើប្រាស់ការប្តូរប្រាក់តាមប្រភេទពាណិជ្ជកម្ម

ក្រាហ្វទី៣.១៤ ៖ សមាសធាតុរូបិយវត្ថុក្នុងចំណូល




ក្រាហ្វទី៣.១៥ ៖ សមាសធាតុរូបិយវត្ថុក្នុងចំណាយ



វិស័យធនាគារ គឺជាកាតាលីករដ៏សំខាន់ ដែលជំរុញឱ្យដុល្លារូបនីយកម្មរីកដុះដាលនៅពាសពេញផ្ទៃប្រទេស តាមរយៈការប្រមូលមូលធនជារូបិយប័ណ្ណនៅក្នុងរាជធានីភ្នំពេញ សម្រាប់ផ្តល់ជាកម្ចីនៅតាមតំបន់នានា ដែលភាគច្រើននៃកម្ចីទាំងនោះធ្វើឡើងជាប្រាក់ដុល្លារអាមេរិក។

បើទោះបីជាប្រាក់បញ្ញើជារៀលនៅក្នុងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ (MDI) មានការកើនឡើងយ៉ាងឆាប់រហ័សយ៉ាងណាក្តី គេសង្កេតឃើញថាចំណែកនៃប្រាក់បញ្ញើជារៀលមិនមានការប្រែប្រួលនោះទេចាប់ពីឆ្នាំ២០១៣ ដល់ឆ្នាំ២០១៧។ ស្ថិរភាពនេះ បណ្តាលមកពីប្រាក់បញ្ញើជារូបិយប័ណ្ណបរទេស ក៏មានកំណើនយ៉ាងឆាប់រហ័សដូចប្រាក់បញ្ញើជារៀលដែរ ព្រមជាមួយនឹងលំហូរចូលនៃមូលធនពីបរទេសមកកាន់ប្រព័ន្ធធនាគារក្នុងស្រុកក៏មានកាន់តែច្រើន។

យ៉ាងណាក៏ដោយ សន្ទស្សន៍នៃកំណើនចំណែកប្រាក់បញ្ញើជារៀល បាននឹងកំពុងតែកើនឡើងនៅក្នុងតំបន់ជនបទទាំងក្នុងធនាគារពាណិជ្ជ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ។ ថ្វីបើប្រាក់បញ្ញើជារៀល មានការកើនឡើងនៅក្នុងស្ថាប័នធនាគារពាណិជ្ជយ៉ាងណាក្តី ក៏មានការកត់សម្គាល់ឃើញថា ដំណើរការនៃការលើកកម្ពស់ការប្រើប្រាស់រូបិយវត្ថុជាតិហាក់នៅមិនទាន់មានសកម្មភាពល្អប្រសើរនៅឡើយ។

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុភាគច្រើនកំពុងតែផ្តល់នូវកម្ចីជារៀលយ៉ាងសកម្ម ក៏ប៉ុន្តែប្រភពមូលធនភាគច្រើនរបស់គ្រឹះស្ថានទាំងនេះ គឺបានមកពីកម្ចីដែលកំណត់ជាប្រាក់ដុល្លារ។ បញ្ហានេះបានធ្វើឱ្យកើតមានឡើងនូវហានិភ័យតារាងតុល្យការ (Currency mismatch) ទៅលើបណ្តាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលកំពុងមានសកម្មភាពខ្លាំង ក្នុងការផ្តល់កម្ចីជារៀល។

### ៣.៤. ចក្ខុវិស័យ និងក្របខ័ណ្ឌគោលនយោបាយរបស់រាជរដ្ឋាភិបាល

ដោយសារមានភាពចាំបាច់នៃការលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល ក្នុងការពង្រឹងគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច សំដៅគាំទ្រកំណើនប្រកបដោយចីរភាព និងសមស្របទៅតាមនិន្នាការសកល និងការត្រៀមខ្លួនសម្រាប់សមាហរណកម្មវិស័យសេដ្ឋកិច្ច និងហិរញ្ញវត្ថុក្នុងតំបន់ដែលមានលក្ខណៈកាន់តែស៊ីជម្រៅ រាជរដ្ឋាភិបាលកម្ពុជាបានកំណត់យ៉ាងច្បាស់ពីគោលដៅលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលនៅក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០១៤-២០១៨ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១៦-២០២៥។ នៅក្នុងទិសដៅនេះ យុទ្ធសាស្ត្រលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល នឹងពង្រឹងតួនាទីរបស់រូបិយវត្ថុជាតិលើប្រតិបត្តិការក្នុងវិស័យរូបវន្ត ក៏ដូចជាវិស័យហិរញ្ញវត្ថុប្រកបដោយនិរន្តរភាពក្នុងគោលដៅឈានទៅរកការកាត់បន្ថយជាលំដាប់នូវការពឹងផ្អែកនៃសេដ្ឋកិច្ចទៅលើរូបិយប័ណ្ណ។

យុទ្ធសាស្ត្រលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលអាចត្រូវបានរៀបចំឡើង ដោយផ្អែកទៅលើបទពិសោធន៍នៃការធ្វើបដិដុល្លារូបនីយកម្មនៅក្នុងប្រទេសមួយចំនួន ការសិក្សាស្រាវជ្រាវលើស្ថានភាពដុល្លារូបនីយកម្មនៅកម្ពុជាដោយសេដ្ឋវិទូ និងស្ថាប័នហិរញ្ញវត្ថុអន្តរជាតិធំៗ ដូចជាមូលនិធិរូបិយវត្ថុអន្តរជាតិ ធនាគារពិភពលោក និងធនាគារអភិវឌ្ឍន៍អាស៊ី និងការធ្វើអង្កេតថ្មីៗរបស់ការិយាល័យស្រាវជ្រាវម៉ាក្រូសេដ្ឋកិច្ចអាស៊ាន+៣ (AMRO) និងភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA)។ ស្មារតីនៃការរៀបចំគោលនយោបាយនេះ គួរអនុលោមតាមគោលការណ៍ចម្បងៗដូចខាងក្រោម៖

- បញ្ហាដុល្លារូបនីយកម្មបានកើតឡើងនៅក្នុងសេដ្ឋកិច្ចក្នុងរយៈពេលមួយយូរ ហើយបានចាក់ឫសគល់ទៅក្នុងសេដ្ឋកិច្ច ហិរញ្ញវត្ថុ និងសង្គម។ មួយវិញទៀត ការអភិវឌ្ឍទីផ្សារហិរញ្ញវត្ថុ និងហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ចកម្ពុជា កំពុងស្ថិតនៅក្នុងដំណាក់កាលអភិវឌ្ឍដំបូងនៅឡើយ។ ដូច្នេះហើយ ការធ្វើបដិដុល្លារូបនីយកម្មត្រូវតែជាដំណើរការសន្សឹមៗ និងមួយជំហានម្តងៗ។
- ការប្តេជ្ញាចិត្ត ឆន្ទៈមុតមាំ និងកិច្ចខិតខំប្រឹងប្រែង ដែលត្រូវបានសម្របសម្រួល និងព្រមព្រៀងគ្នារវាងភាគីពាក់ព័ន្ធទាំងអស់ គឺជាកត្តាបឋមនិងជាមូលដ្ឋានក្នុងការលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល ពីព្រោះថាភាពជោគជ័យនៃគោលនយោបាយនេះ គឺអាស្រ័យដោយមានការចូលរួមអនុវត្តប្រកបដោយស្មារតីទទួលខុសត្រូវរបស់ភ្នាក់ងារពាក់ព័ន្ធជាច្រើន ទាំងវិស័យសាធារណៈ និងវិស័យឯកជន។ ហេតុនេះហើយ យុទ្ធសាស្ត្រលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលចាំបាច់ត្រូវរៀបចំជាយុទ្ធសាស្ត្រ ដែលនឹងក្លាយជាគោលនយោបាយរួមរបស់រាជរដ្ឋាភិបាលកម្ពុជា។
- ការធ្វើបដិដុល្លារូបនីយកម្មពិតជាមានភាពស្មុគស្មាញ និងហានិភ័យច្រើន។ ដូច្នេះទិសដៅគោលនយោបាយដ៏ត្រឹមត្រូវ និងប្រកបដោយភាពប្រុងប្រយ័ត្នគឺ "ការលើកកម្ពស់ការប្រើប្រាស់រូបិយវត្ថុជាតិ" ក្នុងរយៈពេលខ្លី និងមធ្យម ដោយមិនសំដៅទៅលើការបញ្ឈប់នូវការប្រើប្រាស់ប្រាក់ដុល្លារអាមេរិកភ្លាមៗ ឬដោយគំហុកនៅក្នុងសេដ្ឋកិច្ចនោះទេ។
- វិធានការរយៈពេលខ្លី និងមធ្យមនេះផ្តោតសំខាន់ទៅលើការលើកទឹកចិត្តចំពោះការប្រើប្រាស់ប្រាក់រៀល ជាជាងការដាក់គំនាបទៅលើការប្រើប្រាស់ប្រាក់ដុល្លារ។ គោលនយោបាយដាក់គំនាបលើការប្រើប្រាស់រូបិយប័ណ្ណ អាចបណ្តាលឱ្យមានការហូរចេញនៃមូលធនពីសេដ្ឋកិច្ចជាតិ និងកាត់បន្ថយអន្តរការីយកម្មហិរញ្ញវត្ថុ ហើយការដាក់ចេញនូវវិធានការនានា ត្រូវតែមានការពិចារណាឱ្យបានហ្មត់ចត់ ជៀសវាងការបង្កឧបសគ្គចំពោះដំណើរការយ៉ាងសកម្មនៃការអភិវឌ្ឍរចនាសម្ព័ន្ធទីផ្សារក្នុងប្រទេសនាពេលបច្ចុប្បន្ន។

- វិធានការរដ្ឋបាលមួយចំនួនអាចនឹងចាំបាច់យកមកពិចារណា និងដាក់ឱ្យប្រើប្រាស់សំដៅកែប្រែឥរិយាបថ និងទម្លាប់របស់សាធារណជនឱ្យងាកមករកការប្រើប្រាស់ប្រាក់រៀល។ វិធានការទាំងនេះគួរតែត្រូវបានចាត់ទុកជាឧបករណ៍គាំទ្រ និងបន្ទាប់បន្សំដែលគប្បីត្រូវតែបានអនុវត្តដោយប្រុងប្រយ័ត្ន។

យុទ្ធសាស្ត្រលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល ក៏បានបញ្ចូលផងដែរនូវទស្សនៈអនាគតដែលមានទិសដៅទប់ស្កាត់ការកើតឡើងនូវសកម្មភាព ឬប្រតិបត្តិការទាំងឡាយណាដែលអាចផ្តល់ផលប៉ះពាល់ដល់ការខិតខំក្នុងការលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល។

កំណើននៃការប្រើប្រាស់ប្រាក់រៀលនឹងមានឥទ្ធិពលយ៉ាងខ្លាំងទៅលើសេដ្ឋកិច្ច ហើយជាសត្យានុម័ត នឹងនាំមកនូវការប្រែប្រួលក្របខ័ណ្ឌដែលធ្វើឱ្យមានការផ្លាស់ប្តូរទិដ្ឋភាពការរៀបចំ និងដំណើរការនៃសេដ្ឋកិច្ចកម្ពុជាទាំងមូល។ ដូចនេះហើយ ដើម្បីសម្រេចបាននូវគោលដៅខាងលើ គឺចាំបាច់ត្រូវការដំណោះស្រាយយូរអង្វែងនិងទាមទារនូវគោលនយោបាយ និងផែនការសកម្មភាពច្បាស់លាស់ និងគ្រប់ជ្រុងជ្រោយ។

ផែនការសកម្មភាពនេះក៏មានបញ្ចូលកម្មវិធីកំណែទម្រង់ ដែលត្រូវបានកំណត់សម្រាប់រយៈពេលខ្លី មធ្យម និងវែង ហើយផ្តោតទៅលើមុខព្រួញសំខាន់ៗ ដែលអាចអនុញ្ញាតឱ្យមានការកែប្រែនូវឥរិយាបថ ទម្លាប់ និងការលើកទឹកចិត្តដល់ការផ្លាស់ប្តូរទស្សនៈរបស់សាធារណជនឱ្យនិយមប្រើប្រាស់រូបិយវត្ថុជាតិ។ សកម្មភាពនិងគំនិតផ្តួចផ្តើមនានាតាមផ្នែក និងវិស័យពាក់ព័ន្ធត្រូវបានកំណត់ស្របទៅតាមសមត្ថកិច្ច និងទំនួលខុសត្រូវរបស់អាជ្ញាធរពាក់ព័ន្ធ ហើយសកម្មភាព និងគំនិតផ្តួចផ្តើមមួយចំនួន អាចនឹងគួរមានអាទិភាពអនុវត្តមុនសកម្មភាពដទៃ ដែលនាំឱ្យដំណើរការអនុវត្តមានលំដាប់លំដោយ និងជំហានបន្តបន្ទាប់សមស្រប។

ដោយវិសាលភាពនៃវិធានការគោលនយោបាយដែលត្រូវអនុវត្ត និងភាពស្មុគស្មាញនៃបញ្ហាដុល្លារូបនីយកម្ម យុទ្ធសាស្ត្រនេះមានលក្ខណៈជាផែនការរំកិល ដើម្បីអាចពិនិត្យវាយតម្លៃនិងកែលម្អតាមភាពចាំបាច់ ចំពោះរាល់វិធានការគោលនយោបាយដែលបានដាក់ចេញ រួមទាំងដំណើរការអនុវត្តដែលពាក់ព័ន្ធដោយផ្អែកលើកម្រិតនៃវឌ្ឍនភាពដែលទទួលបាន។ ជាមួយគ្នានេះ ដើម្បីផ្តល់ជាមូលដ្ឋានសម្រាប់រៀបចំគោលនយោបាយឱ្យមានភាពស៊ីសង្វាក់ និងអនុញ្ញាតឱ្យមានភាពបត់បែនស្របទៅតាមស្ថានភាពជាក់ស្តែង យុទ្ធសាស្ត្រនេះត្រូវបានបែងចែកចេញជា ២ ផ្នែក គឺៈ ១), គោលដៅនៃគោលនយោបាយ និង ២),ផែនការសកម្មភាពលម្អិតដើម្បីឈានទៅសម្រេចគោលនយោបាយនីមួយៗ។

## ៣.៥. យុទ្ធសាស្ត្រលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល

ដើម្បីទទួលបាននូវផ្លែផ្កាលើគោលដៅរួម ក្នុងការលើកកម្ពស់ការប្រើប្រាស់រូបិយវត្ថុជាតិ ការកំណត់ឱ្យបានច្បាស់នូវទិសដៅគោលនយោបាយចម្បងៗតាមវិស័យ ព្រមទាំងការទទួលបន្ទុកដឹកនាំអនុវត្ត និងសហការអនុវត្តពិតជាមានសារសំខាន់ជាខ្លាំង។ បន្ថែមពីនេះ បណ្តាគោលនយោបាយគាំទ្រដទៃទៀត ក៏នឹងរួមចំណែកធ្វើឱ្យដំណើរការឆ្ពោះទៅកាន់ភាពជោគជ័យដោយរលូន និងមានប្រសិទ្ធភាពផងដែរ។ យុទ្ធសាស្ត្រនេះ បែងចែកជាគោលនយោបាយចម្បងចំនួន៩ គឺ៖ ១),គោលនយោបាយរូបិយវត្ថុនិងអត្រាប្តូរប្រាក់ ២),គោលនយោបាយសារពើពន្ធ ៣),គោលនយោបាយពាណិជ្ជកម្ម ៤),គោលនយោបាយហិរញ្ញវត្ថុ និងក្របខ័ណ្ឌបទប្បញ្ញត្តិប្រុងប្រយ័ត្ន ៥),គោលនយោបាយអភិវឌ្ឍន៍ទីផ្សារ ៦),ការអភិវឌ្ឍប្រព័ន្ធទូទាត់ ៧),ការលើកកម្ពស់ការយល់ដឹង និងការចូលរួម ៨),កិច្ចសហប្រតិបត្តិការដើម្បីអនុវត្តវិធានការប្រកបដោយប្រសិទ្ធភាព និង ៩),គោលនយោបាយគាំទ្រនានា។

### ៣.៥.១. គោលនយោបាយរូបិយវត្ថុ និងអត្រាប្តូរប្រាក់

ប្រទេសកម្ពុជារក្សាបានស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចយ៉ាងល្អប្រសើរក្នុងរយៈពេល ២ ទសវត្សរ៍ចុងក្រោយនេះ ដែលឆ្លុះបញ្ចាំងតាមរយៈស្ថិរភាពថ្លៃនិងអត្រាប្តូរប្រាក់។ ស្ថិរភាពនេះផងដែរ បានបង្កើនទំនុកចិត្តរបស់សាធារណជន និងភ្នាក់ងារសេដ្ឋកិច្ចនានា មកលើសេដ្ឋកិច្ចនិងការប្រើប្រាស់រូបិយវត្ថុជាតិជាលំដាប់ ព្រមទាំងបានបើកកាលានុវត្តភាពឱ្យអាជ្ញាធរដាក់ឱ្យអនុវត្តវិធានការថ្មីៗបន្ថែមទៀត ដើម្បីជំរុញការប្រើប្រាស់រូបិយវត្ថុជាតិឱ្យកាន់តែមានភាពទូលំទូលាយ។

គោលនយោបាយរូបិយវត្ថុ គួរបន្តអនុវត្តដោយភាពទន់ភ្លន់ និងប្រុងប្រយ័ត្ន សំដៅរក្សាឱ្យបាននូវស្ថិរភាពថ្លៃ ដើម្បីការពារអំណាចទិញរបស់រូបិយវត្ថុជាតិ។ ដើម្បីឆ្លើយតបឱ្យបានកាន់តែប្រសើរនូវកំណើនតម្រូវការរូបិយវត្ថុជាតិ ការសម្រួលចរាចរណ៍ប្រាក់រៀលនៅក្នុងសេដ្ឋកិច្ចពិតជាមានសារសំខាន់ណាស់។ ហេតុនេះហើយ ធនាគារជាតិនៃកម្ពុជានឹងពង្រឹងនូវយន្តការបែងចែក និងផ្គត់ផ្គង់ប្រាក់រៀលឱ្យស្របទៅនឹងតម្រូវការទីផ្សារ ហើយបន្តស្វែងរកឱកាសក្នុងការលើកកម្ពស់ប្រសិទ្ធភាពគោលនយោបាយរូបិយវត្ថុ តាមរយៈការអភិវឌ្ឍឧបករណ៍គោលនយោបាយរូបិយវត្ថុ និងពង្រឹងយន្តការចម្លងឥទ្ធិពល (Transmission Mechanism) នៃការអនុវត្តគោលនយោបាយរូបិយវត្ថុ។

ជាមួយគ្នានេះដែរ ការរក្សាស្ថិរភាពអត្រាប្តូរប្រាក់នៅតែជាគោលនយោបាយចាំបាច់ ដើម្បីបង្កើនជំនឿទុកចិត្តមកលើប្រាក់រៀល សំដៅឱ្យមានតម្រូវការរូបិយវត្ថុជាតិ។ នៅក្នុងរយៈពេលខ្លី

និងមធ្យម ការរក្សារបបអត្រាប្តូរប្រាក់អណ្តែតមានការគ្រប់គ្រង (Stabilized exchange rate regime) មានសារសំខាន់ណាស់ដើម្បីសម្រេចបានតាមគោលដៅនេះ។

ធនាគារជាតិនៃកម្ពុជា នឹងបន្តអភិវឌ្ឍក្របខ័ណ្ឌ និងយន្តការដេញថ្លៃលក់និងទិញរូបិយប័ណ្ណ ដើម្បីពង្រឹងប្រសិទ្ធភាព និងកំណត់អត្រាប្តូរប្រាក់ឱ្យកាន់តែឆ្លុះបញ្ចាំងពីស្ថានភាពទីផ្សារ។ នៅក្នុងរយៈពេលវែង អត្រាប្តូរប្រាក់នឹងអនុញ្ញាតឱ្យមានភាពបត់បែនកាន់តែច្រើនស្របតាមបម្រែបម្រួលស្ថានភាពសេដ្ឋកិច្ច និងធ្វើឱ្យភ្នាក់ងារសេដ្ឋកិច្ចយល់ដឹងពីហានិភ័យនៃការកាន់កាប់រូបិយវត្ថុអន្តរជាតិដោយសារការប្រែប្រួលអត្រាប្តូរប្រាក់។

### ៣.៥.២. គោលនយោបាយសារពើពន្ធ

ជាការពិតណាស់ គោលនយោបាយសារពើពន្ធប្រៀបបានដូចជាស្នូលនៃការជំរុញការប្រើប្រាស់រូបិយវត្ថុរបស់ភ្នាក់ងារសេដ្ឋកិច្ចទាំងអស់ ដោយសារការទទួលស្គាល់និងប្រើប្រាស់រូបិយវត្ថុនៃប្រទេសមួយគឺចាំបាច់ត្រូវមានការគាំទ្ររបស់រាជរដ្ឋាភិបាល។ តាមរយៈការគ្រប់គ្រងចំណូលនិងចំណាយរបស់ខ្លួន រដ្ឋាភិបាលនឹងបង្កើនចរន្តនៃលំហូររូបិយវត្ថុឱ្យកាន់តែសកម្ម ដែលក្នុងពេលដំណាលគ្នានោះនឹងបង្កើនទាំងតម្រូវការនិងផ្គត់ផ្គង់រូបិយវត្ថុនៅក្នុងសេដ្ឋកិច្ច។ ដូចនេះ ការកំណត់និងការទូទាត់ជារូបិយវត្ថុជាតិនៅក្នុងគ្រប់ប្រតិបត្តិការចំណូលចំណាយរបស់រដ្ឋ រាប់តាំងពីចំណាយឬចំណូលតូចតាច រហូតដល់ទំហំធំនៅក្នុងស្រុកលើគ្រប់ទិដ្ឋភាព មានសារសំខាន់ណាស់នៅក្នុងការរួមចំណែកដោយផ្ទាល់ដល់ការលើកកម្ពស់ការគាំទ្រ និងប្រើប្រាស់រូបិយវត្ថុជាតិ។

រាជរដ្ឋាភិបាលគួរផ្តោតការយកចិត្តទុកដាក់លើការកាត់បន្ថយឱនភាពថវិកា តាមរយៈការធ្វើវិចារណកម្មចំណាយ ព្រមទាំងពង្រឹងមូលដ្ឋានពន្ធនិងបង្កើនប្រសិទ្ធភាពនៃការប្រមូលពន្ធនៅក្នុងប្រទេស។ ឱនភាពថវិកាមានកម្រិតទាបនឹងអនុញ្ញាតឱ្យរដ្ឋាភិបាលគ្រប់គ្រងបំណុលបានល្អប្រសើរនិងពង្រឹងជំនឿទុកចិត្តរបស់ភ្នាក់ងារសេដ្ឋកិច្ចមកលើស្ថាប័នសាធារណៈនិងរូបិយវត្ថុជាតិ។ ជាមួយគ្នានេះ រដ្ឋាភិបាលនឹងប្រមូលផ្តុំចំណូលថវិកាជាតិជារូបិយប័ណ្ណចូលទៅក្នុងធនាគារជាតិនៃកម្ពុជាដោយអនុវត្តក្រោមរូបភាពជាប្រាក់បញ្ញើ ឬលក់ជូនធនាគារជាតិនៃកម្ពុជា។ ការប្រមូលផ្តុំរូបិយប័ណ្ណចូលទៅក្នុងធនាគារជាតិនៃកម្ពុជា នឹងបង្កលក្ខណៈងាយស្រួលផងដែរដល់រដ្ឋាភិបាលក្នុងការគ្រប់គ្រងចំណូលជារូបិយប័ណ្ណ និងធ្វើការប្តូរជារូបិយវត្ថុបានគ្រប់ពេលវេលាតាមតម្រូវការ។ នៅក្នុងករណីដែលត្រូវការហិរញ្ញប្បទានថវិកាជាតិ រដ្ឋាភិបាលនឹងបោះផ្សាយមូលបត្របំណុលរបស់រដ្ឋជារូបិយវត្ថុជាតិ និងជៀសវាងការបោះផ្សាយនូវរាល់ឧបករណ៍បំណុលជារូបិយប័ណ្ណ។

ម្យ៉ាងវិញទៀត ប្រទេសជាច្រើនដែលទទួលបានជោគជ័យក្នុងការបង្កើនតួនាទីរូបិយវត្ថុជាតិ បានខិតខំធានាថា បន្ទុកពន្ធជាក់ស្តែង (effective tax) នៅលើទ្រព្យសកម្មនិងអកម្មដែលចារឹកជារូបិយវត្ថុក្នុងស្រុកមិនខ្ពស់ជាងបន្ទុកពន្ធនៅលើទ្រព្យសកម្ម និងទ្រព្យអកម្ម ដែលចារឹកជារូបិយ-ប័ណ្ណបរទេសឡើយ។ នៅក្នុងករណីខ្លះទៀត ឧបករណ៍ចារឹកជារូបិយប័ណ្ណត្រូវរងបន្ទុកពន្ធធ្ងន់ធ្ងរជាងឧបករណ៍ចារឹកជារូបិយវត្ថុជាតិ។ ឧទាហរណ៍ ការដាក់ពន្ធលើប្រាក់ចំណូល ឬចំណេញជាប្រាក់រៀលដែលទទួលបានមកពីសកម្មភាពសេដ្ឋកិច្ចនានា ឬប្រាក់បញ្ញើជារៀលក្នុងប្រព័ន្ធធនាគារ ឬការផ្ទេរនានាជាប្រាក់រៀលជាដើម នឹងត្រូវលើកទឹកចិត្តតាមរយៈការដាក់កម្រិតអត្រាពន្ធពិតមួយដែលអំណោយផលដល់រូបិយវត្ថុជាតិ។

### ៣.៥.៣. គោលនយោបាយពាណិជ្ជកម្ម

រូបិយវត្ថុគឺជាកាតាលីករដែលជួយជំរុញដំណើរការនៃសកម្មភាពពាណិជ្ជកម្ម។ ទន្ទឹមនេះ ការរីកចម្រើននៃសកម្មភាពពាណិជ្ជកម្មក៏ជាកត្តាដែលបង្កើនតម្រូវការរូបិយវត្ថុផងដែរ។ ដូចនេះ ការផ្សារភ្ជាប់គោលនយោបាយលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល និងគោលនយោបាយពាណិជ្ជកម្មមានសារសំខាន់ខ្លាំងណាស់ ដើម្បីរក្សានិរន្តរភាពនៃការប្រើប្រាស់ប្រាក់រៀលដោយភ្នាក់ងារសេដ្ឋកិច្ចក្នុងសកម្មភាពដោះដូររបស់ខ្លួន។

រដ្ឋាភិបាលគួរកាត់បន្ថយឱនភាពពាណិជ្ជកម្ម តាមរយៈការពង្រឹងការនាំចេញ និងកាត់បន្ថយការនាំចូល។ ការបង្កើនការនាំចេញ នឹងត្រូវគាំទ្រដោយការបង្កើនផលិតភាពនៃផលិតកម្មពង្រីកនិងពិពិធកម្មទាំងទីផ្សារនិងផលិតផលដែលផលិតក្នុងស្រុក។ កំណើនផលិតកម្មក្នុងស្រុកមិនត្រឹមតែនឹងបង្កើនតម្រូវការរូបិយវត្ថុ នៅក្នុងការដោះដូរផលិតផលទាំងនោះទេ តែថែមទាំងជួយកាត់បន្ថយការនាំចូល ដូច្នេះបន្ថយតម្រូវការនៃរូបិយប័ណ្ណ។ រដ្ឋាភិបាលក៏បានដាក់ឱ្យអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម ដែលជំរុញឱ្យមានការរីកដុះដាលនៃសហគ្រាសធនតូចនិងមធ្យម និងផលិតកម្មក្នុងស្រុក ដែលទាំងនេះនឹងរួមចំណែកកាត់បន្ថយឱនភាពជញ្ជីងពាណិជ្ជកម្មផងដែរ។ បន្ថែមពីនេះ រដ្ឋាភិបាលគួរបន្តគាំទ្រដល់ការបង្កើនផលិតភាពលើផលិតកម្មនានាតាមរយៈការអភិវឌ្ឍបច្ចេកទេសនិងជំនាញនានាឱ្យកាន់តែប្រសើរឡើង ដើម្បីបង្កើនផលិតកម្មក្នុងស្រុក។ ទន្ទឹមនេះ ការបន្តជំរុញផលិតកម្មលើវិស័យកសិកម្ម ក៏នឹងរួមចំណែកដោយផ្ទាល់ដល់ការកាត់បន្ថយការនាំចូលទំនិញកសិកម្មពីបរទេស ជាពិសេសប្រទេសជិតខាង និងបង្កើនតម្រូវការប្រាក់រៀល ដោយសារប្រាក់រៀលត្រូវប្រើប្រាស់លើសលប់នៅក្នុងវិស័យកសិកម្ម។ ទាក់ទងទៅនឹងវិស័យសេវាកម្ម ប្រទេសកម្ពុជាមានឧត្តមភាពខ្ពស់ដោយសារចំណូលដុលពីវិស័យនេះ មានអតិរេក

ដែលគាំទ្រដោយវិស័យទេសចរណ៍។ នាពេលកន្លងមក ការទទួលបានរូបិយប័ណ្ណពីភ្ញៀវទេសចរត្រូវបានប្រើប្រាស់បន្តដោយគ្មានការប្តូរប្រាក់ទៅជារូបិយវត្ថុជាតិនោះទេ។ ក្នុងបរិការណ៍នេះ ធនាគារជាតិ នៃកម្ពុជា ក៏ដូចជាអាជ្ញាធរពាក់ព័ន្ធ ដូចជាក្រសួងទេសចរណ៍ និងអាជ្ញាធរមានសមត្ថកិច្ច គឺបង្កើនការប្រើប្រាស់ប្រាក់រៀលរបស់ទេសចរ និងស្រូបយករូបិយប័ណ្ណដែលទទួលបានទៅចូលក្នុងប្រព័ន្ធធនាគារ។

សម្រាប់ការដោះដូរក្នុងស្រុក ការកំណត់យករូបិយវត្ថុជាតិជាឯកតាកំណត់និងតាំងថ្លៃ និងជាមធ្យោបាយទូទាត់ នឹងបង្កើនការប្រើប្រាស់ប្រាក់រៀលដោយផ្ទាល់នៅក្នុងសេដ្ឋកិច្ច ហើយជាបន្តបន្ទាប់ នឹងអាចមានឥទ្ធិពលវិជ្ជមានដល់ការប្រើប្រាស់ប្រាក់រៀលដោយផ្ទាល់នៅក្នុងវិស័យហិរញ្ញវត្ថុថែមទៀតផង។

រាជរដ្ឋាភិបាលគួរលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលឱ្យកាន់តែមានភាពទូលំទូលាយ ជាឯកតាកំណត់ថ្លៃនិងដាក់តាំងថ្លៃ។ ការជំរុញមុខងារប្រាក់រៀលជាឯកតាកំណត់ និងដាក់តាំងថ្លៃគួរត្រូវអនុវត្តនៅក្នុងផ្នែក ឬវិស័យជាក់លាក់មួយចំនួន បន្ទាប់មកអាចនឹងជំរុញ ឬពង្រីកន្ថែមទៀត នៅក្នុងផ្នែកឬវិស័យជាក់លាក់ដទៃទៀត។ ដោយផ្អែកទៅតាមទ្រឹស្តី និងបទពិសោធន៍របស់អន្តរជាតិ វិធានការបែបនេះមានផលប៉ះពាល់តិចតួចបំផុតចំពោះទំនុកចិត្តរបស់សាធារណជន និងដំណើរការសេដ្ឋកិច្ច។ ដំណាក់កាលនេះក៏ជាមូលដ្ឋានគ្រឹះដ៏សំខាន់ផងដែរចំពោះការលើកកម្ពស់តួនាទីប្រាក់រៀលជាមធ្យោបាយទូទាត់។ បើសិនជាគ្មានវឌ្ឍនភាពសម្រាប់ការដាក់ឱ្យប្រើប្រាស់ប្រាក់រៀលសម្រាប់ការកំណត់និងការតាំងថ្លៃទំនិញ និងសេវាឱ្យបានទូលំទូលាយទេនោះ ការលើកស្ទួយប្រាក់រៀលជាមធ្យោបាយទូទាត់យ៉ាងទូលំទូលាយនឹងនៅតែមានកម្រិត។

ដើម្បីឱ្យការអនុវត្តនេះប្រព្រឹត្តទៅដោយមានប្រសិទ្ធភាព អាជ្ញាធរចាំបាច់ត្រូវអនុញ្ញាតឱ្យមានរយៈពេលអន្តរកាលមួយ (ឧទាហរណ៍ ១ឬ ២ឆ្នាំ) សម្រាប់ត្រៀមលក្ខណៈផ្លាស់ប្តូរពីការកំណត់និងការដាក់តាំងថ្លៃជាប្រាក់ដុល្លារមកជាប្រាក់រៀលវិញ។ នៅក្នុងកំឡុងពេលអន្តរកាលនេះ ផ្អែកលើការស្ម័គ្រចិត្តរបស់វិស័យឯកជន ថ្លៃទំនិញអាចបន្តដាក់តាំងជាប្រាក់ដុល្លារដែលនឹងជួយសម្រួលជាបណ្តើរៗចំពោះពាណិជ្ជករក្នុងការរៀបចំចាត់ចែងដាក់ថ្លៃថ្មីទៅលើទំនិញរបស់ពួកគេ។ បន្ទាប់ពីដំណាក់កាលនេះថ្លៃទំនិញទាំងអស់ត្រូវឈប់បង្ហាញជារូបិយប័ណ្ណ។ នៅក្នុងរយៈពេលខ្លីទៅមធ្យម ប្រាក់បៀវត្សក៏ត្រូវចារឹកជាប្រាក់រៀលដែរ។ ក៏ប៉ុន្តែ ក្នុងកំឡុងពេលអន្តរកាលមួយដោយឡែក ប្រាក់បៀវត្សអាចត្រូវបានលើកលែងឱ្យបន្តកំណត់ជាប្រាក់ដុល្លារដដែល ដើម្បីឱ្យនិយោជក និងធនាគារមានពេលវេលាសម្រាប់កែប្រែការចុះកិច្ចបញ្ជិកាក្នុងគណនេយ្យរបស់ខ្លួន។

រាជរដ្ឋាភិបាលគួរលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល ឱ្យកាន់តែមានភាពទូលំទូលាយជាមធ្យោបាយទូទាត់។ ក្នុងពេលដែលការកំណត់និងតាំងថ្លៃទំនិញនិងសេវាជាប្រាក់រៀលនៅក្នុងសកម្មភាពពាណិជ្ជកម្ម មិនមែនមានន័យជាស្វ័យប្រវត្តិថាការទូទាត់ត្រូវតែចាំបាច់ធ្វើឡើងជាប្រាក់រៀលទេ។ នៅក្នុងដំណាក់កាលដំបូង ការប្រើប្រាស់ប្រាក់រៀលនៅក្នុងការទូទាត់ អាចត្រូវបានលើកទឹកចិត្តនិងពង្រឹង ហើយប្រសិនបើចាំបាច់ អាចត្រូវដាក់ឱ្យអនុវត្តចំពោះប្រតិបត្តិការ ដែលទាក់ទងនឹងវិស័យសាធារណៈ និងចំពោះប្រតិបត្តិការដែលមានតម្លៃតូចៗនៅក្នុងវិស័យឯកជន។ ដូចគ្នានឹងការកំណត់និងតាំងថ្លៃទំនិញជារូបិយវត្ថុដែរ វិធានការលើកកម្ពស់ការទូទាត់ជាប្រាក់រៀលនឹងត្រូវធ្វើទៀតជាបណ្តើរៗ ស្របទៅតាមការវិវត្តនៃសភាពការណ៍ និងទុករយៈពេលអន្តរកាលមួយជូនភ្នាក់ងារសេដ្ឋកិច្ចដើម្បីអនុវត្ត។

សរុបជារួម អំឡុងពេលអន្តរកាលអាចមានរយៈពេលខុសៗគ្នា អាស្រ័យទៅនឹងប្រភេទទំនិញឬសេវា ឬផ្នែកនិងវិស័យដែលជាកម្មវត្ថុនៃវិធានការ និងជាពិសេស អាស្រ័យលើភាពងាយទទួលយកបានពីសំណាក់មជ្ឈដ្ឋានពាក់ព័ន្ធផ្ទាល់។

### ៣.៥.៤. គោលនយោបាយហិរញ្ញវត្ថុ និងក្របខ័ណ្ឌបទប្បញ្ញត្តិប្រុងប្រយ័ត្ន

ដុល្លារូបនីយកម្មវិស័យហិរញ្ញវត្ថុ សំដៅទៅលើស្ថានភាពដែលវិស័យឯកជនរក្សាទុករូបិយ-វត្ថុអន្តរជាតិក្នុងទម្រង់ជាសាច់ប្រាក់និងជាប្រាក់បញ្ញើ ក៏ដូចជាក្នុងករណីដែលស្ថាប័នហិរញ្ញវត្ថុរក្សាទុកទ្រព្យសកម្មនិងទ្រព្យអកម្មហិរញ្ញវត្ថុជារូបិយប័ណ្ណ។ បទពិសោធន៍របស់អន្តរជាតិបានបង្ហាញថា ការប្រើប្រាស់គោលនយោបាយកាត់បន្ថយដុល្លារូបនីយកម្មនៅក្នុងវិស័យហិរញ្ញវត្ថុ ដូចជា ការបង្ខំឱ្យប្តូរប្រាក់បញ្ញើជារូបិយប័ណ្ណបរទេសទៅជារូបិយវត្ថុជាតិ ឬការហាមឃាត់ការដាក់ប្រាក់បញ្ញើជារូបិយប័ណ្ណ[11]នឹងធ្វើឱ្យមានការហូរចេញទៅក្រៅនៃមូលធន និងកាត់បន្ថយការហូរចូលមូលធនបរទេសមកក្នុងសេដ្ឋកិច្ចជាតិ ដែលកត្តាទាំងនេះមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរលើស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ការវិនិយោគ និងកំណើនសេដ្ឋកិច្ច។

ការលើកកម្ពស់ការប្រើប្រាស់រូបិយវត្ថុជាតិនៅក្នុងវិស័យហិរញ្ញវត្ថុ ពាក់ព័ន្ធនឹងពហុវិស័យដែលតម្រូវឱ្យមានគោលនយោបាយគាំទ្រដទៃទៀត ទាំងកម្រិតម៉ាក្រូនិងមីក្រូ និងការចូលរួមសកម្មពីសំណាក់ភាគីពាក់ព័ន្ធផ្សេងៗ។ ដូច្នេះ គោលនយោបាយចំពោះដុល្លារូបនីយកម្មវិស័យ

[11] ធនាគារកណ្តាលឡាវធ្លាប់បានចេញប្រកាសហាមដកប្រាក់បញ្ញើជារូបិយប័ណ្ណ ហើយថ្ងៃបន្ទាប់មកបានដាក់ចេញវិញដោយឥទ្ធិពលនៃការធ្លាក់ចុះជាគំហុក នៃប្រាក់បញ្ញើ

ហិរញ្ញវត្ថុ នឹងត្រូវបានពិចារណាដោយប្រុងប្រយ័ត្នបំផុតដើម្បីជៀសវាងផលវិបាកដែលអាចផ្តល់បច្ច័យមិនល្អដល់ការរីកចម្រើនកន្លងមកក្នុងការបង្កើនការប្រើប្រាស់ប្រាក់រៀល។

នាពេលបច្ចុប្បន្ននេះ វិស័យហិរញ្ញវត្ថុត្រូវបានគ្របដណ្តប់ដោយវិស័យធនាគារ ដែលមានទ្រព្យសកម្មប្រមាណលើសពី៩០% នៃទ្រព្យសកម្មវិស័យហិរញ្ញវត្ថុទាំងមូល។ ជាមួយគ្នានេះដែរ អន្តរការីយកម្មនៅក្នុងវិស័យធនាគារ និងមីក្រូហិរញ្ញវត្ថុជិត ៩០% ធ្វើឡើងជាប្រាក់ដុល្លារ។ ទោះជាយ៉ាងណាក៏ដោយ ការអនុវត្តគោលនយោបាយលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលកន្លងមកបានបង្កើនទាំងប្រាក់បញ្ញើ និងឥណទានជាប្រាក់រៀលជាលំដាប់ ប៉ុន្តែនៅមានកម្រិតទាបនៅឡើយ ក្នុងនោះវិស័យមីក្រូហិរញ្ញវត្ថុបានដើរតួនាទីយ៉ាងសកម្ម។ ទន្ទឹមនេះការបង្កើនបរិយាប័ន្នហិរញ្ញវត្ថុជាប្រាក់រៀលដោយការផ្តល់សេវាទាំងប្រាក់បញ្ញើនិងឥណទាន និងការផ្ទេរប្រាក់ជារៀល អាចចូលរួមចំណែកយ៉ាងសំខាន់ដល់ការពង្រីកការប្រើប្រាស់ប្រាក់រៀលនៅគ្រប់មជ្ឈដ្ឋាន។

នៅចំពោះមុខស្ថានភាពខាងលើនេះ វិស័យធនាគារនិងហិរញ្ញវត្ថុនឹងបង្កបង្កើនភាពស៊ីជម្រៅផ្នែកហិរញ្ញវត្ថុនិងអន្តរការីយកម្មហិរញ្ញវត្ថុជាប្រាក់រៀលបន្ថែមទៀត ដោយបង្កើតលក្ខណៈអំណោយផលនានាដល់ការប្រើប្រាស់ប្រាក់រៀលជាងរូបិយប័ណ្ណ។ ដូចនេះ វិស័យធនាគារនិងហិរញ្ញវត្ថុគួរត្រូវបានលើកទឹកចិត្តនិងជំរុញឱ្យផ្តល់សេវាហិរញ្ញវត្ថុនានា (ដូចជា សេវាឥណទាន ប្រាក់បញ្ញើ និងផ្ទេរប្រាក់ ជាដើម) ជាប្រាក់រៀល។ ទន្ទឹមនេះ អាជ្ញាធរគួរមានគោលនយោបាយលើកទឹកចិត្តសាធារណជន ដើម្បីឱ្យការប្រើប្រាស់សេវាទាំងនេះមានភាពទាក់ទាញជាងប្រាក់ដុល្លារជាដើម។ ក្នុងទិសដៅនេះ ការសិក្សាពីលទ្ធភាពបង្កើតប្រព័ន្ធធានារ៉ាប់រងលើប្រាក់បញ្ញើជារៀលនឹងក្លាយជាវិធានការគាំទ្រដ៏សំខាន់មួយ។

ជាមួយគ្នានេះ ក្របខ័ណ្ឌបទប្បញ្ញត្តិប្រុងប្រយ័ត្នក្នុងវិស័យហិរញ្ញវត្ថុនឹងត្រូវពង្រឹងដើម្បីបន្តរក្សាស្ថិរភាពហិរញ្ញវត្ថុឱ្យបានប្រសើរ។ បទប្បញ្ញត្តិប្រុងប្រយ័ត្នទាំងនេះ នឹងត្រូវបញ្ជ្រាបស្មារតីនៃការប្រើប្រាស់ប្រាក់រៀល ដូចជាការកំណត់លក្ខខណ្ឌខុសគ្នារវាងរូបិយវត្ថុនិងរូបិយប័ណ្ណទៅលើអនុបាតសន្ទនីយភាព និងអត្រាប្រាក់បម្រុងកាតព្វកិច្ច ជាដើម។

មួយវិញទៀត ការបង្កើនទំនាក់ទំនងប្រតិបត្តិការរវាងគ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុ និងរវាងគ្រឹះស្ថានធនាគារនិងអាជីវករប្តូរប្រាក់ នឹងមានការចាំបាច់ដើម្បីឱ្យគ្រឹះស្ថានទាំងនេះអាចធ្វើប្រតិបត្តិការហិរញ្ញវត្ថុរវាងគ្នា ដើម្បីបង្កើតទីផ្សារក៏ដូចជាបំពេញសេចក្តីត្រូវការរបស់ប្រាក់រៀលក្នុងចំណោមភ្នាក់ងារសេដ្ឋកិច្ចដែលប្រើប្រាស់រូបិយប័ណ្ណក្នុងសេដ្ឋកិច្ច។

### ៣.៥.៥. គោលនយោបាយអភិវឌ្ឍន៍ទីផ្សារ

នៅក្នុងពេលកន្លងមក ទីផ្សារហិរញ្ញវត្ថុដែលគាំទ្រការប្រើប្រាស់រូបិយវត្ថុជាតិស្ថិតនៅក្នុងដំណាក់កាលដំបូងនៃការអភិវឌ្ឍនៅឡើយ។ ទីផ្សារទាំងនេះនឹងបង្កើនបរិយាកាសអំណោយផលដល់ការប្រើប្រាស់ប្រាក់រៀល និងឧបករណ៍ហិរញ្ញវត្ថុជារៀល និងផ្តល់ភាពងាយស្រួលដល់គំនិតផ្តួចផ្តើមដទៃទៀតក្នុងការជំរុញការប្រើប្រាស់ប្រាក់រៀល។ ទីផ្សារសំខាន់ៗដែលត្រូវអភិវឌ្ឍរួមមាន ៖ ទីផ្សារប្តូរប្រាក់ ទីផ្សារអន្តរធនាគារនិងរូបិយវត្ថុ និងទីផ្សារមូលបត្រ។

**ក. ការអភិវឌ្ឍទីផ្សារប្តូរប្រាក់ ៖** ទីផ្សារប្តូរប្រាក់ជាសសរទ្រូងមួយដ៏សំខាន់នៅក្នុងប្រព័ន្ធហិរញ្ញវត្ថុដែលមានតួនាទីដ៏សកម្មក្នុងការជួយសម្រួលការប្រើប្រាស់ប្រាក់រៀល។ នាពេលបច្ចុប្បន្ននេះ ទីផ្សារប្តូរប្រាក់នៅកម្ពុជាមានលក្ខណៈជាទីផ្សាររាយដែលមានអាជីវករប្តូរប្រាក់ដើរតួនាទីដ៏សំខាន់ ហើយប្រតិបត្តិការទូទាត់នៅពឹងផ្អែកលើការប្រើប្រាស់សាច់ប្រាក់ ជាជាងការបង្វែរតាមប្រព័ន្ធធនាគារ ដែលធ្វើឱ្យទីផ្សារនេះមិនទាន់មានភាពស៊ីជម្រៅនៅឡើយ។ នាពេលកន្លងមក ទីផ្សារនេះបានគាំទ្រការប្រើប្រាស់រូបិយប័ណ្ណអន្តរជាតិរបស់ភ្នាក់ងារសេដ្ឋកិច្ច ដោយសារវត្តមានស្ទើរគ្រប់ទីកន្លែងនៃអាជីវករប្តូរប្រាក់ ភាពរីកចម្រើននៃបណ្តាញភ្នាក់ងារប្តូរប្រាក់ក្រៅផ្លូវការនៅក្នុងតំបន់និងថ្នាក់ជាតិ និងការផ្តល់នូវអត្រាប្តូរប្រាក់ក្នុងកម្រិតអំណោយផលដល់អ្នកប្រើប្រាស់រូបិយប័ណ្ណ (បច្ចុប្បន្ន គម្លាតអត្រាប្តូរប្រាក់នៅកម្ពុជាមានកម្រិតទាបបើធៀបនឹងប្រទេសដទៃទៀត ហើយមិនទាន់មានការដាក់ពន្ធលើការប្តូរប្រាក់ទេ)។ ការអភិវឌ្ឍទីផ្សារប្តូរប្រាក់បន្ថែមទៀតឱ្យក្លាយជាទីផ្សារលក់ដុំ និងមានគ្រឹះស្ថានធនាគារជាអ្នកដើរតួនាទីស្នូលក្នុងប្រតិបត្តិការប្តូរប្រាក់មានសាសំខាន់ណាស់ ដើម្បីប្រមូលរូបិយប័ណ្ណអន្តរជាតិឱ្យចូលទៅក្នុងវិស័យធនាគារ និងឆ្លើយតបទៅនឹងតម្រូវការប្រាក់រៀលនៅលើទីផ្សារឱ្យកាន់តែប្រសើរឡើង។ នៅក្នុងទិសដៅនេះ អាជ្ញាធរគួរបង្កើនការត្រួតពិនិត្យ ពង្រឹងក្របខ័ណ្ឌបទប្បញ្ញត្តិ និងសមត្ថភាពស្ថាប័នដើម្បីឱ្យទីផ្សារប្តូរប្រាក់ប្រព្រឹត្តិទៅប្រកបដោយប្រសិទ្ធភាពខ្ពស់ និងមានការគ្រប់គ្រងល្អ ដែលអំណោយផលដល់ការគៀងគររូបិយ-ប័ណ្ណអន្តរជាតិចូលក្នុងប្រព័ន្ធធនាគារ និងការផ្គត់ផ្គង់ប្រាក់រៀលឱ្យបានកាន់តែច្រើននៅក្នុងសេដ្ឋកិច្ច។

**ខ. ទីផ្សារអន្តរធនាគារ និងរូបិយវត្ថុ ៖** ទីផ្សារអន្តរធនាគារនិងរូបិយវត្ថុនាពេលបច្ចុប្បន្ននេះ កំពុងស្ថិតនៅក្នុងដំណាក់កាលដំបូងនៃការអភិវឌ្ឍនៅឡើយ។ ធនាគារធំៗមួយចំនួនបានបង្កើតទំនាក់ទំនងតាមរយៈការផ្គត់ផ្គង់ឥណទាន និងការដាក់ប្រាក់បញ្ញើ ប៉ុន្តែទំនាក់ទំនងនេះនៅពុំសូវមានលក្ខណៈសកម្មនៅឡើយ។ កន្លងមកធនាគារជាតិនៃកម្ពុជាបានយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងការអភិវឌ្ឍទីផ្សារនេះ តាមរយៈការបង្កើតមូលបត្រអាចជួញដូរបាន (NCD) ការដាក់ឱ្យដំណើរការនូវ

ប្រតិបត្តិការផ្តល់សន្ទនីយភាពជាប្រាក់រៀលដោយមានការធានា (LPCO) និងការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធអនឡាញត្រេដឹង (online trading plateform) ដើម្បីសម្រួលដល់ការទិញ-លក់ NCDs ក៏ដូចជាការចូលរួមប្រតិបត្តិការ LPCO ។ ទោះជាយ៉ាងណា ការអភិវឌ្ឍទីផ្សារអន្តរធនាគារនិងរូបិយវត្ថុទាមទារការអភិវឌ្ឍបន្តទៀតដើម្បីជំរុញឱ្យមានទីផ្សារបន្ទាប់ (Secondary Market) ជាពិសេសសម្រាប់មូលបត្រអាចជួញដូរបានជារូបិយវត្ថុជាតិ។

ទន្ទឹមនេះ ការអភិវឌ្ឍទីផ្សារអន្តរធនាគារនិងរូបិយវត្ថុក៏ពឹងផ្អែកផងដែរទៅលើការអភិវឌ្ឍឧបករណ៍បំណុលរយៈពេលខ្លីផ្សេងទៀត ជាពិសេស ប័ណ្ណរតនាគារ។ ប័ណ្ណរតនាគារត្រូវបានចេញផ្សាយលើកដំបូងនៅឆ្នាំ២០០៣ និងបញ្ឈប់ទៅវិញនៅឆ្នាំ២០០៦។ ជាមួយគ្នានេះដែរ រាជរដ្ឋាភិបាលបាននិងកំពុងសិក្សាលើលទ្ធភាពក្នុងការបង្កើតប័ណ្ណរតនាគារជាប្រាក់រៀល ដើម្បីគ្រប់គ្រងលំហូរសាច់ប្រាក់ និងផ្តល់ហិរញ្ញប្បទានដល់ឱនភាពថវិការដ្ឋ។

សរុបមក រដ្ឋាភិបាលនិងធនាគារជាតិនៃកម្ពុជាគួរអនុវត្តវិធានការអភិវឌ្ឍឧបករណ៍បំណុលជាប្រាក់រៀលឱ្យកាន់តែមានភាពទាក់ទាញ ដើម្បីផ្តល់ជម្រើសដល់ការរក្សាទុកនូវទ្រព្យសកម្មជារូបិយវត្ថុជាតិឱ្យកាន់តែសម្បូរបែប ក្នុងខណៈដែលពេលបច្ចុប្បន្ន ប្រាក់ដុល្លារគឺជាជម្រើសចម្បងរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងសាធារណជន។

**គ. ទីផ្សារមូលបត្រ ៖** ទីផ្សារមូលបត្រត្រូវបានបង្កើតឡើងកាលពីចុងឆ្នាំ២០១២ កន្លងទៅ ហើយបច្ចុប្បន្នមានមូលបត្រសាជីវកម្មចំនួន ៥ កំពុងត្រូវបានជួញដូរ។ បើទោះបីជាការជួញដូរនៅមានកម្រិតទាបនៅឡើយ ការបង្កើតទីផ្សារមូលបត្រគឺជាមូលដ្ឋានដ៏មានសារសំខាន់ ក្នុងការអភិវឌ្ឍឧបករណ៍ហិរញ្ញវត្ថុនានាជាប្រាក់រៀល។ ការកំណត់តម្លៃមូលបត្រជាប្រាក់រៀល បានបង្ហាញពីការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលក្នុងការអភិវឌ្ឍទីផ្សារមូលបត្រជារូបិយវត្ថុជាតិ។

យោងទៅតាមលក្ខខណ្ឌដែលមានលក្ខណៈអំណោយផលរបស់សេដ្ឋកិច្ច រាជរដ្ឋាភិបាលគួរចេញផ្សាយសញ្ញាប័ណ្ណរដ្ឋចារឹកជារូបិយវត្ថុជាតិដើម្បីផ្តល់ហិរញ្ញប្បទានចំពោះគម្រោងវិនិយោគរយៈពេលវែងរបស់រាជរដ្ឋាភិបាល។ នៅពេលដែលធនធានហិរញ្ញវត្ថុរបស់វិស័យឯកជនកាន់តែមានការកើនឡើង រដ្ឋាភិបាលគួរពិចារណាជាអាទិភាពលើការស្វែងរកកម្ចីមូលនិធិរយៈពេលវែងពីប្រភពទុនក្នុងស្រុក។ ការខ្ចីនេះអាចនឹងរួមចំណែកកាត់បន្ថយសមាមាត្រនៃបំណុលបរទេសនៅក្នុងបំណុលសាធារណៈសរុប និងកាត់បន្ថយហានិភ័យនៃការប្រែប្រួលអត្រាប្តូរប្រាក់ផងដែរ។

### ៣.៥.៦. ការអភិវឌ្ឍប្រព័ន្ធទូទាត់

ប្រព័ន្ធទូទាត់គឺជាផ្នែកស្នូលនៃហេដ្ឋារចនាសម្ព័ន្ធហិរញ្ញវត្ថុ។ ការអភិវឌ្ឍប្រព័ន្ធនេះនឹងជួយសម្រួលដល់ប្រតិបត្តិការទូទាត់ប្រកបដោយភាពងាយស្រួល សុវត្ថិភាព ឆាប់រហ័ស និងចំណាយកាន់តែតិច។ បច្ចុប្បន្ននេះ ការទូទាត់ភាគច្រើនត្រូវបានធ្វើឡើងជាប្រាក់ដុល្លារទាំងក្នុងប្រព័ន្ធធនាគារនិងហិញ្ញវត្ថុ ទាំងក្នុងវិស័យសេដ្ឋកិច្ចរូបវន្ត។ គោលនយោបាយអភិវឌ្ឍន៍ប្រព័ន្ធទូទាត់ នឹងត្រូវអនុវត្តដោយប្រុងប្រយ័ត្នផ្អែកលើមូលដ្ឋានអាទិភាពនៃការជំរុញកំណើនសេដ្ឋកិច្ច និងរក្សាស្ថិរ-ភាពហិរញ្ញវត្ថុ។ កន្លងមក ធនាគារជាតិនៃកម្ពុជាបានបង្កើតប្រព័ន្ធសម្រាប់សេវាទូទាត់រហ័ស (Fast Payment) ដើម្បីសម្រួលដល់ការទូទាត់ជាប្រាក់រៀល ជាមួយតម្លៃទាបសមរម្យ ឆាប់រហ័ស និងប្រសិទ្ធភាព។ ការសិកបញ្ចូលវិធានការលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលជាលំដាប់ ស្របតាមតម្រូវការទីផ្សារគឺជាការចាំបាច់បំផុត។ ក្នុងទិសដៅនេះ ធនាគារជាតិនៃកម្ពុជាគួរបន្តលើកកម្ពស់ការត្រួតពិនិត្យ ក្របខ័ណ្ឌច្បាប់ សមត្ថភាពគ្រប់គ្រងរបស់ស្ថាប័ន ដែលអំណោយផលដល់ដំណើរការទូទាត់ជាប្រាក់រៀល និងរក្សាស្ថិរភាពហិរញ្ញវត្ថុ។ ទន្ទឹមនេះ ធនាគារជាតិនៃកម្ពុជាគួរបង្កើនប្រសិទ្ធភាព និងបន្ទាបចំណាយលើការទូទាត់ជាប្រាក់រៀល ដែលធ្វើឱ្យការទូទាត់ជាប្រាក់រៀលមានភាពទាក់ទាញជាងរូបិយប័ណ្ណ។ អាជ្ញាធរនឹងពង្រឹងគោលនយោបាយក្នុងការទូទាត់ដោយមិនប្រើសាច់ប្រាក់ ដែលនឹងជួយគ្រប់គ្រងចរាចរណ៍រូបិយវត្ថុអន្តរជាតិ និងលើកទឹកចិត្តឱ្យធ្វើការទូទាត់ជារូបិយវត្ថុជាតិ។ ក្នុងស្មារតីនេះ ធនាគារជាតិនៃកម្ពុជាគួរបន្តធ្វើទំនើបកម្មប្រព័ន្ធទូទាត់ ដោយធ្វើការអភិវឌ្ឍប្រព័ន្ធទូទាត់រាយអេឡិចត្រូនិចជាប្រាក់រៀល ដែលអំណោយផលដល់ប្រតិបត្តិការទូទាត់ជាប្រាក់រៀលឱ្យកាន់តែទូលំទូលាយ។

មួយវិញទៀត សេវានិងឧបករណ៍ទូទាត់ជាប្រាក់រៀលក្នុងទម្រង់ជាមូលប្បទានបត្រ អេ-ឡិចត្រូនិច និងទម្រង់ផ្សេងៗទៀតគួរត្រូវអភិវឌ្ឍឱ្យកាន់តែសម្បូរបែប ដើម្បីអាចឆ្លើយតបនឹងតម្រូវការរបស់ទីផ្សារ ក្នុងពេលដែលតម្រូវការប្រាក់រៀលសម្រាប់ប្រើប្រាស់ជាមធ្យោបាយទូទាត់កាន់តែច្រើនឡើង។ បន្ថែមពីនេះ បន្ទាប់ពីកំឡុងពេលមួយដែលប្រាក់រៀលត្រូវបានទទួលស្គាល់កាន់តែខ្លាំងជាឯកតាកំណត់និងតាំងថ្លៃ ក្រដាសប្រាក់រៀលដែលមានតម្លៃចារឹកខ្ពស់នឹងចាំបាច់ត្រូវការដើម្បីជួយសម្រួលដល់ប្រតិបត្តិការដែលមានតម្លៃធំៗនៅក្នុងវិស័យពាណិជ្ជកម្ម និងហិរញ្ញវត្ថុ។ បច្ចុប្បន្ននេះ ក្រដាសប្រាក់រៀលចារឹកតម្លៃខ្ពស់បំផុតគឺ ១០០ ០០០រៀល ស្មើនឹងប្រមាណ ២៥ ដុល្លារអាមេរិក។ ក្រដាសប្រាក់រៀលដែលចារឹកក្នុងតម្លៃខ្ពស់គួរត្រូវបានពិចារណាបោះផ្សាយ នៅពេលដែលសេដ្ឋកិច្ចមានការរីកចម្រើនគ្រប់គ្រាន់ក្នុងទិដ្ឋភាពនៃការបង្កើនការប្រើប្រាស់រូបិយវត្ថុជាតិ។

នៅក្នុងរយៈពេលវែង ធនាគារជាតិនៃកម្ពុជាគួរពិចារណាលើការតម្រូវឱ្យមានការទូទាត់តាមរយៈប្រព័ន្ធធនាគារចំពោះទឹកប្រាក់ធំចាប់ពីកម្រិតសមស្របណាមួយ ដើម្បីកាត់បន្ថយការទូទាត់សាច់ប្រាក់និងបង្កើនការទាក់ទាញក្នុងការទូទាត់ធំជាប្រាក់រៀល។ ស្របពេលជាមួយគ្នានេះ ការសិក្សាដោយហ្មត់ចត់លើការធ្វើកំណែទម្រង់រូបិយវត្ថុ (Monetary Reform) គួរត្រូវបានធ្វើឡើងដើម្បីវិភាគពីគុណសម្បត្តិ និងគុណវិបត្តិនៃការធ្វើកំណែទម្រង់នេះដល់ការពង្រីកការប្រើប្រាស់រូបិយវត្ថុជាតិគឺប្រាក់រៀល។

### ៣.៥.៧. ការលើកកម្ពស់ការយល់ដឹង និងការចូលរួម

សាធារណជន គឺជាមូលដ្ឋានគន្លឹះនៃយុទ្ធសាស្ត្រលើកកម្ពស់ការប្រើប្រាស់រូបិយវត្ថុជាតិ ដោយសារគោលនយោបាយនេះអាចមានឥទ្ធិពលដល់ផលប្រយោជន៍សេដ្ឋកិច្ច ព្រមទាំងទម្លាប់នៃការរស់នៅរបស់ពួកគេ។ តាមរយៈការសិក្សាកន្លងមកបានបង្ហាញថាការប្រើប្រាស់ប្រាក់ដុល្លារបានចាក់ឫសគល់យ៉ាងជ្រៅក្នុងផ្នត់គំនិតរបស់ប្រជាជន ហើយការប្រើប្រាស់ និងការគិតចំនួនទឹកប្រាក់នានាជាប្រាក់ដុល្លារសម្រាប់ប្រជាជនមួយចំនួនបានក្លាយជាទម្លាប់ទៅហើយ។ ហេតុដូចនេះ ការសម្រេចនូវគោលនយោបាយលើកកម្ពស់ការប្រើប្រាស់រូបិយវត្ថុជាតិ មិនអាចធ្វើឡើងដោយអត្តនោម័ត និងដោយគ្មានការចូលរួមពីសំណាក់សាធារណជនឡើយ។ នៅក្នុងទិសដៅនេះ សាធារណជនចាំបាច់ត្រូវយល់ដឹងឱ្យកាន់តែច្បាស់ពីអត្ថប្រយោជន៍នៃរូបិយវត្ថុជាតិ និងគោលនយោបាយរបស់រាជរដ្ឋាភិបាល ព្រមទាំងរួមចំណែកនៅក្នុងដំណើរការនៃការលើកកម្ពស់ការប្រើប្រាស់រូបិយវត្ថុជាតិ។ ការបញ្ជ្រាបនិងលើកទឹកចិត្តឱ្យចូលរួមនេះអាចនឹងធ្វើឡើងតាមរយៈរូបភាពនានា ជាពិសេស ប្រព័ន្ធផ្សព្វផ្សាយនានា ការរៀបចំសិក្ខាសាលា ឬវេទិការពិភាក្សារវាងអាជ្ញាធរនិងសាធារណជន និងនៅក្នុងប្រព័ន្ធអប់រំជាដើម។

### ៣.៥.៨. កិច្ចសហប្រតិបត្តិការដើម្បីអនុវត្តវិធានការប្រកបដោយប្រសិទ្ធភាព

ការតាមដានត្រួតពិនិត្យ និងការធានានូវភាពត្រឹមត្រូវនិងហ្មត់ចត់នៃការអនុវត្តនូវវិធានការដែលបានដាក់ចេញ មានសារសំខាន់ណាស់ ជាពិសេស ចំពោះការសម្រេចជោគជ័យនៅលើផែនការដែលបានគ្រោងទុក។ លើសពីនេះ ការជំរុញការប្រើប្រាស់រូបិយវត្ថុជាតិជាការងារពាក់ព័ន្ធនឹងផលប្រយោជន៍ជាតិនិងមោទនភាពជាតិ ដែលទាមទារជាចាំបាច់នូវកិច្ចខិតខំប្រឹងប្រែងរួមគ្នាក្នុងការរៀបចំគោលនយោបាយនិងវិធានការឱ្យមានសង្គតិភាព។ នៅក្នុងការសម្របសម្រួលវិធានការនិងសកម្មភាពទាំងឡាយ រវាងគ្រប់វិស័យពាក់ព័ន្ធផ្សេងៗក្នុងការសម្រេចគោលដៅនយោបាយរួមនេះ ចាំបាច់ត្រូវបង្កើតក្របខ័ណ្ឌសម្រាប់សម្រួលកិច្ចសហប្រតិបត្តិការរវាងភាគីពាក់ព័ន្ធទាំងឡាយ។

ទន្ទឹមនឹងនេះ ក្របខ័ណ្ឌនៃកិច្ចសហប្រតិបត្តិការត្រូវក្រសោបភាគីពាក់ព័ន្ធសំខាន់ៗក្នុងជួរស្ថាប័នរដ្ឋនិងអាជ្ញាធរតំបន់ ដើម្បីគាំទ្រដំណើរការតាមដានជាប្រចាំនូវរាល់បញ្ហាដែលពាក់ព័ន្ធនឹងការអនុវត្តគោលនយោបាយ និងវិធានការដែលបានដាក់ចេញ។ អាជ្ញាធរពាក់ព័ន្ធសំខាន់ៗក្នុងការអនុវត្តយុទ្ធសាស្ត្រនេះរួមមាន ធនាគារជាតិនៃកម្ពុជា, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ក្រសួងពាណិជ្ជកម្ម, ក្រសួងទេសចរណ៍, ក្រសួងមហាផ្ទៃ, ក្រសួងព័ត៌មាន, ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និង ក្រសួងស្ថាប័នទាំងក្នុងវិស័យសាធារណៈ និងវិស័យឯកជនពាក់ព័ន្ធនានា។

នៅក្នុងកម្រិតគោលនយោបាយ គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ គឺជាផ្នែកទទួលខុសត្រូវ និងផ្តល់ការណែនាំគោលនយោបាយ ព្រមទាំងការសម្របសម្រួលចាំបាច់សម្រាប់ការអនុវត្តប្រកបដោយប្រសិទ្ធភាព។ នៅក្នុងកម្រិតបច្ចេកទេស ក្រុមការងារអន្តរក្រសួងមួយគួរត្រូវបានបង្កើតឡើងសម្រាប់ជំរុញនិងតាមដានការអនុវត្តវិធានការដែលបានដាក់ចេញ ព្រមទាំងលើកសំណើដើម្បីពង្រឹង កែលម្អ ឬដាក់ចេញវិធានការចាំបាច់បន្ថែមទៀត។

### ៣.៥.៩. គោលនយោបាយគាំទ្រនានា

ដើម្បីរក្សានិរន្តរភាពនៃការលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល គោលនយោបាយគាំទ្រនានាគួរតែត្រូវអនុវត្ត។ ជាក់ស្តែង ប្រទេសមួយចំនួនដែលខ្វះខាតនូវគោលនយោបាយគាំទ្រទាំងនេះ បានជួបប្រទះនឹងការកើនឡើងវិញនូវកម្រិតដុល្លារូបនីយកម្ម បន្ទាប់ពីបានកាត់បន្ថយកម្រិតដុល្លារូបនីយកម្មបានមួយរយៈពេល។

គោលនយោបាយគាំទ្រទាំងនេះ អាចគ្របដណ្តប់ទៅលើការងារជាច្រើនដូចជា៖

- អាជ្ញាធរគួរបញ្ជ្រាបស្មារតីលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលនៅក្នុងរាល់ក្របខ័ណ្ឌច្បាប់ និងបទប្បញ្ញត្តិផ្សេងៗ ដូចជាការប្រើប្រាស់ឯកតារៀលសម្រាប់កំណត់បៀវត្សរអប្បបរមាជាដើម។
- ការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងការប្រឆាំងអំពើពុករលួយ នឹងចូលរួមចំណែកដោយប្រយោលដល់ការពង្រឹងការប្រើប្រាស់រូបិយវត្ថុជាតិ ដោយសារសកម្មភាពទាំងនោះអាចជាបរិយាកាសអំណោយផលដល់ការប្រើប្រាស់រូបិយប័ណ្ណអន្តរជាតិ។
- ប្រែក្លាយពីវិស័យក្រៅផ្លូវការទៅជាវិស័យផ្លូវការជាលំដាប់ ដូចជា ការចុះបញ្ជីក្រុមហ៊ុន និងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុជាដើម ដើម្បីឱ្យសកម្មភាពសេដ្ឋកិច្ចទាំងនេះ អាចទទួលផលកាន់តែច្រើនពីការប្រើប្រាស់ប្រាក់រៀល ក៏ដូចជាជំរុញតម្រូវការប្រាក់រៀល ដូចជាការអាចទទួលបានឥណទានជាប្រាក់រៀលក្នុងអត្រាសមរម្យ និងការប្រើប្រាស់សេវាកម្មទូទាត់ជាប្រាក់រៀល ។

- វិនិយោគិននិងសហគ្រិននានា គួរត្រូវបានលើកទឹកចិត្តឱ្យធ្វើប្រតិបត្តិការរបស់ខ្លួនជាប្រាក់រៀលជាលំដាប់ ក្នុងកំឡុងពេលបាននិងកំពុងដំណើរការអាជីវកម្មរបស់ខ្លួន និងជាពិសេសនៅមុនពេលចាប់ផ្តើមធ្វើប្រតិបត្តិការអាជីវកម្ម។
- គួរមានការសិក្សាបង្កើតគម្រោងសន្សំខ្នាតតូចៗ ជាប្រាក់រៀល។ គម្រោងនេះអាចផ្តួចផ្តើមដោយកិច្ចសហការរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍នានា ហើយបន្ទាប់មកឱ្យវិស័យឯកជនចូលរួមដើម្បីរក្សានិរន្តរភាពនៃគម្រោង។ គម្រោងនេះគួរពង្រីកជាលំដាប់នៅទូទាំងប្រទេស។
- នៅក្នុងរយៈពេលមធ្យមនិងវែង ការសិក្សាលើការដាក់គំហិតលើការកាន់កាប់រូបិយប័ណ្ណនៅក្នុងប្រតិបត្តិការដោយភ្នាក់ងារ ដែលមិនមានប្រតិបត្តិការជាមួយភ្នាក់ងារនៅក្រៅប្រទេសនឹងត្រូវចាប់ផ្តើម និងត្រូវធានាឱ្យបានថាវិធានការនេះនឹងមិនប៉ះពាល់ដល់លំហូរចេញនៃមូលធនទេ។
- ផ្តល់ការលើកទឹកចិត្តចំពោះគ្រឹះស្ថានធនាគារនិងក្រុមហ៊ុននានា ក្នុងការបើកគណនីជាប្រាក់រៀលជូននិយោជិក។ ការងារនេះទាមទារឱ្យមានកិច្ចសហការរវាងរាជរដ្ឋាភិបាល ក៏ដូចជាធនាគារជាតិនៃកម្ពុជា ដើម្បីឱ្យនិយោជិកអាចប្រើប្រាស់សេវាធនាគារក្នុងប្រតិបត្តិការសេដ្ឋកិច្ចនានា និងបន្ថយសាច់ប្រាក់ ដែលបច្ចុប្បន្នអាចមានចំនួនច្រើនចំពោះការទូទាត់ប្រាក់ធំៗ។

## ៣.៦. សារសំខាន់នៃប្រាក់រៀល

### ក. មោទនភាពជាតិ និងសាមគ្គីភាពជាតិ

បណ្តាប្រទេសនីមួយៗតែងតែមាននូវរូបិយវត្ថុជាតិរបស់ខ្លួន ដែលតំណាងឱ្យអត្តសញ្ញាណជាតិមាតុភូមិ។ វត្តមាននៃរូបិយវត្ថុជាតិគឺជាមោទនភាពសម្រាប់ប្រជាជនទាំងអស់នៅក្នុងប្រទេស។ ដោយសារតែរូបិយវត្ថុត្រូវបានប្រើប្រាស់ជាទូទៅនៅក្នុងសង្គមមួយ ចរាចរណ៍ក្រដាសប្រាក់ក្នុងចំណោមប្រជាជនគឺជាមធ្យោបាយដ៏មានប្រសិទ្ធភាពក្នុងការរំលឹក និងបង្កើនចំណេះដឹងដល់សាធារណជនអំពីព្រឹត្តិការណ៍ប្រវត្តិសាស្ត្រនិងវប្បធម៌ ក៏ដូចជា ស្ថានភាពសង្គមនិងសេដ្ឋកិច្ចរបស់ប្រទេសមួយផងដែរ។ ចំពោះកម្ពុជា ក្រដាសប្រាក់រៀលអាចរំលឹកដល់ប្រជាជនពីវីរបុរសដែលមានកិត្តិនាមជាប្រវត្តិសាស្ត្រ (ឧទាហរណ៍ដូចជា ព្រះមហាក្សត្រ) ឬ ប្រាង្គប្រាសាទនានាដែលត្រូវបានបង្ហាញនៅលើក្រដាសប្រាក់។

ជាមួយការប្រើប្រាស់រូបិយវត្ថុជាតិ យើងអាចចូលរួមក្នុងការរក្សា ពង្រីកនិងចែករំលែកនូវចំណេះដឹងពីប្រវត្តិសាស្ត្រ វប្បធម៌ និងអត្តសញ្ញាណជាតិដល់អ្នកជំនាន់ក្រោយ ហើយនឹងអាចពង្រឹងនូវស្មារតីបង្រួបបង្រួមជាតិ ក្នុងនាមជាប្រជាជននៅក្នុងសង្គមនិងជាតិតែមួយ។

**ខ. រក្សាស្ថិរភាពថ្លៃ**

យោងទៅតាមទ្រឹស្តី ស្ថិរភាពថ្លៃត្រូវបានរក្សាតាមរយៈការគ្រប់គ្រងការផ្គត់ផ្គង់រូបិយវត្ថុនៅក្នុងសេដ្ឋកិច្ច។ ដូចគ្នាទៅនឹងទំនិញដែរ ការផ្គត់ផ្គង់រូបិយវត្ថុលើសទៅក្នុងចរាចរណ៍សេដ្ឋកិច្ចនឹងធ្វើឱ្យតម្លៃរូបិយវត្ថុថយចុះ ហើយក៏នឹងធ្វើឱ្យសម្ពាធអតិផរណាកើនឡើងផងដែរ។ ផ្ទុយទៅវិញ ប្រសិនបើការផ្គត់ផ្គង់ទាបជាងតម្រូវការនោះ នឹងធ្វើឱ្យរូបិយវត្ថុឡើងថ្លៃខ្ពស់ជាងកម្រិតសមស្រប ដែលអាចធ្វើឱ្យមានបរិត្តផរណា (ការធ្លាក់ថ្លៃទំនិញ)។ ដូច្នេះ ទាំងការផ្គត់ផ្គង់លើស និងខ្វះ សុទ្ធតែមានផលប៉ះពាល់ដល់តម្លៃទំនិញនៅលើទីផ្សារ។

អតិផរណាខ្ពស់ នឹងផ្តល់ផលប៉ះពាល់អវិជ្ជមានដល់ជីវភាពរស់នៅរបស់ប្រជាជននៅពេលដែលទំនិញកាន់តែឡើងថ្លៃ ខណៈដែលបរិត្តផរណាក៏នឹងមានផលអវិជ្ជមានចំពោះវិនិយោគិនផងដែរ ដោយសារតែផលចំណេញពីការវិនិយោគមានការថយចុះ។ ប្រសិនបើការផ្គត់ផ្គង់រូបិយវត្ថុត្រូវបានធ្វើឡើងមិនសមស្របនោះ អស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចអាចនឹងកើតឡើងបាន។

ដើម្បីរក្សាស្ថិរភាពថ្លៃ ធនាគារជាតិនៃកម្ពុជាចាំបាច់ត្រូវគ្រប់គ្រងការផ្គត់ផ្គង់រូបិយវត្ថុ ដោយស្រូបយក ឬចាក់បញ្ចូលរូបិយវត្ថុទៅក្នុងទីផ្សារ។ នៅកម្ពុជា ដោយសារតែដុល្លារូបនីយកម្មមានកម្រិតខ្ពស់ ហើយរូបិយប័ណ្ណបរទេសមានការចរាចរដោយសេរី (ប្រការនេះ លើសពីដែនសមត្ថកិច្ចរបស់ធនាគារជាតិនៃកម្ពុជា) ធនាគារជាតិនៃកម្ពុជាមិនអាចកំណត់ពីចំនួនប្រាក់ដុល្លារអាមេរិកនិងរូបិយប័ណ្ណផ្សេងៗទៀតដែលកំពុងចរាចរនៅក្នុងសេដ្ឋកិច្ចបានទេ។ ដូច្នេះប្រសិទ្ធភាពនៃការអនុវត្តគោលនយោបាយរូបិយវត្ថុដើម្បីរក្សាស្ថិរភាពថ្លៃ ក៏ត្រូវបានដាក់កំហិតផងដែរ។

**គ. កាត់បន្ថយចំណាយប្រតិបត្តិការ**

ការប្រើប្រាស់រូបិយប័ណ្ណលើសពីមួយនៅក្នុងសេដ្ឋកិច្ច បានបង្កើនចំណាយប្រតិបត្តិការទាំងពេលវេលា និង ប្រាក់កាស។ ទំនិញនិងសេវាអាចនឹងត្រូវបានគិតថ្លៃជារូបិយប័ណ្ណផ្សេងគ្នាអាស្រ័យលើ៖ ក),ប្រភពដើមនៃទំនិញ និងសេវាទាំងនោះ (ផលិតក្នុងស្រុកឬនាំចូល) ខ),ទំហំប្រតិបត្តិការ (តូចឬធំ) និង គ),ប្រភេទទីផ្សារ (ប្រពៃណីឬទំនើប) ។ ដោយសារតែប្រាក់រៀលនិងដុល្លារអាមេរិកចរាចរទន្ទឹមគ្នា អ្នកទិញអាចប្រឈមនឹងការខាតបង់អាស្រ័យលើក្រដាសប្រាក់ដែលគេកាន់កាប់។ អត្រាប្តូរប្រាក់ត្រូវបានកំណត់ដោយអ្នកលក់ ដោយមិនផ្អែកលើអត្រាទីផ្សារ និងមានទំនោរផ្តល់ផលប្រយោជន៍ដល់អ្នកលក់។ ឧទាហរណ៍ អ្នកទិញត្រូវប្តូរប្រាក់មុននឹងទូទាត់ឱ្យអ្នកលក់ដែលធ្វើឱ្យខាតទាំងពេលវេលា និងថវិកា។ សូម្បីតែអ្នកលក់ក៏អាចខាតបង់ទាំងពេលវេលា និងប្រាក់កាសផងដែរ នៅពេលដែលពួកគេកំណត់តម្លៃទំនិញជារូបិយប័ណ្ណផ្សេងៗគ្នា។ អ្នកលក់

ប្រឈមនឹងផលលំបាកចំពោះការធ្វើកិច្ចបញ្ជីការគណនេយ្យ នៅពេលដែលរូបិយវត្ថុ ឬរូបិយប័ណ្ណដែលគេទទួលបានខុសពីរូបិយវត្ថុ ឬរូបិយប័ណ្ណដែលគេប្រើប្រាស់ក្នុងប្រព័ន្ធគណនេយ្យ។ ទាំងអ្នកលក់ និងអ្នកទិញ សុទ្ធតែប្រឈមមុខនឹងហានិភ័យអត្រាប្តូរប្រាក់ នៅពេលដែលតម្លៃនៃរូបិយវត្ថុ ឬរូបិយប័ណ្ណបរទេសមានការប្រែប្រួលម្តងៗ។

ការប្រើប្រាស់រូបិយវត្ថុជាតិតែមួយ ចំពោះការទូទាត់គ្រប់ប្រតិបត្តិការនានានៅក្នុងសេដ្ឋកិច្ចជាតិ នឹងអាចជួយកាត់បន្ថយចំណាយជាច្រើនសម្រាប់អ្នកលក់និងអ្នកទិញ។ លើសពីនេះ ការប្រើប្រាស់រូបិយវត្ថុជាតិនឹងអាចជួយបង្កើនប្រតិបត្តិការសេដ្ឋកិច្ចឱ្យកាន់តែច្រើន ដោយសារភាពងាយស្រួលឆាប់រហ័ស និងមានប្រសិទ្ធភាព នៅពេលដែលភាគី ទាំងពីរមិនចាំបាច់ត្រូវខ្វល់ខ្វាយពីប្រភេទរូបិយវត្ថុ ឬរូបិយប័ណ្ណក្នុងការទូទាត់ ឬគម្លាតអត្រាប្តូរប្រាក់។

**ឃ. ជំរុញពាណិជ្ជកម្ម**

នាពេលបច្ចុប្បន្ន កម្ពុជាពឹងផ្អែកមួយភាគធំទៅលើការនាំចេញ និងទេសចរណ៍ ដើម្បីជំរុញកំណើនសេដ្ឋកិច្ចរបស់ខ្លួន។ ប្រសិនបើកម្ពុជាប្រើប្រាស់តែប្រាក់រៀល នោះធនាគារជាតិនៃកម្ពុជាអាចជំរុញការនាំចេញ ដោយធ្វើឱ្យភាពប្រកួតប្រជែងថ្លៃកើនឡើងតាមរយៈការបន្ថយតម្លៃរូបិយ-វត្ថុ។ ដូច្នេះ ការបន្ថយតម្លៃរូបិយវត្ថុនឹងធ្វើឱ្យការនាំចេញកើនឡើង។

អំណាចនៃការបន្ថយតម្លៃរូបិយវត្ថុ គឺជាសមត្ថកិច្ចរបស់ធនាគារជាតិនៃកម្ពុជាដោយមានការប្រឹក្សាជាមួយរាជរដ្ឋាភិបាល និងភាគីពាក់តែងគោលនយោបាយពាក់ព័ន្ធនានា ។ ឧទាហរណ៍ ដើម្បីផលិតបានអាវ១ គេត្រូវចំណាយប្រាក់ចំនួន៤.០០០រៀល។ ប្រសិនបើអត្រាការប្រាក់ស្ថិតនៅក្នុងកម្រិត៤.០០០រៀល ក្នុង១ដុល្លារអាមេរិក នោះដៃគូពាណិជ្ជកម្មនឹងត្រូវការប្រាក់១ដុល្លារអាមេ-រិក ដើម្បីទិញអាវនេះ ។ ប៉ុន្តែ ប្រសិនបើប្រាក់រៀលធ្លាក់ដល់៤.២០០រៀល ក្នុង១ដុល្លារអាមេរិក អ្នកនាំចេញនឹងត្រូវការប្រាក់ត្រឹមតែ ០,៨៨ដុល្លារអាមេរិកប៉ុណ្ណោះដើម្បីទិញអាវនេះ ដែលមានន័យថាអាវនេះមានតម្លៃទាបជាងមុននៅលើទីផ្សារអន្តរជាតិ។ នៅពេលតម្លៃទំនិញកាន់តែទាប អ្នកប្រើប្រាស់អាចទិញកាន់តែច្រើន ដែលនាំឱ្យតម្រូវការកាន់តែកើនឡើង ក៏ដូចជាការបង្កើតការងារកាន់តែច្រើននៅក្នុងប្រទេសផងដែរ។ ដោយសារធាតុចូលនៅក្នុងផលិតកម្ម ដូចជាវត្ថុធាតុដើមនិងប្រាក់ឈ្នួល ត្រូវបានគិតជាប្រាក់ដុល្លារអាមេរិក ការធ្លាក់ថ្លៃនៃប្រាក់រៀលនឹងមិនមានឥទ្ធិពលលើថ្លៃទំនិញនាំចេញនោះទេដែលនឹងបណ្តាលឱ្យកម្ពុជាបាត់បង់ឱកាសក្នុងការជំរុញការនាំចេញ និងកំណើនសេដ្ឋកិច្ចថែមទៀតផង។ ស្រដៀងគ្នានេះដែរ ការធ្លាក់ចុះនៃតម្លៃរូបិយវត្ថុអាចទាក់ទាញ

ភ្ញៀវទេសចរណ៍ច្រើនជាងមុនមកកាន់ប្រទេសកម្ពុជា និងធ្វើឱ្យពួកគេចំណាយកាន់តែច្រើន ដោយសារទំនិញកម្ពុជាមានតម្លៃទាបជាងមុនបើគិតជារូបិយប័ណ្ណ។

**ខ. ជំរុញវិនិយោគ និងការបង្កើតការងារ**

ធនាគារកណ្តាលជាច្រើន ដូចជាធនាគារកណ្តាលអាមេរិក បានកែតម្រូវអត្រាការប្រាក់គោលរបស់ខ្លួន ដើម្បីជំរុញការវិនិយោគក្នុងស្រុកនិងបង្កើតការងារបន្ថែម។ កម្រិតអត្រាការប្រាក់គោលដែលកំណត់ដោយធនាគារកណ្តាល មានឥទ្ធិពលលើថ្លៃដើមនៃមូលនិធិវិនិយោគរបស់គ្រឹះស្ថានធនាគារ ហើយជាលទ្ធផល ក៏នាំឱ្យមានការប្រែប្រួលដល់អត្រាការប្រាក់ដែលគ្រឹះស្ថានធនាគារកំណត់លើកម្ចីទៅកាន់វិនិយោគិននិងអង្គភាពគ្រួសារផងដែរ។ នៅពេលដែលធនាគារកណ្តាលបន្ទាបការប្រាក់គោល វាជាសញ្ញាណដល់គ្រឹះស្ថានធនាគារក្នុងការកាត់បន្ថយអត្រាការប្រាក់កម្ចីដែលនឹងត្រូវធ្វើឱ្យកម្ចីមានតម្រូវការខ្ពស់ជាងមុនសម្រាប់វិនិយោគិននិងអង្គភាពគ្រួសារ។

ធនាគារកណ្តាលក៏អាចដំឡើងអត្រាការប្រាក់គោលផងដែរ ប្រសិនបើមានសញ្ញាណថាបរិមាណកម្ចីមានកំណើនខ្ពស់ហួសហេតុនៅក្នុងសេដ្ឋកិច្ច ជាពិសេសនៅក្នុងវិស័យណាមួយ (ឧទាហរណ៍ វិស័យសំណង់ និងអចលនទ្រព្យ) ដើម្បីជៀសវាងការឡើងថ្លៃជ្រុល។ ទ្រឹស្តីនេះអាចអនុវត្តបានតែក្នុងសេដ្ឋកិច្ចដែលប្រើប្រាស់រូបិយវត្ថុក្នុងស្រុកទាំងស្រុងឬមួយភាគធំប៉ុណ្ណោះ។ នៅក្នុងករណីប្រទេសកម្ពុជា ប្រាក់បញ្ញើនិងឥណទានប្រមាណ៩០% គឺជាប្រាក់ដុល្លារអាមេរិក។ ផ្ទុយទៅវិញ ធនាគារជាតិនៃកម្ពុជាអាចផ្តល់តែកម្ចីជាប្រាក់រៀលប៉ុណ្ណោះដល់គ្រឹះស្ថានធនាគារ។ នេះមានន័យថា អត្រាការប្រាក់គោលដែលធនាគារជាតិនៃកម្ពុជាកំណត់ នឹងមិនមានឥទ្ធិពលលើថ្លៃដើមនៃមូលនិធិវិនិយោគរបស់គ្រឹះស្ថានធនាគារនោះទេ។ ចំណុចនេះគឺជាគុណវិបត្តិដ៏ធំមួយសម្រាប់ប្រជាជនកម្ពុជានិងវិនិយោគិន ដែលកំពុងប្រឈមនឹងការចំណាយថ្លៃដើមវិនិយោគខ្ពស់ ដោយសារធនាគារកណ្តាលមិនអាចមានឥទ្ធិពលលើអត្រាការប្រាក់កម្ចីរបស់គ្រឹះស្ថានធនាគារ។

**គ. លើកកម្ពស់ហេដ្ឋារចនាសម្ព័ន្ធនិងសុខុមាលភាពសង្គម**

ការប្រើប្រាស់រូបិយវត្ថុជាតិកាន់តែច្រើន អាចអនុញ្ញាតឱ្យរាជរដ្ឋាភិបាលធ្វើការគ្រប់គ្រងថវិកាបានកាន់តែប្រសើរដើម្បីបំពេញតម្រូវការនៅក្នុងការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ និងសុខុមាលភាពសង្គម។ បច្ចុប្បន្ន រាជរដ្ឋាភិបាលធ្វើការប្រមូលចំណូលជាប្រាក់រៀល ប៉ុន្តែចំណាយលើហេដ្ឋារចនាសម្ព័ន្ធ និងគម្រោងអភិវឌ្ឍន៍ផ្សេងទៀតភាគច្រើនជាប្រាក់ដុល្លារអាមេរិក។ នៅក្នុងរយៈកាលវែង ភាពមិនស៊ីគ្នានៃចំណូលជារូបិយវត្ថុនិងចំណាយជារូបិយប័ណ្ណនេះ នឹងជាឧបសគ្គមួយសម្រាប់រាជរដ្ឋាភិបាលក្នុងការគ្រប់គ្រងថវិកាជាតិឱ្យមានប្រសិទ្ធភាព។

នៅប្រទេសកម្ពុជា ការអនុវត្តគោលនយោបាយសារពើពន្ធត្រូវបានកម្រិតដោយសារបរិមាណប្រាក់ដុល្លារអាមេរិកដ៏ច្រើនសន្ធឹកសន្ធាប់នៅក្នុងសេដ្ឋកិច្ច។ មូលហេតុនេះបានដាក់កំហិតដល់ការខ្ចីរបស់រាជរដ្ឋាភិបាលពីសាធារណជន ក្នុងការអភិវឌ្ឍគម្រោងអភិវឌ្ឍន៍អាទិភាពនានា ដូចជាការសាងសង់ផ្លូវថ្នល់ ស្ពាន សាលារៀន មន្ទីរពេទ្យ និងកម្មវិធីកាត់បន្ថយភាពក្រីក្រផ្សេងៗទៀត។ ប្រសិនបើរាជរដ្ឋាភិបាលមានបំណងបង្កើនចំណាយសាធារណៈ រាជរដ្ឋាភិបាលមិនអាចខ្ចីប្រាក់ជារូបិយប័ណ្ណពីទីផ្សារក្នុងស្រុកនោះទេ ដោយសារតម្រូវការប្រាក់ដុល្លារអាមេរិកនឹងកើនឡើង ដែលនឹងរឹតតែបង្កើនកម្រិតដុល្លារូបនីយកម្មនៅកម្ពុជា។

ការលើកកម្ពស់នូវការប្រើប្រាស់ប្រាក់រៀល នឹងរួមចំណែកយ៉ាងសំខាន់ក្នុងការធ្វើឱ្យថវិការដ្ឋមានភាពប្រសើរឡើង និងជួយកាត់បន្ថយការដាក់កំហិតលើគោលនយោបាយសារពើពន្ធ។ បើសិនជានៅលើទីផ្សារមានការប្រើប្រាស់ប្រាក់រៀលកាន់តែច្រើន រាជរដ្ឋាភិបាលអាចពិចារណាចេញផ្សាយមូលបត្រចារឹកជាប្រាក់រៀល ដើម្បីគ្រប់គ្រងថវិកា ក៏ដូចជាផ្តល់ហិរញ្ញប្បទាន លើគម្រោងអភិវឌ្ឍន៍នានា។ ដូចនេះ លទ្ធភាពក្នុងការគ្រប់គ្រងហិរញ្ញប្បទានក្នុងស្រុក នឹងអាចជួយឱ្យកម្ពុជាកាត់បន្ថយការពឹងផ្អែកមួយភាគធំទៅលើបំណុលបរទេស។

**ឆ. ជំរុញបរិយាប័ន្នហិរញ្ញវត្ថុ**

តាមរយៈការសិក្សារបស់ធនាគារពិភពលោក ការអភិវឌ្ឍសេដ្ឋកិច្ចមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនឹងការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ។ ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុមិនត្រឹមតែមានសារៈសំខាន់ចំពោះឧស្សាហកម្មធនាគារប៉ុណ្ណោះទេ ថែមទាំងជំរុញបរិយាប័ន្នហិរញ្ញវត្ថុ ដែលអនុញ្ញាតឱ្យប្រជាជនកម្ពុជាទទួលបានសេវាហិរញ្ញវត្ថុផ្លូវការនិងមានតម្លៃសមរម្យ។

ប្រជាជនកម្ពុជាប្រមាណ ៧០% កំពុងរស់នៅតាមតំបន់ជនបទ ហើយភាគច្រើនប្រកបរបរកសិកម្មដើម្បីចិញ្ចឹមជីវិត។ ប្រាក់រៀលបានដើរតួនាទីយ៉ាងសំខាន់នៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃរបស់ពួកគេ ដូចជាសម្រាប់ការជួញដូរនិងការចំណាយនានា។ បច្ចុប្បន្ន គ្រឹះស្ថានហិរញ្ញវត្ថុដែលធ្វើប្រតិបត្តិការនៅតាមជនបទ ទទួលបានមូលនិធិពីវិនិយោគិនបរទេសនិងពីអ្នកដាក់ប្រាក់បញ្ញើជាប្រាក់ដុល្លារអាមេរិក។ ដើម្បីបំពេញតម្រូវការប្រាក់រៀល គ្រឹះស្ថានហិរញ្ញវត្ថុទាំងនេះតែងតែប្តូរប្រាក់ដុល្លារអាមេរិកទៅជាប្រាក់រៀល ដែលអាចធ្វើឱ្យពួកគេប្រឈមនឹងហានិភ័យប្តូរប្រាក់។ ដើម្បីបង្ការហានិភ័យនេះ គ្រឹះស្ថានហិរញ្ញវត្ថុទាំងនេះបានកំណត់អត្រាការប្រាក់កម្ចីជាប្រាក់រៀលខ្ពស់ ដែលជាកត្តាធ្វើឱ្យកម្ចីជាប្រាក់រៀលមានអត្រាការប្រាក់ខ្ពស់ជាងកម្ចីជាប្រាក់ដុល្លារអាមេរិក។

ជាទូទៅ ចំពោះប្រជាជននៅតាមទីក្រុង ប្រតិបត្តិការធំៗភាគច្រើនធ្វើឡើងជាប្រាក់ដុល្លារអាមេរិក ដែលអនុញ្ញាតឱ្យពួកគេជៀសផុតពីហានិភ័យប្តូរប្រាក់បានមួយកម្រិតធំ។ ផ្ទុយទៅវិញ ប្រជាជនដែលរស់នៅតាមជនបទភាគច្រើន និងប្រជាជនដែលមានចំណូលជារូបិយវត្ថុ ត្រូវប្រឈមនឹងអត្រាការប្រាក់កម្ចីខ្ពស់ ហើយប្រជាជនមួយចំនួនយល់ឃើញថានេះឧបសគ្គចម្បងសម្រាប់ពួកគេក្នុងការប្រើប្រាស់សេវាហិរញ្ញវត្ថុ ដូចជាការខ្ចីប្រាក់ពីធនាគារ ហើយមួយចំនួននៅតែបន្តខ្ចីពីអ្នកចងការប្រាក់ក្រៅផ្លូវការដែលទាញយកផលប្រយោជន៍ច្រើនហួសហេតុ។ ការជំរុញការប្រើប្រាស់ប្រាក់រៀលតាមរយៈការសន្សំនិងសកម្មភាពសេដ្ឋកិច្ចផ្សេងៗ នឹងអាចជួយកាត់បន្ថយចំណាយនៃកម្ចីជាប្រាក់រៀល និងជំរុញបរិយាប័ន្នហិរញ្ញវត្ថុនៅកម្ពុជា។

### ៥. គរពូនទុនបម្រុងអន្តរជាតិ

សម្រាប់ប្រទេសដែលរូបិយវត្ថុជាតិត្រូវបានប្រើប្រាស់ជាទូទៅ រូបិយប័ណ្ណដែលហូរចូលមកក្នុងប្រទេសត្រូវប្តូរទៅជារូបិយវត្ថុជាតិ មុននឹងយកមកប្រើប្រាស់នៅក្នុងសកម្មភាពសេដ្ឋកិច្ចផ្សេងៗនៅក្នុងស្រុក។ ធនាគារកណ្តាលមានតួនាទីស្រូបយករូបិយប័ណ្ណទាំងនេះតាមរយៈការប្តូរជារូបិយ-វត្ថុជាតិ។ ប្រសិនបើមានតែប្រាក់រៀលដែលត្រូវបានប្រើប្រាស់ក្នុងសកម្មភាពសេដ្ឋកិច្ច កម្ពុជាអាចបង្កើនទុនបម្រុងអន្តរជាតិបានយ៉ាងសន្ធឹកសន្ធាប់ តាមរយៈការគរពូនអតិរេកនៃលំហូររូបិយប័ណ្ណបរទេសមកក្នុងសេដ្ឋកិច្ចកម្ពុជារៀងរាល់ឆ្នាំ។

ការគរពូនទុនបម្រុងអន្តរជាតិបង្កើនទ្រព្យសម្បត្តិជាតិ លើកកម្ពស់ជំនឿទុកចិត្តមកលើរូបិយវត្ថុជាតិ និងពង្រឹងមូលដ្ឋានរឹងមាំសម្រាប់ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច។ ទុនបម្រុងអន្តរជាតិដែលមានបរិមាណមួយខ្ពស់សមស្រប ក៏នឹងអនុញ្ញាតឱ្យធនាគារកណ្តាលមានលទ្ធភាពខ្ពស់ក្នុងការធ្វើការអន្តរាគមន៍លើទីផ្សារប្តូរប្រាក់ដើម្បីកាត់បន្ថយការប្រែប្រួលខ្លាំងនៃតម្លៃរូបិយវត្ថុជាតិ ក្នុងគោលបំណងសម្រេចបាននូវសមិទ្ធផលដែលគាំទ្រកំណើនសេដ្ឋកិច្ច។ បន្ថែមពីនេះ កំណើនទុនបម្រុងអន្តរជាតិក៏នឹងបង្កើន ការវិនិយោគ ស្របតាមគោលការណ៍លំដាប់អាទិភាព ១), សុវត្ថិភាព៖ វិនិ-យោគលើឧបករណ៍ហិរញ្ញវត្ថុដែលមានសុវត្ថិភាព នៅក្នុងគោលបំណងចម្បងដើម្បីរក្សាដើមទុន ២), កម្រិតសន្ទនីយភាពខ្ពស់៖ រក្សាជាឧបករណ៍ដែលមានសន្ទនីយភាពខ្ពស់ សម្រាប់យកទៅប្រើប្រាស់បានភ្លាមៗទៅតាមតម្រូវការរបស់ប្រព័ន្ធធនាគារ ៣), បង្កើនចំណូល៖ វិនិយោគនៅលើឧបករណ៍ហិរញ្ញវត្ថុនានាដើម្បីទទួលបានប្រាក់ចំណេញ សំដៅគរពូនទុកបម្រុងអន្តរជាតិបន្ថែម។ ប្រាក់ចំណេញនេះនឹងត្រូវបែងចែករវាងធនាគារកណ្តាល (សម្រាប់ចំណាយប្រតិបត្តិការ) និងរាជ-រដ្ឋាភិបាល ដែលអាចត្រូវយកទៅប្រើប្រាស់ក្នុងការវិនិយោគដើម្បីការអភិវឌ្ឍនៅក្នុងប្រទេសវិញ។

ដូច្នេះ ថ្វីត្បិតតែមានបរិមាណសមស្របចំពោះទំហំសេដ្ឋកិច្ច ទុនបម្រុងអន្តរជាតិនៅកម្ពុជា អាចនឹងត្រូវបានគរពូនបន្ថែមយ៉ាងច្រើនថែមទៀត នៅពេលដែលប្រាក់រៀលត្រូវបានប្រើប្រាស់កាន់តែទូលំទូលាយនៅក្នុងប្រទេស។

**ឈ. ចំណូលពីការបោះពុម្ពក្រដាសប្រាក់**

ចំណូលពីការបោះពុម្ពក្រដាសប្រាក់ គឺជាភាពខុសគ្នារវាងតម្លៃចារឹករបស់ក្រដាសប្រាក់និងចំណាយនៅក្នុងផលិតកម្ម ។ ឧទាហរណ៍ ក្រដាសប្រាក់ ១០.០០០ រៀល ត្រូវការថ្លៃចំណាយបោះពុម្ពចំនួន ៣០០ រៀល។ នៅពេលដែលក្រដាសប្រាក់ប្រភេទ ១០.០០០ រៀលនេះត្រូវបានបោះផ្សាយនិងដាក់ឱ្យចរាចរដល់សាធារណជន ក្រដាសប្រាក់នេះអាចទិញទំនិញក្នុងតម្លៃ ១០.០០០ រៀល។ ដូច្នេះចំណូលពីការបោះពុម្ពផ្សាយស្មើនឹង ៩.៧០០ រៀល។ កំណើនតម្រូវការប្រាក់រៀលនឹងធ្វើឱ្យធនាគារជាតិនៃកម្ពុជាអាចបោះផ្សាយក្រដាសប្រាក់រៀលកាន់តែច្រើន។ ជាលទ្ធផល នៅពេលដែលក្រដាសប្រាក់រៀលត្រូវបានបោះពុម្ពកាន់តែច្រើន កម្ពុជានឹងអាចទទួលបានចំណូលពីការបោះពុម្ពកាន់តែច្រើនដែរ។

នៅក្នុងសេដ្ឋកិច្ចដែលមានដុល្លារូបនីយកម្មខ្ពស់ បានដាក់កំហិតលើលទ្ធភាពរបស់ប្រទេសក្នុងការទទួលបានចំណូលពីការបោះពុម្ពនេះ ដោយសារសាធារណជនកាន់កាប់រូបិយប័ណ្ណជាចម្បង ជំនួសឱ្យរូបិយវត្ថុជាតិ។ ដូច្នេះ ការកាន់កាប់រូបិយប័ណ្ណមានន័យស្មើនឹងការខាតបង់ចំណូលពីការបោះពុម្ព។ លើសពីនេះ ការកាន់កាប់នេះក៏ធ្វើឱ្យកម្ពុជាបាត់ឱកាសទទួលបាននូវចំណូលការប្រាក់ពីការដាក់ប្រាក់បញ្ញើនិងការវិនិយោគរូបិយប័ណ្ណ (ដែលត្រូវស្រូបយកដោយធនាគារកណ្តាលក្នុងករណីគ្មានដុល្លារូបនីយកម្ម) នៅក្នុងទីផ្សារហិរញ្ញវត្ថុអន្តរជាតិ។

តាមរយៈការបោះពុម្ពក្រដាសប្រាក់រៀលកាន់តែច្រើន រាជរដ្ឋាភិបាលនឹងទទួលបានមូលនិធិក្នុងនាមជាអ្នកខ្ចីពីសេដ្ឋកិច្ចដោយមិនមានការប្រាក់ ដើម្បីយកទៅធ្វើការវិនិយោគក្នុងសេដ្ឋកិច្ច ឬបង្កើនចំណាយ សំដៅអភិវឌ្ឍវិស័យអាទិភាពនានា។

**ញ. បង្ការការក្លែងក្រដាសប្រាក់**

ដោយសារសេដ្ឋកិច្ចកម្ពុជាប្រើប្រាស់ក្រដាសប្រាក់ជាមូលដ្ឋាន ជាពិសេសការប្រើប្រាស់ប្រាក់ដុល្លារអាមេរិកយ៉ាងទូលំទូលាយ កម្ពុជាអាចជាគោលដៅនៃការហូរចូលក្រដាសប្រាក់ដុល្លារក្លែងក្លាយ ដោយសារតែសាធារណជនមិនសូវមានការយល់ដឹងច្បាស់ពីរូបិយប័ណ្ណបរទេស និងមិនអាចបែងចែករវាងក្រដាសប្រាក់ពិតនិងក្លែងក្លាយ ដូចជាតាមរយៈរូបភាពនិងលក្ខណៈនៃក្រដាសប្រាក់រូបិយប័ណ្ណបរទេស។ ក្នុងបរិការណ៍នេះ ការលើកទឹកចិត្តឱ្យមានការប្រើប្រាស់ប្រាក់

រៀលកាន់តែទូលំទូលាយ មានសារសំខាន់ណាស់ក្នុងការទប់ស្កាត់ការចរាចររូបិយប័ណ្ណក្លែងក្លាយនៅប្រទេសកម្ពុជា ហើយក៏រួមចំណែកកាត់បន្ថយកម្រិតដុល្លារូបនីយកម្មបន្តិចម្តងៗផងដែរ។

ការប្រើប្រាស់រូបិយវត្ថុជាតិដែលប្រជាជនស្គាល់ច្បាស់ នឹងអាចជួយកាត់បន្ថយនិងបង្ការការក្លែងក្រដាសប្រាក់រូបិយប័ណ្ណបរទេសដោយសារតែរូបិយប័ណ្ណទាំងនេះ នឹងហូរចូលទៅក្នុងសេដ្ឋកិច្ចតាមរយៈប្រព័ន្ធធនាគារ។

## ៣.៧. ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ

### ៣.៧.១. ការវិភាគលើចំណុចខ្លាំង

ធនាគារជាតិនៃកម្ពុជា បានដើរតួយ៉ាងសំខាន់ក្នុងនាមជាអាជ្ញាធរដឹកនាំគោលនយោបាយរូបិយវត្ថុជាតិ ដោយរក្សាបានស្ថិរភាពថ្លៃ និងអតិផរណា ព្រមទាំងជំរុញកំណើនសេដ្ឋកិច្ចជាតិជាលំដាប់។ ខាងក្រោមនេះ គឺជាចំណុចខ្លាំងរបស់ធនាគារជាតិនៃកម្ពុជា នៅក្នុងការអនុវត្តការងារនិងការបង្កើនការប្រើប្រាស់ប្រាក់រៀលនាពេលកន្លងមក៖

១. ធនាគារជាតិនៃកម្ពុជា មានធនធានមនុស្ស និងបុគ្គលិកជំនាញដែលមានសមត្ថភាព និងបទពិសោធន៍ជាច្រើនឆ្នាំនៅក្នុងការអនុវត្តការងារ ជាពិសេសគោលនយោបាយរូបិយវត្ថុ។

២. នាពេលកន្លងមក ធនាគារជាតិនៃកម្ពុជាបានអនុវត្តគោលនយោបាយរូបិយវត្ថុដែលមានលក្ខណៈទន់ភ្លន់ ដែលរួមមាន ការរក្សាស្ថិរភាពអត្រាការប្រាក់ និងអត្រាប្តូរប្រាក់មិនឱ្យមានការប្រែប្រួលខ្លាំង ព្រមជាមួយនឹងការកំណត់អត្រាប្រាក់បម្រុងកាតព្វកិច្ចរបស់ធនាគារពាណិជ្ជជាប្រាក់រៀលទាបជាងរូបិយប័ណ្ណបរទេស ដែលជំរុញឱ្យស្ថាប័នធនាគារពាណិជ្ជខិតខំបង្កើននូវប្រតិបត្តិការសេវាកម្មរបស់ខ្លួនជារូបិយវត្ថុជាតិ។

៣. យុទ្ធសាស្ត្រលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល បានអនុញ្ញាតឱ្យធនាគារជាតិនៃកម្ពុជាអនុវត្តគោលនយោបាយរូបិយវត្ថុរបស់ខ្លួនបានប្រសើរជាងមុន ដោយសារការកើនឡើងនៃបរិមាណតម្រូវការប្រាក់រៀលនៅក្នុងប្រព័ន្ធធនាគារ។

### ៣.៧.២. ការវិភាគលើចំណុចខ្សោយ

ក្រៅពីចំណុចខ្លាំង ខាងក្រោមនេះគឺជាចំណុចខ្សោយមួយចំនួនរបស់ប្រធានបទ៖

១. យុទ្ធសាស្ត្រលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល មិនទាន់បានដាក់ជាយុទ្ធសាស្ត្រថ្នាក់ជាតិ ដែលជាបញ្ហារាំងស្ទះមិនអាចឱ្យការអនុវត្តយុទ្ធសាស្ត្រនេះបានទូលំទូលាយ និងទទួលបានប្រសិទ្ធភាពខ្ពស់។

២. នាពេលបច្ចុប្បន្ននេះ រាល់ជំនួយ និងការវិនិយោគជារូបិយប័ណ្ណពីបរទេសគឺមិនបានតម្រូវឱ្យធ្វើការប្តូរទៅជារូបិយវត្ថុជាតិនោះទេ។ បញ្ហានេះបានបណ្តាលឱ្យបរិមាណនៃរូបិយប័ណ្ណបរទេសជាពិសេសប្រាក់ដុល្លារអាមេរិក មានការកើនឡើងជាលំដាប់ស្របពេលដែលសេដ្ឋកិច្ចជាតិកំពុងមានការអភិវឌ្ឍយ៉ាងឆាប់រហ័ស។

# សេចក្តីសន្និដ្ឋាន និងអនុសាសន៍

## ១. សេចក្តីសន្និដ្ឋាន

តាមរយៈការសិក្សាស្រាវជ្រាវ និងចុះកម្មសិក្សារបស់ក្រុមយើងខ្ញុំកន្លងមកនេះ យើងខ្ញុំសូមធ្វើការសន្និដ្ឋានថា ដុល្លារូបនីយកម្មនៅកម្ពុជា គឺជាបញ្ហាដែលកើតឡើងតាមរយៈផលវិបាកនៃដំណើរការប្រវត្តិសាស្ត្រ និងមិនមែនជាលទ្ធផលនៃជម្រើសគោលនយោបាយរបស់រាជរដ្ឋាភិបាលឡើយ។ បើទោះបីជា វត្តមាននៃដុល្លារូបនីយកម្មបានជួយឱ្យសេដ្ឋកិច្ចកម្ពុជារក្សាបាននូវកំណើនមួយខ្ពស់អស់រយៈពេលជាងមួយទសវត្សយ៉ាងណាក្តី យើងសង្កេតឃើញថាកម្រិតនៃចរាចរប្រាក់ដុល្លារហាក់នៅមិនទាន់មានភាពថមថយនៅឡើយទេ។ មានការកត់សម្គាល់ឃើញថា ភាពពេញនិយមនៃការប្រើប្រាស់ប្រាក់ដុល្លារ បានចាក់ឫសគល់យ៉ាងជ្រៅទៅក្នុងផ្នត់គំនិតរបស់ប្រជាជនតាមរយៈភាពងាយស្រួលនិងទំនុកចិត្តនៅក្នុងការទូទាត់ជាមធ្យោបាយដោះដូរប្រចាំថ្ងៃ។

យោងទៅតាមនិន្នាការនៃការប្រើប្រាស់រូបិយប័ណ្ណនាពេលបច្ចុប្បន្ន បានបង្ហាញឱ្យឃើញថា កម្រិតដុល្លារូបនីយកម្មនឹងបន្តមានការកើនឡើងថែមទៀត ដែលអាចឈានដល់ដុល្លារូបនីយកម្មទាំងស្រុងនាពេលអនាគត ប្រសិនបើមិនមានការខិតខំយ៉ាងមោះមុតនិងច្បាស់លាស់នៅក្នុងការពង្រឹងការប្រើប្រាស់រូបិយវត្ថុជាតិទេនោះ។

ធនាគារជាតិនៃកម្ពុជាបានដើរតួនាទីយ៉ាងសំខាន់នៅក្នុងការដឹកនាំ និងអនុវត្តយុទ្ធសាស្ត្រលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលនាពេលកន្លងមក និងបច្ចុប្បន្ន។ ក្នុងនាមជាអាជ្ញាធររូបិយវត្ថុរបស់ប្រទេស ធនាគារជាតិនៃកម្ពុជាបានខិតខំអនុវត្តគោលនយោបាយរូបិយវត្ថុ និងអភិវឌ្ឍន៍ឧបករណ៍គោលនយោបាយរូបិយវត្ថុរបស់ខ្លួនបន្ថែមទៀត ដើម្បីរួមចំណែកក្នុងការរក្សាស្ថិរភាពថ្លៃនិងជំរុញកំណើនសេដ្ឋកិច្ចនៅក្នុងក្របខ័ណ្ឌនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា។ ដោយសារដុល្លារូបនីយកម្មមានវត្តមាននៅក្នុងសេដ្ឋកិច្ចកម្ពុជាអស់រយៈពេលយូរមកហើយ ដូច្នេះនៅក្នុងគោលដៅរយៈពេលខ្លីនិងមធ្យម ការលើកកម្ពស់ការប្រើប្រាស់រូបិយវត្ថុជាតិ គឺជាភារកិច្ចចម្បងរបស់ធនាគារជាតិនៃកម្ពុជា ក៏ដូចជាស្ថាប័នពាក់ព័ន្ធដទៃទៀត។ ក្នុងគោលដៅនេះធនាគារជាតិនៃកម្ពុជាបានព្យាយាមបង្កើនទំនុកចិត្តរបស់ប្រជាជន និងភ្នាក់ងារសេដ្ឋកិច្ចមកលើប្រាក់រៀលតាមរយៈការអនុវត្តគោលនយោបាយរូបិយវត្ថុប្រកបដោយភាពទន់ភ្លន់ និងប្រុងប្រយ័ត្ននិងរក្សាស្ថិរភាពអត្រាប្តូរប្រាក់រៀលនិងដុល្លារមិនឱ្យមានការប្រែប្រួលខ្លាំង។ លើសពីនេះ ដើម្បីលើកកម្ពស់ការយល់ដឹងនិងការពារផលប្រយោជន៍របស់សារធារណជន ធនាគារជាតិនៃកម្ពុជា

បានបង្កើតការផ្សព្វផ្សាយពីគុណសម្បត្តិ និងសារសំខាន់នៃប្រាក់រៀលតាម រយៈសិក្ខាសាលាឬវេទិការសាធារណៈ ដោយមានការចូលរួមពីសំណាក់វិស័យឯកជន ព្រមទាំងអាជ្ញាធរពាក់ព័ន្ធនានា។

រាជរដ្ឋាភិបាលកម្ពុជា បានកំណត់យ៉ាងច្បាស់នៅក្នុងយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១៦-២០២៥ អំពីគោលដៅលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល សំដៅឈានទៅដល់ការកាត់បន្ថយនូវការពឹងផ្អែកនៃសេដ្ឋកិច្ចទៅលើរូបិយប័ណ្ណ។ ដើម្បីជាការឆ្លើយតបទៅនឹងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងពាណិជ្ជកម្ម ព្រមទាំងបណ្ដាក្រសួងស្ថាប័នពាក់ព័ន្ធដទៃទៀត បានខិតខំ និងបន្តពង្រឹងការងាររបស់ខ្លួននៅក្នុងការបង្កើនការប្រើប្រាស់ប្រាក់រៀល តាមរយៈការតាមដាន និងត្រួតពិនិត្យយ៉ាងហ្មត់ចត់ទៅលើដំណើរការនៃការអនុវត្តយុទ្ធសាស្ត្រខាងលើឱ្យមានប្រសិទ្ធភាព។

យើងអាចសន្និដ្ឋានបានថាធនាគារជាតិនៃកម្ពុជា និងរាជរដ្ឋាភិបាលពិតជាបានខិតខំប្រឹងប្រែង និងយកចិត្តទុកដាក់ក្នុងការជំរុញកំណើនការប្រើប្រាស់រូបិយវត្ថុជាតិនៅក្នុងសេដ្ឋកិច្ចយ៉ាងពិតប្រាកដមែន។ ដូចនេះ ការអនុវត្តយុទ្ធសាស្ត្រលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល អាចនឹងត្រូវចំណាយពេលវេលាយូរ និងត្រូវការ ការចូលរួមយ៉ាងសកម្មពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់ ជាពិសេសមហាជន ដើម្បីរួមគ្នាសម្រេចគោលដៅឱ្យបានជោគជ័យ។

## ២. អនុសាសន៍

យើងខ្ញុំសូមធ្វើការផ្ដល់ជាគំនិតនិងអនុសាសន៍មួយចំនួនក្នុងន័យចូលរួមកែលម្អ និងផ្ដល់ជាទស្សនទានសម្រាប់ការអនុវត្តយុទ្ធសាស្ត្រលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលឱ្យកាន់តែមានភាពប្រសើរឡើង។ យើងខ្ញុំសូមផ្ដល់ជាអនុសាសន៍ដូចខាងក្រោមនេះ៖

១. ធនាគារជាតិនៃកម្ពុជា គួរតែដាក់បញ្ចូលយុទ្ធសាស្ត្រលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលទៅក្នុងយុទ្ធសាស្ត្រថ្នាក់ជាតិ ដើម្បីអនុវត្តយុទ្ធសាស្ត្រនេះឱ្យកាន់តែមានប្រសិទ្ធភាព។

២. រាល់ជំនួយនិងការវិនិយោគពីបរទេស គួរធ្វើការប្តូរប្រាក់ទៅជាប្រាក់រៀល ដើម្បីឱ្យអាជ្ញាធររូបិយវត្ថុអាចមានលទ្ធភាពក្នុងការស្រូបយករូបិយប័ណ្ណបរទេសចូលទៅក្នុងប្រព័ន្ធធនាគារ និងបញ្ចេញរូបិយវត្ថុជាតិចូលទៅក្នុងសេដ្ឋកិច្ចកាន់តែច្រើន។

# ឯកសារយោង

## ឯកសារជាខេមរភាសា


១. សាស្ត្រាចារ្យ ខឹម សារិទ្ធ, សេដ្ឋកិច្ច, ដុល្លារូបនីយកម្ម សម្រាប់ត្រៀមប្រឡងពន្ធដារ, ឆ្នាំ២០១៨

២. សាស្ត្រាចារ្យ ខឹម សារិទ្ធ, ហិរញ្ញវត្ថុ១, ឯកសារបង្រៀន, ឆ្នាំ២០១៧

៣. សាស្ត្រាចារ្យ ឌុន ថាវី, ធនាគារកណ្តាល, ឯកសារបង្រៀន, ឆ្នាំ២០១៨

៤. សាស្ត្រាចារ្យ ឌុន ថាវី, ទស្សនៈស្តីពីរូបិយវត្ថុ, ឯកសារបង្រៀន, ឆ្នាំ២០១៨

៥. ធនាគារជាតិនៃកម្ពុជា, យុទ្ធសាស្ត្រលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល (អត្ថបទពិភាក្សា) បោះពុម្ពលើក ទី១ ឆ្នាំ២០១៧

៦. ធនាគារជាតិនៃកម្ពុជា, ការពង្រឹងការប្រើប្រាស់ប្រាក់រៀលនៅប្រទេសកម្ពុជា, បោះពុម្ពលើក ទី២, ឆ្នាំ២០១៥

៧. ធនាគារជាតិនៃកម្ពុជា, សារសំខាន់នៃប្រាក់រៀលសម្រាប់កម្ពុជា

៨. ធនាគារជាតិនៃកម្ពុជា, របាយការណ៍ប្រចាំឆ្នាំ២០១៦, ឆ្នាំ២០១៧, ឆ្នាំ២០១៨

៩. ធនាគារជាតិនៃកម្ពុជា, ព្រឹត្តិបត្រលេខ៤៩ ប្រចាំត្រីមាសទី៤, ឆ្នាំ២០១៦

១០. ឯកឧត្តម បណ្ឌិតសភាចារ្យ ហង់ ជួន ណារ៉ុន, ម៉ាក្រូសេដ្ឋកិច្ច, ឆ្នាំ២០០៩

១១. ឯកឧត្តម បណ្ឌិតសភាចារ្យ ហង់ ជួន ណារ៉ុន, សេដ្ឋកិច្ចកម្ពុជា មាគ៌ាឆ្ពោះទៅរកអនាគតដ៏ភ្លឺស្វាង, ឆ្នាំ២០១៥

១២. តាល់ ណៃអ៊ីម, Michel Dabadie, ង៉ួន សុខា, ដុល្លារូបនីយកម្មនៅប្រទេសកម្ពុជា, ឆ្នាំ២០០៧

១៣. បណ្ឌិត ហ៊ីង ថូរ៉ាក់ស៊ី, បណ្ឌិត ហ៊ាន សាហ៊ីប, វចនានុក្រមបច្ចេកស័ព្ទសេដ្ឋកិច្ច, ឆ្នាំ២០០៤


## ឯកសារជាភាសាបរទេស


១៤. IMF Working Paper, Macroeconomics Adjustment in a Highly Dollarization Economy: The Case of Cambodia (WP/02/92), May 2002.

១៥. IMF Working Paper, Dollarization in Cambodia: Causes and Policy Implications (WP/11/49), March 2011.

១៦. NBC and JICA Survey, Dollarization in Cambodia, October 20, 2016.

១៧. Daiju Aiba (JICA Research Institute), Finding from NBC-JICA Survey and Policy Implications, 2019.

ឯកសារពីគេហទំព័រ


១៨. https://www.nbc.org.kh/english/

១៩. https://www.imf.org/

២០. https://www.adb.org/sites/default/files/publication/28494/wp19-cambodias-persistent-dollarization.pdf

២១. https://www.investopedia.com/terms/d/dollarization.asp

២២. https://www.khmertimeskh.com/115086/de-dollarisation-needed-for-sustainable-growth-nbc/

# ឧបសម្ព័ន្ធ

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ
និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
លេខ..២៤២..ស.ភ.ន.វ.ស

**សាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**

**សូមគោរពជូន**

**ឯកឧត្តមទេសាភិបាលធនាគារជាតិ នៃ កម្ពុជា**

**កម្មវត្ថុ** ៖ សំណើសុំអនុញ្ញាតឲ្យនិស្សិតចំនួនពីររូបចុះកម្មសិក្សា។

**យោង** ៖ សំណើរបស់សាមីនិស្សិតចុះថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០១៩។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមគោរពជម្រាបជូន **ឯកឧត្តមទេសាភិបាល** មេត្តាជ្រាបថា សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ចបាន និងកំពុងបណ្តុះបណ្តាលនិស្សិតថ្នាក់បរិញ្ញាបត្រ ធនាគារ និងហិរញ្ញវត្ថុ។ អំឡុងពេលសិក្សាឆ្នាំបញ្ចប់ និស្សិតយើងខ្ញុំចំនួនពីររូបដូចមានបញ្ជីរាយនាមជូនភ្ជាប់មកជាមួយនេះត្រូវចុះកម្មសិក្សា និងស្វែងយល់ពីការងារមួយចំនួនដែលទាក់ទងនឹងប្រធានបទស្តីពី "គោលនយោបាយបដិវុល្លារូបនីយកម្មរបស់ធនាគារជាតិ នៃ កម្ពុជា" នៅធនាគារជាតិ នៃ កម្ពុជា ចាប់ពីថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០១៩ ដល់ថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០១៩ ដើម្បីទទួលបានមកវិញនូវបទពិសោធន៍ការងារជាក់ស្តែង និងដើម្បីសរសេររបាយការណ៍កម្មសិក្សា និងការពារបញ្ចប់ការសិក្សារបស់ខ្លួន។

អាស្រ័យដូចបានគោរពជម្រាបជូនខាងលើ សូម **ឯកឧត្តមទេសាភិបាល** ពិនិត្យលទ្ធភាពអនុញ្ញាតឲ្យនិស្សិតយើងខ្ញុំបានចុះកម្មសិក្សាដោយសេចក្តីអនុគ្រោះ។

សូម **ឯកឧត្តមទេសាភិបាល** មេត្តាទទួលនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់ពីខ្ញុំ។

ថ្ងៃសៅរ៍ ១១រោច ខែមាឃ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ មីនា ឆ្នាំ ២០១៩
**ជ.សាកលវិទ្យាធិការ**
**សាកលវិទ្យាធិការរង**

**យិត_សូវួច**

Monivong Blvd, Sangkat Tonle Bassac, Khan Chamkamon, Phnom Penh, Cambodia.
P.O. Box 842, Tel: (855) 23 214 703, Fax: (855)23 214 953, E-mail: rector@rule.edu.kh,website: www.rule.edu.kh

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ

និង វិទ្យាសាស្ត្រសេដ្ឋកិច្ច

# បញ្ជីរាយនាម

## និស្សិតថ្នាក់បរិញ្ញាបត្រធនាគារ និងហិរញ្ញវត្ថុ ឆ្នាំទី៤ ជំនាន់ទី១៣ ក្រុម$B_4A_2$ និង$B_4C_2$

## ឆ្នាំសិក្សា ២០១៨-២០១៩

## ដែលត្រូវចុះកម្មសិក្សានៅ ធនាគារជាតិនៃកម្ពុជា

| ល.រ | គោត្តនាម - នាម | ភេទ | ថ្ងៃខែឆ្នាំកំណើត | លេខទូរស័ព្ទ | ផ្សេងៗ |
|---|---|---|---|---|---|
| ១ | ម៉ៅ សុមុន្នី | ប្រុស | ១០ វិច្ឆិកា ១៩៩៧ | ០៨៩ ៤១៨ ០៤៣ | |
| ២ | រិត ស្រីឡែន | ស្រី | ១៩ ធ្នូ ១៩៩៧ | ០១២ ២៥២ ៤៨០ | |

ថ្ងៃព្រហស្បតិ៍ ៩រោច ខែមាឃ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ ២០១៩

**ប្រធានការិយាល័យស្រាវជ្រាវ**

ញឹក_វុឌ្ឍី

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ០៤៤.០១៩-២១៤ ពក

ថ្ងៃ សុក្រ ៨ រោច ខែផល្គុន ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែមីនា ឆ្នាំ២០១៩

**សូមគោរពជូន**

**លោក អគ្គនាយករងបច្ចេកទេស និងជាប្រធាននាយកដ្ឋានស្រាវជ្រាវសេដ្ឋកិច្ច និងសហប្រតិបត្តិការអន្តរជាតិ**

**លោក ប្រធាននាយកដ្ឋានស្ថិតិ**

**កម្មវត្ថុ** ៖ សំណើសុំការអនុញ្ញាតរៀបចំកម្មវិធីចុះធ្វើកម្មសិក្សា ជូននិស្សិតថ្នាក់បរិញ្ញាបត្រធនាគារ និងហិរញ្ញវត្ថុ ឆ្នាំទី៤ ជំនាន់ទី១៣ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

**យោង** ៖ ចំណាររបស់ ឯកឧត្តម អគ្គលេខាធិការ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៩ ។

តបតាមកម្មវត្ថុនិងយោងខាងលើ ខ្ញុំសូមជម្រាបជូនលោកប្រធានមេត្តាជ្រាបថា នៅថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៩ ឯកឧត្តម អគ្គលេខាធិការ បានឱ្យនាយកដ្ឋានបុគ្គលិក ជួយសម្រួលដល់ការធ្វើកម្មសិក្សាជូននិស្សិតថ្នាក់បរិញ្ញាបត្រធនាគារនិងហិរញ្ញវត្ថុ ឆ្នាំទី៤ ជំនាន់ទី១៣ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ចំនួន ២រូប រួមមាន៖១). លោក មៅ សុមុន្នី ២). កញ្ញា រិត ស្រីឡែន ចុះធ្វើកម្មសិក្សាចំនួន ៥សប្តាហ៍ សម្រាប់វេនព្រឹកដើម្បីសិក្សាស្វែងយល់បន្ថែមលើទ្រឹស្តីដែលបានសិក្សាកន្លងមកនៅសាកលវិទ្យាល័យ អំពីប្រធានបទស្តីពី "គោលនយោបាយបដិជុល្លរូបនីយកម្មរបស់ធនាគារជាតិនៃកម្ពុជា"។

អនុវត្តតាមចំណារណែនាំរបស់ ឯកឧត្តម អគ្គលេខាធិការ ខ្ញុំសូមលោកប្រធានមេត្តាអនុញ្ញាតឱ្យនិស្សិតទាំង ២រូប ខាងលើចុះធ្វើកម្មសិក្សារយៈពេល ៥សប្តាហ៍សម្រាប់វេនព្រឹក ចាប់ពីថ្ងៃទី២៥ ខែមីនា ដល់ថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៩ នៅតាមបណ្តានាយកដ្ឋានដូចខាងក្រោម ៖

១. នាយកដ្ឋានបុគ្គលិក :ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៩ ។
២. នាយកដ្ឋានស្ថិតិ :ថ្ងៃទី២៦-២៩ ខែមីនា ឆ្នាំ២០១៩ ។
៣. នាយកដ្ឋានស្រាវជ្រាវសេដ្ឋកិច្ច និងសហប្រតិបត្តិការអន្តរជាតិ :ថ្ងៃទី១-២៦ ខែមេសា ឆ្នាំ២០១៩។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមលោកប្រធាននាយកដ្ឋាន មេត្តាជ្រាបព័ត៌មាន និងចាត់ចែងតាមការគួរ។

សូម លោកប្រធាននាយកដ្ឋាន មេត្តាទទួលនូវការគោរពរាប់អានអំពីខ្ញុំ ។

**ប្រធាននាយកដ្ឋានបុគ្គលិក**

**ចាត សុធីរៈ**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ០៥៤.០១៩.៣៧៥៣ ល.ប

ថ្ងៃ អង្គារ ១១ កើត ខែ ចេត្រ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែមេសា ឆ្នាំ២០១៩

# លិខិតបញ្ជាក់

## នាយកដ្ឋានបុគ្គលិកនៃធនាគារជាតិនៃកម្ពុជា សូមបញ្ជាក់ថា :

លោក **ម៉ៅ សុមុន្នី** ជានិស្សិតថ្នាក់បរិញ្ញាបត្រ ជំនាន់ទី១៣ ឆ្នាំទី៤ ឯកទេសធនាគារ និង ហិរញ្ញវត្ថុ មកពី **សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច** ពិតជាបានបញ្ចប់កម្មសិក្សានៅធនាគារជាតិនៃកម្ពុជា ចាប់ពីថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៩ ដល់ថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៩ ក្រោមប្រធានបទស្តីពី គោលនយោបាយបដិដុល្លារូបនីយកម្មរបស់ធនាគារជាតិនៃកម្ពុជា តាមបណ្តានាយកដ្ឋានដូចខាងក្រោមពិតប្រាកដមែន ៖

- នាយកដ្ឋានបុគ្គលិក : ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៩។
- នាយកដ្ឋានស្ថិតិ : ថ្ងៃទី២៦-២៩ ខែមីនា ឆ្នាំ២០១៩។
- នាយកដ្ឋានស្រាវជ្រាវសេដ្ឋកិច្ច និងសហប្រតិបត្តិការអន្តរជាតិ : ថ្ងៃទី១-២៦ ខែមេសា ឆ្នាំ២០១៩។

លិខិតបញ្ជាក់នេះ ត្រូវបានចេញឲ្យសាមីខ្លួនដើម្បីយកទៅប្រើប្រាស់តាមលក្ខណៈច្បាប់ដែលអាចប្រើបាន ។

**ប្រធាននាយកដ្ឋានបុគ្គលិក**

ចាត សុទីរៈ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**
លេខ ២៥៨.០១៩.៣៧២ ល.ប

ថ្ងៃអង្គារ ១១កើត ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែមេសា ឆ្នាំ២០១៩

# លិខិតបញ្ជាក់

## នាយកដ្ឋានបុគ្គលិកនៃធនាគារជាតិនៃកម្ពុជា សូមបញ្ជាក់ថា :

កញ្ញា **រិត ស្រីឡែន** ជានិស្សិតថ្នាក់បរិញ្ញាបត្រ ជំនាន់ទី១៣ ឆ្នាំទី៤ ឯកទេសធនាគារ និងហិរញ្ញវត្ថុ មកពី **សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច** ពិតជាបានបញ្ចប់កម្មសិក្សានៅធនាគារជាតិនៃកម្ពុជា ចាប់ពីថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៩ ដល់ថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៩ ក្រោមប្រធានបទស្ដីពី គោលនយោបាយបដិដុល្លារូបនីយកម្មរបស់ធនាគារជាតិនៃកម្ពុជា តាមបណ្ដានាយកដ្ឋានដូចខាងក្រោមពិតប្រាកដមែន ៖

- នាយកដ្ឋានបុគ្គលិក : ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៩។
- នាយកដ្ឋានស្ថិតិ : ថ្ងៃទី២៦-២៩ ខែមីនា ឆ្នាំ២០១៩។
- នាយកដ្ឋានស្រាវជ្រាវសេដ្ឋកិច្ច និងសហប្រតិបត្តិការអន្តរជាតិ : ថ្ងៃទី១-២៦ ខែមេសា ឆ្នាំ២០១៩។

លិខិតបញ្ជាក់នេះ ត្រូវបានចេញឲ្យសាមីខ្លួនដើម្បីយកទៅប្រើប្រាស់តាមលក្ខណៈច្បាប់ដែលអាចប្រើបាន ។

**ប្រធាននាយកដ្ឋានបុគ្គលិក**

**ចាត សុទីរៈ**

ប្រអប់សំបុត្រលេខ ២៥, ផ្លូវលេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

(23)

សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ
និង វិទ្យាសាស្ត្រសេដ្ឋកិច្ច
ការិយាល័យស្រាវជ្រាវ

## របាយការណ៍វាយតម្លៃរបស់សាស្ត្រាចារ្យណែនាំ

**ចំពោះនិស្សិតសរសេរសារណា ឬរបាយការណ៍កម្មសិក្សា និងការពារបញ្ចប់ការសិក្សា**

**ថ្នាក់បរិញ្ញាបត្រ** ធនាគារ និង ហិរញ្ញវត្ថុ **ឆ្នាំទី៤ ជំនាន់ទី** 12 **ក្រុម** BA42 & BC42

**ឆ្នាំសិក្សា ២០១៨ - ២០១៩**

១-គោត្តនាម និងនាម ៖ ១- ម៉ៅ សុខជី ភេទ ប្រុស លេខទូរស័ព្ទ 089 418 043

២- ទិត ស្រីខ្លួន ភេទ ស្រី លេខទូរស័ព្ទ 012 252 480

២-កន្លែងចុះកម្មសិក្សា ឬស្រាវជ្រាវឯកសារ ៖ ធនាគារជាតិ នៃកម្ពុជា

៣-អ្នកទទួលបន្ទុកដឹកនាំនៅកន្លែងចុះស្រាវជ្រាវឯកសារ ឬ កម្មសិក្សា៖

-គោត្តនាម និងនាម ៖ [illegible] ភេទ ប្រុស លេខទូរស័ព្ទ 077 579 007

-មុខងារ ៖ អនុប្រធានការិយាល័យចំណុះចំណូល នៃនាយកដ្ឋានបច្ចេកទេស [illegible]

៤-ការពិចារណានៅកន្លែងចុះស្រាវជ្រាវឯកសារ ឬ កម្មសិក្សា ៖

-ការងាយស្រួល ៖ ទទួលបានការសហការ និងយកចិត្តទុកដាក់ពីសំណាក់មន្ត្រីធនាគារ

-ការលំបាក ៖ គ្មាន

៥-ថ្ងៃ ខែ ឆ្នាំ ម៉ោង និងទីកន្លែង ដែលនិស្សិតបានជួបសាស្ត្រាចារ្យណែនាំ ៖

-ថ្ងៃ 18 កក្កដា 2019 ម៉ោង 9:30-11:00 ទីកន្លែង សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

-ថ្ងៃ 21 សីហា 2019 ម៉ោង 2:30-4:00 ទីកន្លែង ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

-ថ្ងៃ 19 [illegible] 2019 ម៉ោង 2:30-4:00 ទីកន្លែង ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

-ថ្ងៃ 24 [illegible] 2019 ម៉ោង 2:00-3:30 ទីកន្លែង ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

៦-គុណភាពនៃសារណា ឬរបាយការណ៍កម្មសិក្សា ៖

-ខ្លឹមសារ ៖ [illegible]

-ឧបសម្ព័ន្ធ ៖ [illegible]

៧-ការសំរេចចិត្តរបស់សាស្ត្រាចារ្យណែនាំ ៖

សារណា ឬរបាយការណ៍ទទួលស្គាល់ ☑ សារណា ឬរបាយការណ៍បដិសេធ ☐

ថ្ងៃ[illegible] ខែ[illegible] ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ [illegible] ឆ្នាំ ២០១៩

ហត្ថលេខា និងឈ្មោះសាស្ត្រាចារ្យណែនាំ

បណ្ឌិត ហួន ប៉ូលី

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ
និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

## កម្រងសំណួរលើប្រធានបទ៖ ការលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលរបស់ធនាគារជាតិនៃកម្ពុជា

យើងខ្ញុំជានិស្សិតកំពុងសិក្សាថ្នាក់បរិញ្ញាបត្រធនាគារ និងហិរញ្ញវត្ថុ ជំនាន់ទី១២ ឆមាសទី២ ឆ្នាំទី៤ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

ដើម្បីឱ្យការសិក្សាស្រាវជ្រាវលើប្រធានបទ "**ការលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលរបស់ធនាគារជាតិនៃកម្ពុជា**" ទទួលបានទិន្នន័យ ព័ត៌មាន និងឯកសារគ្រប់គ្រាន់ យើងខ្ញុំបានចងក្រងជាកម្រងសំណួរចំនួន២២សំណួរ ដើម្បីសួរទៅកាន់លោក លោកស្រី និងមន្ត្រីដែលកំពុងបម្រើការនៅធនាគារជាតិនៃកម្ពុជា។

យើងខ្ញុំសង្ឃឹមយ៉ាងមុតមាំថា លោក លោកស្រី និងមន្ត្រីរបស់ធនាគារជាតិនៃកម្ពុជា នឹងចូលរួមសហការក្នុងការផ្តល់ព័ត៌មានទាក់ទងទៅនឹងសំណួរតាមរយៈការផ្តល់បទសម្ភាសន៍ និងការផ្តល់ជាឯកសារពាក់ព័ន្ធនានាមកកាន់ក្រុមយើងខ្ញុំ។

យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះលោក លោកស្រី និងមន្ត្រីរបស់ធនាគារជាតិនៃកម្ពុជា ដែលបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការផ្តល់បទសម្ភាសន៍ ព័ត៌មាន ព្រមទាំងការផ្តល់មតិយោបល់ណែនាំផ្សេងៗដើម្បីកែលម្អលទ្ធផលស្រាវជ្រាវនៃប្រធានបទខាងលើឲ្យកាន់តែមានភាពត្រឹមត្រូវ និងល្អប្រសើរ។

## កម្រងសំណួរ

១. តើធនាគារជាតិនៃកម្ពុជាបានបង្កើតឡើងតាំងពីពេលណា? ហើយមានប្រវត្តិយ៉ាងដូចម្តេច?

២. តើធនាគារជាតិនៃកម្ពុជាមានស្នាក់ការកណ្តាលនៅឯណា?

៣. តើធនាគារជាតិនៃកម្ពុជាមានសាខាចំនួនប៉ុន្មាននៅទូទាំងប្រទេសកម្ពុជា? ហើយមានអាស័យដ្ឋាននៅឯណាខ្លះ?

៤. តើធនាគារជាតិនៃកម្ពុជាមានរូបអ្វីជាតំណាង? រូបភាពនោះមានអត្ថន័យយ៉ាងដូចម្តេច?

៥. តើធនាគារជាតិនៃកម្ពុជាមានរចនាសម្ព័ន្ធយ៉ាងដូចម្តេច? (ការគ្រប់គ្រង, នាយកដ្ឋាន, ការិយាល័យ, ចំនួនបុគ្គលិក,...)

៦. តើធនាគារជាតិនៃកម្ពុជាមានទស្សនវិស័យ, ចក្ខុវិស័យ និងបេសកកម្មយ៉ាងដូចម្តេចខ្លះ?

៧. នាពេលបច្ចុប្បន្ននេះតើធនាគារជាតិនៃកម្ពុជាមានតួនាទីសំខាន់ៗអ្វីខ្លះ?

៨. តើធនាគារជាតិនៃកម្ពុជាមានគោលនយោបាយអ្វីខ្លះ ដើម្បីចូលរួមក្នុងការជំរុញកំណើនសេដ្ឋកិច្ចជាតិ?

៩. តើធនាគារជាតិនៃកម្ពុជាធ្វើការផ្គត់ផ្គង់រូបិយវត្ថុយ៉ាងដូចម្តច?

១០. តើអ្វីទៅជាគោលនយោបាយរូបិយវត្ថុ? តើធនាគារជាតិនៃកម្ពុជាអនុវត្តគោលនយោយបាយនេះយ៉ាងដូចម្តេច?

១១. តើដុល្លារូបនីយកម្មគឺជាអ្វី? ហើយវាមានប្រវត្តិយ៉ាងដូចម្តេច?

១២. ហេតុអ្វីបានជាមានដុល្លារូបនីយកម្មនៅកម្ពុជា? ហើយវាមានវត្តមាននៅកម្ពុជាតាំងពីពេលណាមក?

១៣. តើដុល្លារូបនីយកម្មមានគុណសម្បត្តិ និងគុណវិបត្តិអ្វីខ្លះចំពោះប្រទេសកម្ពុជា?

១៤. តើប្រទេសកម្ពុជាទទួលរងឥទ្ធិពលនៃដុល្លារូបនីយកម្មដល់កម្រិតណា? តើធ្ងន់ធ្ងរដែរឬទេ?

១៥. តើស្ថិតិនៃការប្រើប្រាស់ប្រាក់ដុល្លារនៅក្នុងទីផ្សារនៅឆ្នាំ២០១៨ ធៀបទៅនឹងឆ្នាំ២០១៧, ២០១៦, ២០១៥ មានការកើនឡើង ឬក៏ថយចុះ? ក្នុងកម្រិតប៉ុន្មានដែរ?

១៦. តើការប្រើប្រាស់ប្រាក់ដុល្លារមានចំនួនប៉ុន្មានភាគរយ បើប្រៀបធៀបទៅនឹងរូបិយប័ណ្ណនានារួមទាំងប្រាក់រៀលដែលកំពុងចរាចរក្នុងសេដ្ឋកិច្ចកម្ពុជានាពេលបច្ចុប្បន្ន?

១៧. តើធនាគារជាតិនៃកម្ពុជាចាប់ផ្តើមអនុវត្តយុទ្ធសាស្រ្តលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលតាំងពីពេលណាមក?

១៨. តើធនាគារជាតិនៃកម្ពុជាអនុវត្តយុទ្ធសាស្រ្តលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលយ៉ាងដូចម្តេចខ្លះ?

១៩. តើភាគីណាខ្លះដែលពាក់ព័ន្ធក្នុងការចូលរួមអនុវត្តវិធានការនេះ?

២០. តើធនាគារជាតិនៃកម្ពុជាមានវិធានការបែបណាខ្លះ ដើម្បីកាត់បន្ថយការប្រើប្រាស់ប្រាក់ដុល្លារ ក៏ដូចជារូបិយប័ណ្ណបរទេសនៅប្រទេសកម្ពុជា?

២១. តើធនាគារជាតិនៃកម្ពុជាមានវិធានការបែបណាខ្លះ ដើម្បីបង្កើនការប្រើប្រាស់ប្រាក់រៀលនៅក្នុងការទូទាត់គ្រប់ប្រភេទនៅក្នុងប្រទេសកម្ពុជា?

២២. តើប្រាក់រៀលមានសារៈសំខាន់អ្វីខ្លះចំពោះសេដ្ឋកិច្ចកម្ពុជា?

## តារាង ២ - ប្រាក់រៀលធៀបជាមួយរូបិយប័ណ្ណផ្សេងៗ (អត្រាទិញចុងខែ)

| រូបិយប័ណ្ណ | ២០១៦ | ២០១៧ | ២០១៨ | | | | | | | | | | | | បម្រែបម្រួល% |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ធ្នូ | ធ្នូ | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ | ធ្នូ-១៨/ធ្នូ-១៧ |
| អឺរ៉ូ-អឺរ៉ូ (អេសដេអែរ) | ៥.៤១ | ៥.៧៣៥ | ៥.៨៣៣ | ៥.៨២ | ៥.៨១៥ | ៥.៧៩៧ | ៥.៧៦៣ | ៥.៧០៨ | ៥.៦៩៦ | ៥.៧២៧ | ៥.៧២៣ | ៥.៦១២ | ៥.៥៧៦ | ៥.៥៨៨ | -២,៦ |
| **អាស៊ី** | | | | | | | | | | | | | | | |
| ដុល្លារ-អូស្ត្រាលី | ២.៩២១ | ៣.១៤៧ | ៣.២៥២ | ៣.១២៥ | ៣.០៧៤ | ៣.០៤៥ | ៣.០៨៥ | ២.៩៨៥ | ៣.០០៨ | ២.៩៦៤ | ២.៩៤១ | ២.៨៨៤ | ២.៩៥១ | ២.៨៣២ | -១០,០ |
| ដុល្លារ-ហុងកុង | ៥២១ | ៥១៦ | ៥១៤ | ៥១២ | ៥១០ | ៥១៤ | ៥១៩ | ៥១៨ | ៥១៧ | ៥២០ | ៥២២ | ៥១៨ | ៥១៥ | ៥១៣ | -០,៦ |
| យ៉េន-ជប៉ុន | ៣៤,៦៧ | ៣៥,៧៤ | ៣៦,៨៦ | ៣៧,៣០ | ៣៧,៥៧ | ៣៦,៩៤ | ៣៧,៥៣ | ៣៦,៧៩ | ៣៦,៦០ | ៣៦,៨១ | ៣៦,០០ | ៣៥,៨៩ | ៣៥,៥៥ | ៣៦,៤១ | ១,៩ |
| វ៉ុន-កូរ៉េ | ៣,៣៤ | ៣,៧៨ | ៣,៧៥ | ៣,៧១ | ៣,៧៦ | ៣,៧៥ | ៣.៧៨ | ៣,៦៣ | ៣,៦៣ | ៣,៦៦ | ៣,៦៦ | ៣,៥៦ | ៣,៦០ | ៣,៦២ | -៤,២ |
| ដុល្លារ-ញ៉ូស៊ីឡែន | ២.៨១៣ | ២.៨៦៣ | ២.៩៤៣ | ២.៨៥៦ | ២.៨៩១ | ២.៨៥៣ | ២.៨៤៦ | ២.៧៤៦ | ២.៧៧១ | ២.៧២១ | ២.៦៩៩ | ២.៦៦៥ | ២.៧៦៧ | ២.៦៩៦ | -៥,៨ |
| យ័ន់ចិន | ៥៨០ | ៦១៨ | ៦៣៤ | ៦៣៥ | ៦៣៦ | ៦៣៧ | ៦៣៥ | ៦១៣ | ៥៩៦ | ៥៩៧ | ៥៩៣ | ៥៨៣ | ៥៨១ | ៥៨៤ | -៥,៥ |
| ដុល្លារ-តៃវ៉ាន់ | ១២៥ | ១៣៦ | ១៣៨ | ១៣៧ | ១៣៧ | ១៣៦ | ១៣៦ | ១៣៣ | ១៣៣ | ១៣៣ | ១៣៤ | ១៣១ | ១៣១ | ១៣២ | -២,៩ |
| **អាស៊ាន** | | | | | | | | | | | | | | | |
| រូពី-ឥណ្ឌូណេស៊ី | ០,៣០០ | ០,២៩៨ | ០,៣០០ | ០,២៩៣ | ០,២៩១ | ០,២៩០ | ០,២៩១ | ០,២៨២ | ០,២៨២ | ០,២៧៨ | ០,២៧៤ | ០,២៦៧ | ០,២៨ | ០,២៨ | -៧,០ |
| រីងហ្គីត-ម៉ាឡេស៊ី | ៩០១ | ៩៩៤ | ១.០៣៣ | ១.០២២ | ១.០៣៥ | ១.០២៩ | ១.០២២ | ១.០០៥ | ១.០០០ | ៩៩៤ | ៩៨៥ | ៩៧១ | ៩៦៣ | ៩៦៩ | -២,៥ |
| ប៉េសូ-ហ្វីលីពីន | ៨១,១៩ | ៨០,៩៤ | ៧៨,៤១ | ៧៧,១២ | ៧៦,៥៤ | ៧៧,៧១ | ៧៧,៤៤ | ៧៥,៩៣ | ៧៦,៣២ | ៧៦,៣៤ | ៧៥,៤២ | ៧៥,៨៣ | ៧៦,៩៣ | ៧៦,៥៣ | -៥,៤ |
| ដុល្លារ-សាំងហ្គាពួរ | ២.៧៩២ | ៣.០១៧ | ៣.០៦៤ | ៣.០២៧ | ៣.០៥ | ៣.០៤៥ | ៣.០៤៣ | ២.៩៧២ | ២.៩៨៤ | ២.៩៨៥ | ២.៩៨៤ | ២.៩៣១ | ២.៩៤៣ | ២.៩៤២ | -២,៥ |
| បាត-ថៃ | ១១២ | ១២៤ | ១២៨ | ១២៨ | ១២៨ | ១២៨ | ១២៧ | ១២៣ | ១២២ | ១២៥ | ១២៦ | ១២២ | ១២២ | ១២៤ | ០,០ |
| ដុង-វៀតណាម | ០,១៧៨ | ០,១៧៨ | ០,១៧៧ | ០,១៧៦ | ០,១៧៥ | ០,១៧៧ | ០,១៧៩ | ០,១៧៧ | ០,១៧៥ | ០,១៧៥ | ០,១៧៥ | ០,១៧៤ | ០,១៧ | ០,១៧ | -២,២ |
| **អឺរ៉ុប** | | | | | | | | | | | | | | | |
| រ៉ូប៊ី | ៤.២៦៥ | ៤.៨២១ | ៤.៩៧១ | ៤.៩០៣ | ៤.៩១៩ | ៤.៨៨៧ | ៤.៧៥១ | ៤.៧០១ | ៤.៧៥៣ | ៤.៧៦៣ | ៤.៧៥១ | ៤.៦០៦ | ៤.៥៥២ | ៤.៥៥៧ | -៤,៦ |
| **ផ្សេង** | | | | | | | | | | | | | | | |
| ផោន-អង់គ្លេស | ៤.៩៦ | ៥.៤២៦ | ៥.៦៥១ | ៥.៥៧៤ | ៥.៦០៩ | ៥.៥៥២ | ៥.៣១២ | ៥.៣១៤ | ៥.៣៣២ | ៥.៣១២ | ៥.៣៣៨ | ៥.១៦ | ៥.១៥៣ | ៥.០៩៨ | -៦,០ |

*ទិន្នន័យព្យាករណ៍

## តារាង ៣ - ស្ថានភាពរូបិយវត្ថុ

(ប៊ីលានរៀល)

| | ២០១២[ក] | ២០១៣[ក] | ២០១៤[ក] | ២០១៥[ក] | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|---|---|---|---|
| **ទ្រព្យសកម្មបរទេសសុទ្ធ** | **១៨.១៧២** | **២១.២៨៥** | **២៦.៧៤២** | **២៦.៧០៧** | **៣១.៨១៤** | **៤២.៥៧៥** | **៥៤.៤៥៧** |
| ទ្រព្យសកម្មបរទេស | ២៤.៦៣១ | ២៨.៥៤៦ | ៣៤.៩២៨ | ៣៩.៣៥៥ | ៤៧.៥៨២ | ៦០.៨៩៣ | ៧២.៤០៨ |
| ទ្រព្យអកម្មបរទេស | -៦.៤៥៩ | -៧.២៦០ | -៨.១៨៦ | -១២.៦៤៨ | -១៥.៧៦៧ | -១៨.៣១៨ | -១៧.៩៥០ |
| **ទ្រព្យសកម្មក្នុងស្រុកសុទ្ធ** | **១០.៤៣៩** | **១១.៥១១** | **១៥.៨៦៩** | **២២.១៦១** | **២៥.៨០២** | **២៨.៧៤៤** | **៣២.៩៩៩** |
| ឥណទានក្នុងស្រុក | ២១.០៥៦ | ២៤.៨២៧ | ៣១.៨៨៥ | ៣៩.៦៤២ | ៤៨.៣១០ | ៥៥.៨៥៦ | ៦៦.១៥១ |
| ឥណទេយ្យសុទ្ធចំពោះរដ្ឋាភិបាល | -២.៤៨៦ | -២.៧៩៥ | -៤.៣៥៩ | -៦.៤២៩ | -៨.១៤៨ | -១១.០៦៧ | -១៤.១៩៥ |
| ឥណទេយ្យចំពោះរដ្ឋាភិបាល | ២៧០ | ២៧០ | ២៧០ | ២៧០ | ២៧០ | ២៧០ | 0 |
| ប្រាក់បញ្ញើរដ្ឋាភិបាល | -២.៧៥៧ | -៣.០៦៥ | -៤.៦៣០ | -៦.៦៩៩ | -៨.៤១៩ | -១១.៣៣៧ | -១៤.១៩៥ |
| ផ្នែកមិនមែនរដ្ឋាភិបាល | ២៣.៥៤២ | ២៧.៦២២ | ៣៦.២៤៥ | ៤៦.០៧១ | ៥៦.៤៥៩ | ៦៦.៩២៣ | ៨០.៣៤៥ |
| ចំពោះសហគ្រាសរដ្ឋ | ៦ | ១៣ | 0 | 0 | 0 | 0 | ១ |
| ចំពោះផ្នែកឯកជន | ២៣.៥៣៧ | ២៧.៦០៩ | ៣៦.២៤៥ | ៤៦.០៧១ | ៥៦.៤៥៩ | ៦៦.៩២៣ | ៨០.៣៤៥ |
| **ខ្ទង់ផ្សេងៗសុទ្ធ** | **-១០.៦១៧** | **-១៣.៣១៦** | **-១៦.០១៦** | **-១៧.៤៨១** | **-២២.៥០៨** | **-២៧.១១៣** | **-៣៣.១៥១** |
| ប្រាក់បញ្ញើរឹតត្បិត | -៦៥៥ | -៧៧៨ | -៩០២ | -១.០២១ | -១.៣០២ | -១.៦២៤ | -១.៩៨៧ |
| ដើមទុន និងទុនបម្រុង | -១១.៤៩១ | -១២.១១៦ | -១៣.៨១២ | -១៥.៣៧៨ | -១៧.៩០៥ | -២២.៨៦២ | -២៦.៣៣១ |
| ផ្សេងៗ | ១.៥២៩ | -៤២២ | -១.៣០៣ | -១.០៨៣ | -៣.៣០២ | -២.៦២៦ | -៤.៨៣៣ |
| **រូបិយវត្ថុទូទៅ (M2)** | **២៨.៦១១** | **៣២.៧៩៦** | **៤២.៦១២** | **៤៨.៨៦៨** | **៥៧.៦១៧** | **៧១.៣១៩** | **៨៧.៤៥៦** |
| **រូបិយវត្ថុ (M1)** | **៤.០៦៥** | **៤.៩០៦** | **៦.៣៦១** | **៦.៧៨៦** | **៧.២៧៣** | **៩.៤២៨** | **១០.២២៤** |
| រូបិយវត្ថុក្រៅធនាគារ | ៣.៧៧៥ | ៤.៤៨២ | ៥.៦៤៥ | ៥.៩៤២ | ៦.៤៧៣ | ៨.៣០២ | ៩.២២៩ |
| ប្រាក់បញ្ញើចរន្ត | ២៩០ | ៤២៤ | ៧១៥ | ៨៤៥ | ៨០០ | ១.១២៧ | ៩៩៥ |
| **រូបិយវត្ថុផ្សេងៗ** | **២៤.៥៤៦** | **២៧.៨៩០** | **៣៦.២៥១** | **៤២.០៨២** | **៥០.៣៤៤** | **៦១.៨៩០** | **៧៧.២៣៣** |
| ប្រាក់បញ្ញើមានកាលកំណត់និងសន្សំ | ៧៨០ | ៩៤៥ | ១.០៩០ | ១.៥៥០ | ២.៣៨៦ | ២.៦១៥ | ៣.០៥៥ |
| ប្រាក់បញ្ញើជារូបិយប័ណ្ណ | ២៣.៧៦៦ | ២៦.៩៤៥ | ៣៥.១៦១ | ៤០.៥៣២ | ៤៧.៩៥៧ | ៥៩.២៧៥ | ៧៤.១៧៧ |

*ក/.ទិន្នន័យកែសម្រួល*

**ទិន្នន័យព្យាករណ៍*

## តារាង ៤ - ស្ថានភាពរូបិយវត្ថុ

(បម្រែបម្រួលប្រចាំឆ្នាំជាភាគរយ)

| | ២០១២ក | ២០១៣ក | ២០១៤ក | ២០១៥ក | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|---|---|---|---|
| **ទ្រព្យសកម្មបរទេសសុទ្ធ** | **-១,៤** | **១៧,១** | **២៥,៦** | **-០,១** | **១៩,១** | **៣៣,៨** | **២៧,៩** |
| ទ្រព្យសកម្មបរទេស | ១៦,៥ | ១៥,៩ | ២២,៤ | ១២,៧ | ២០,៩ | ២៨,០ | ១៨,៩ |
| ទ្រព្យអកម្មបរទេស | ១៣៧,២ | ១២,៤ | ១២,៨ | ៥៤,៥ | ២៤,៧ | ១៦,២ | -២,០ |
| **ទ្រព្យសកម្មក្នុងស្រុកសុទ្ធ** | **១០០,២** | **១០,៣** | **៣៧,៩** | **៣៩,៦** | **១៦,៤** | **១១,៤** | **១៤,៨** |
| **ឥណទានក្នុងស្រុក** | **៣៦,៥** | **១៧,៩** | **២៨,៤** | **២៤,៣** | **២១,៩** | **១៥,៦** | **១៨,៤** |
| **ឥណទេយ្យសុទ្ធចំពោះរដ្ឋាភិបាល** | **-១៧,១** | **-១២,៤** | **-៥៦,០** | **-៤៧,៥** | **-២៦,៨** | **-៣៥,៨** | **-២៨,០** |
| ឥណទេយ្យចំពោះរដ្ឋាភិបាល | ០,១ | ០,០ | ០,០ | ០,០ | -០,១ | ០,០ | -១០០,០ |
| ប្រាក់បញ្ញើរដ្ឋាភិបាល | ១៥,២ | ១១,២ | ៥១,០ | ៤៤,៧ | ២៥,៧ | ៣៤,៧ | ២៥,២ |
| **ផ្នែកមិនមែនរដ្ឋាភិបាល** | **៣៨,៣** | **១៧,៣** | **៣១,២** | **២៧,១** | **២២,៥** | **១៨,៥** | **២០,១** |
| ចំពោះសហគ្រាសរដ្ឋ | ១០០ | ១២៨,៧ | -១០០,០ | ០,០ | ០,០ | ០,០ | ២៥,១ |
| ចំពោះផ្នែកឯកជន | ៣៨,៣ | ១៧,៣ | ៣១,៣ | ២៧,១ | ២២,៥ | ១៨,៥ | ២០,១ |
| **ខ្ទង់ផ្សេងៗសុទ្ធ** | **៩,៦** | **២៥,៤** | **២០,៣** | **៩,១** | **២៨,៨** | **២០,៥** | **២២,៣** |
| ប្រាក់បញ្ញើរឹតត្បិត | ៥,៣ | ១៨,៨ | ១៥,៨ | ១៣,២ | ២៧,៥ | ២៤,៨ | ២២,៣ |
| ដើមទុន និងទុនបម្រុង | ១៨,៤ | ៥,៤ | ១៤,០ | ១១,៣ | ១៦,៤ | ២៧,៧ | ១៥,២ |
| ផ្សេងៗ | ១៣៨,៥ | -១២៧,៦ | ២០៨,៧ | -១៦,៩ | ២០៤,៩ | -២០,៥ | ៨៤,០ |
| **រូបិយវត្ថុទូទៅ (M2)** | **២១,០** | **១៤,៦** | **២៩,៩** | **១៤,៧** | **១៧,៩** | **២៣,៨** | ២២,៦ |
| **រូបិយវត្ថុ (M1)** | **២,៧** | **២០,៧** | **២៩,៦** | **៦,៧** | **៧,២** | **២៩,៦** | ៨,៤ |
| រូបិយវត្ថុក្រៅធនាគារ | ០,១ | ១៨,៧ | ២៦,០ | ៥,៣ | ៨,៩ | ២៨,២ | ១១,២ |
| ប្រាក់បញ្ញើចរន្ត | ៥៧,២ | ៤៦,៣ | ៦៨,៥ | ១៨,១ | -៥,៣ | ៤០,៩ | -១១,៧ |
| **រូបិយវត្ថុផ្សេងៗ** | **២៤,៧** | ១៣,៦ | ៣០,០ | ១៦,១ | ១៩,៦ | ២២,៩ | ២៤,៨ |
| ប្រាក់បញ្ញើមានកាលកំណត់និងសន្សំ | ៤០,០ | ២១,២ | ១៥,៣ | ៤២,២ | ៥៤,០ | ៩,៦ | ១៦,៨ |
| ប្រាក់បញ្ញើជារូបិយប័ណ្ណ | ២៤,៣ | ១៣,៤ | ៣០,៥ | ១៥,៣ | ១៨,៣ | ២៣,៦ | ២៥,១ |

*ក/.ទិន្នន័យកែសម្រួល*

**ទិន្នន័យព្យាករណ៍*

## VII-អនុសាសន៍លើផែនការសកម្មភាពការលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល

| ទិសដៅការតាមវិស័យ | រយៈពេលខ្លី(២០១៦-២០១៨) | រយៈពេលមធ្យម (២០១៩-២០២២) | រយៈពេលវែង (២០២២-២០២៥) | ស្ថាប័នអនុវត្ត/ពាក់ព័ន្ធ |
|---|---|---|---|---|
| គោលនយោបាយរូបិយវត្ថុនិងអត្រាប្តូរប្រាក់ | • អនុវត្តគោលនយោបាយរូបិយវត្ថុប្រកបដោយភាពទន់ភ្លន់និងប្រុងប្រយ័ត្នដើម្បីរក្សាស្ថិរភាពថ្លៃ ដោយគ្រប់គ្រងអត្រាអតិផរណា ឱ្យស្ថិតនៅក្នុងកម្រិតទាបសមស្រប | • អនុវត្តគោលនយោបាយរូបិយវត្ថុប្រកបដោយភាពទន់ភ្លន់និងប្រុងប្រយ័ត្នដើម្បីរក្សាស្ថិរភាពថ្លៃ ដោយគ្រប់គ្រងអត្រាអតិផរណាឱ្យស្ថិតនៅក្នុងកម្រិតទាបសមស្រប | • បន្តអនុវត្តគោលនយោបាយរូបិយវត្ថុប្រកបដោយភាពទន់ភ្លន់និងប្រុងប្រយ័ត្នដើម្បីរក្សាស្ថិរភាពថ្លៃ ដោយគ្រប់គ្រងអត្រាអតិផរណាឱ្យស្ថិតនៅក្នុងកម្រិតទាបសមស្រប | • ធនាគារជាតិនៃកម្ពុជា<br>• ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>• ក្រសួងស្ថាប័នពាក់ព័ន្ធ |
| | • រក្សាស្ថិរភាពអត្រាប្តូរប្រាក់រៀលនិងដុល្លារក្រោមរបបអត្រាប្តូរប្រាក់ស្ថិរភាពដោយបន្តធ្វើអន្តរាគមន៍លើទីផ្សារប្តូរប្រាក់ | • រក្សាស្ថិរភាពតម្លៃអត្រាប្តូរប្រាក់រៀលនិងដុល្លារក្រោមរបបអត្រាប្តូរប្រាក់ស្ថិរភាពដោយបន្តធ្វើអន្តរាគមន៍លើទីផ្សារប្តូរប្រាក់ | • ពិចារណាអនុញ្ញាតឱ្យអត្រាប្តូរប្រាក់ កាន់តែមានភាពបត់បែនតាមមូលដ្ឋានសេដ្ឋកិច្ច | |
| | • ពង្រឹងយន្តការកំណត់អត្រាការប្រាក់គោលរបស់ធនាគារកណ្តាល ដើម្បីផ្គត់ផ្គង់ និងស្រូបយកប្រាក់រៀលឱ្យកាន់តែមានប្រសិទ្ធភាព | • បន្តពង្រឹងយន្តការកំណត់អត្រាការប្រាក់គោល | • ប្រើប្រាស់អត្រាការប្រាក់គោល | |
| | • ពង្រឹងយន្តការដេញថ្លៃទិញ-លក់រូបិយប័ណ្ណឱ្យមានប្រសិទ្ធភាពនិងផ្អែកលើទីផ្សារ | • បន្តពង្រឹងយន្តការដេញថ្លៃទិញ-លក់រូបិយ-ប័ណ្ណឱ្យមានប្រសិទ្ធភាពនិងផ្អែកលើទីផ្សារ | • ធានាប្រសិទ្ធភាពក្នុងការធ្វើអន្តរាគមន៍លើទីផ្សារប្តូរប្រាក់ប្រកបដោយសុក្រឹត្យភាពស្របតាមការប្រែប្រួលនៃស្ថានភាពសេដ្ឋកិច្ច | |
| | • អភិវឌ្ឍឧបករណ៍ និងប្រតិបត្តិការគោលនយោបាយរូបិយវត្ថុជាប្រាក់រៀល | • បន្តអភិវឌ្ឍឧបករណ៍ និងប្រតិបត្តិការគោលនយោបាយរូបិយវត្ថុជាប្រាក់រៀល | • បន្តអភិវឌ្ឍឧបករណ៍ និងប្រតិបត្តិការគោលនយោបាយរូបិយវត្ថុជាប្រាក់រៀល | |
| គោលនយោបាយសារពើពន្ធ | • បង្កើនប្រសិទ្ធភាពនៃការប្រមូលពន្ធនិងធ្វើវិចារណកម្មចំណាយរដ្ឋ | • បន្តបង្កើនប្រសិទ្ធភាពនៃការប្រមូលពន្ធនិងធ្វើវិចារណកម្មចំណាយរដ្ឋ | • បន្តបង្កើនប្រសិទ្ធភាពនៃការប្រមូលពន្ធនិងធ្វើវិចារណកម្មចំណាយរដ្ឋ | • ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>• ធនាគារជាតិនៃកម្ពុជា<br>• ក្រសួងស្ថាប័នពាក់ព័ន្ធ |
| | • ដាក់កាតព្វកិច្ចលើការបង់ពន្ធគ្រប់ប្រភេទជាប្រាក់រៀល ។ ប្រភេទពន្ធដែលនៅសេសសល់ហើយបច្ចុប្បន្នត្រូវបានបង់ជារូបិយប័ណ្ណ គួរតែតម្រូវឱ្យបង់ជាប្រាក់រៀលវិញ | • បន្តតាមដានលើការអនុវត្តការកំណត់ និងទូទាត់ជាប្រាក់រៀលលើចំណូលនិងចំណាយរដ្ឋ | • ធានាថារាល់ចំណូលនិងចំណាយរបស់រដ្ឋលើប្រតិបត្តិការក្នុងស្រុកត្រូវបានធ្វើឡើងជាប្រាក់រៀលតែមួយគត់ | |
| | • កំណត់ការទទួលយកប្រាក់រៀលតែមួយគត់លើការទូទាត់ចំណូលលទ្ធកម្មនិងការចូលទ្រព្យរដ្ឋ | | | |
| | • ការទូទាត់ចំណាយសាធារណៈក្នុងស្រុកទាំងអស់ត្រូវធ្វើឡើងជាប្រាក់រៀលរួមទាំងការទូទាត់ដែលមានទំហំធំ ដូចជា ការទូទាត់សម្រាប់ការសាងសង់ ជាដើម | | | |
| | • សេវាសាធារណៈដែលផ្តល់ដោយស្ថាប័ន/ក្រុមហ៊ុន-សហគ្រាសសាធារណៈ ដូចជាថ្លៃសិក្សានៅសាកលវិទ្យាល័យ សេវាមន្ទីរពេទ្យ ជាដើម ត្រូវតែទូទាត់ជាប្រាក់រៀល | | | |

| | | | | |
|---|---|---|---|---|
| | • គាំទ្រប្រតិបត្តិការនិងការប្រកបមុខរបរអាជីវកម្មនានាដែលជារូបិយវត្ថុជាតិនៅក្នុងប្រទេសកម្ពុជាតាមមធ្យោបាយផ្សេងៗ | • គាំទ្រប្រតិបត្តិការនិងការប្រកបមុខរបរអាជីវកម្មនានាក្នុងប្រទេសកម្ពុជាដែលជារូបិយវត្ថុជាតិតាមមធ្យោបាយផ្សេងៗ | គាំទ្រប្រតិបត្តិការនិងការប្រកបមុខរបរអាជីវកម្មនានាក្នុងប្រទេសកម្ពុជាដែលជារូបិយវត្ថុជាតិតាមមធ្យោបាយផ្សេងៗ ពិសេស ការបន្ធូរបន្ថយអត្រាពន្ធ បើធៀបនឹងរូបិយប័ណ្ណបរទេស | |
| | • សិក្សាពីលទ្ធភាពដាក់អត្រាពន្ធខុសគ្នារវាងចំណូល ឬប្រាក់ចំណេញដែលទទួលបានក្នុងស្រុកជារៀល និងជារូបិយប័ណ្ណ | • អនុវត្តលទ្ធផលនៃការសិក្សាអំពីការដាក់អត្រាពន្ធលើចំណូលឬប្រាក់ចំណេញទទួលបានក្នុងស្រុកជារូបិយប័ណ្ណក្នុងកម្រិតសមស្រប ដែលមិនធ្វើឲ្យប៉ះពាល់ដល់ការប្រើប្រាស់ ការវិនិយោគ កំណើនសេដ្ឋកិច្ច ។ល។ | | |
| គោលនយោបាយពាណិជ្ជកម្ម | • បង្កើនផលិតភាព ដើម្បីជំរុញផលិតកម្មក្នុងស្រុក | • បន្តបង្កើនផលិតភាពដើម្បីជំរុញផលិតកម្មក្នុងស្រុក | • បន្តបង្កើនផលិតភាពដើម្បីជំរុញផលិតកម្មក្នុងស្រុក | •ក្រសួងពាណិជ្ជកម្ម<br>•ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>•ក្រសួងមហាផ្ទៃ<br>•ក្រសួងការងារនិងបណ្តុះ |
| | • បន្តធ្វើពិពិធកម្មទីផ្សារនិងផលិតផលនាំចេញដើម្បីបង្កើនផលិតកម្មក្នុងស្រុក | • បន្តធ្វើពិពិធកម្មទីផ្សារនិងផលិតផលនាំចេញដើម្បីបង្កើនផលិតកម្មក្នុងស្រុក | • បន្តធ្វើពិពិធកម្មទីផ្សារនិងផលិតផលនាំចេញដើម្បីបង្កើនផលិតកម្មក្នុងស្រុក | |
| | • ជូនដំណឹងពីការតម្រូវឱ្យថ្លៃទំនិញនិងសេវាត្រូវកំណត់និងដាក់តាំងថ្លៃជាប្រាក់រៀល | • ជំរុញថ្លៃទំនិញនិងសេវាត្រូវបានកំណត់និងដាក់តាំងថ្លៃជាប្រាក់រៀល | • ធានាថារាល់ការកំណត់និងដាក់តាំងថ្លៃត្រូវធ្វើឡើងជាប្រាក់រៀល | |

| | | | | |
|---|---|---|---|---|
| | • ជូនដំណឹងពីការតម្រូវឱ្យវិស័យឯកជនឲ្យធ្វើការទូទាត់ថ្លៃទំនិញនិងសេវានានាជាប្រាក់រៀល | • បន្តលើកទឹកចិត្តនិងជំរុញវិស័យឯកជនឲ្យធ្វើការទូទាត់ថ្លៃទំនិញនិងសេវានានាជាប្រាក់រៀល | • បន្តលើកទឹកចិត្តនិងជំរុញវិស័យឯកជនឲ្យធ្វើការទូទាត់ថ្លៃទំនិញនិងសេវានានាជាប្រាក់រៀល | បណ្តាល វិជ្ជាជីវៈ<br>•សភាពាណិជ្ជកម្ម<br>•ក្រសួងស្ថាប័នពាក់ព័ន្ធ |
| | • លើកទឹកចិត្តឱ្យការបើកប្រាក់ខែរបស់វិស័យឯកជននិងអង្គការក្រៅរដ្ឋាភិបាលនានាជាប្រាក់រៀល | • ជំរុញឱ្យការបើកប្រាក់ខែរបស់វិស័យឯកជននិងអង្គការក្រៅរដ្ឋាភិបាលនានាជាប្រាក់រៀល | • ធានាថារាល់ការបើកប្រាក់ខែទាំងអស់ត្រូវជាប្រាក់រៀល | |
| គោលនយោបាយហិរញ្ញវត្ថុនិងក្របខ័ណ្ឌបទប្បញ្ញត្តិប្រុងប្រយ័ត្ន | • អភិវឌ្ឍ ឬលើកទឹកចិត្តឱ្យមានការបង្កើតឧបករណ៍ហិរញ្ញវត្ថុថ្មីៗជារូបិយវត្ថុជាតិ | • អភិវឌ្ឍឬលើកទឹកចិត្តឱ្យមានការបង្កើតឧបករណ៍ហិរញ្ញវត្ថុថ្មីៗជារូបិយវត្ថុជាតិ | • អភិវឌ្ឍឬលើកទឹកចិត្តឱ្យមានការបង្កើតឧបករណ៍ហិរញ្ញវត្ថុថ្មីៗជារូបិយវត្ថុជាតិ | • ធនាគារជាតិនៃកម្ពុជា<br>• ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>• សមាគមធនាគារនៅកម្ពុជា<br>• សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា<br>• ក្រសួងស្ថាប័នពាក់ព័ន្ធ |
| | • លើកទឹកចិត្តនិងជំរុញឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុបង្កើនប្រតិបត្តិការជារូបិយវត្ថុជាតិ | • លើកទឹកចិត្តនិងជំរុញឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុបង្កើនប្រតិបត្តិការជារូបិយវត្ថុជាតិ | • លើកទឹកចិត្តនិងជំរុញឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុបង្កើនប្រតិបត្តិការជារូបិយវត្ថុជាតិ | |
| | • បង្កើនទំនាក់ទំនងប្រតិបត្តិការរវាងវិស័យធនាគារនិង វិស័យមីក្រូហិរញ្ញវត្ថុឱ្យកាន់តែជិតស្និទ្ធដើម្បីបង្កើនប្រតិបត្តិការរវាងគ្នាជារូបិយវត្ថុជាតិ | • បន្តពង្រឹងទំនាក់ទំនងប្រតិបត្តិការរវាងវិស័យធនាគារនិង វិស័យមីក្រូហិរញ្ញវត្ថុនិងរវាងគ្រឹះស្ថានធនាគារនិងអាជីវករប្តូរប្រាក់ឱ្យកាន់តែជិតស្និទ្ធដើម្បីឱ្យ វិស័យទាំងនេះមានលទ្ធភាពបង្កើនប្រតិបត្តិការរវាងគ្នាជារូបិយវត្ថុជាតិ | • បន្តពង្រឹងទំនាក់ទំនងប្រតិបត្តិការរវាងវិស័យធនាគារនិងវិស័យមីក្រូហិរញ្ញវត្ថុនិងរវាងគ្រឹះស្ថានធនាគារនិងអាជីវករប្តូរប្រាក់ឱ្យកាន់តែជិតស្និទ្ធដើម្បីឱ្យវិស័យទាំងនេះមានលទ្ធភាពបង្កើនប្រតិបត្តិរវាងគ្នាជារូបិយវត្ថុជាតិ | |
| | • ពិនិត្យឡើងវិញនូវក្របខ័ណ្ឌបទប្បញ្ញត្តិ ដែលជាឧបសគ្គដល់ការលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលនិងបញ្ចូលស្មារតីលើកកម្ពស់ការ | • បន្តពិនិត្យឡើងវិញនូវក្របខ័ណ្ឌបទប្បញ្ញត្តិដែលជាឧបសគ្គដល់ការលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលនិងបញ្ចូលស្មារតីលើកកម្ពស់ | • បន្តពិនិត្យឡើងវិញនូវក្របខ័ណ្ឌបទប្បញ្ញត្តិដែលជាឧបសគ្គដល់ការលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលនិងបញ្ចូលស្មារតី | |

| | | | | |
|---|---|---|---|---|
| | ប្រើប្រាស់ប្រាក់រៀលក្នុងក្របខ័ណ្ឌបទប្បញ្ញត្តិ | ការប្រើប្រាស់ប្រាក់រៀលក្នុងក្របខ័ណ្ឌបទប្បញ្ញត្តិ | លើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលក្នុងក្របខ័ណ្ឌបទប្បញ្ញត្តិ | |
| | • លើកទឹកចិត្តឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុបែងចែកសន្ទនីយភាពជាប្រាក់រៀលលើសទៅតាមសាខាដែលខ្វះខាត | • បន្តលើកទឹកចិត្តឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុបែងចែកសន្ទនីយភាពជាប្រាក់រៀលលើសទៅតាមសាខាដែលខ្វះខាត | • បន្តលើកទឹកចិត្តឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុបែងចែកសន្ទនីយភាពជាប្រាក់រៀលលើសទៅតាមសាខាដែលខ្វះខាត | |
| | • លើកកម្ពស់បរិយាប័ន្នហិរញ្ញវត្ថុឱ្យកាន់តែកើនឡើង | • បន្តលើកកម្ពស់បរិយាប័ន្នហិរញ្ញវត្ថុឱ្យកាន់តែកើនឡើង | • បន្តលើកកម្ពស់បរិយាប័ន្នហិរញ្ញវត្ថុឱ្យកាន់តែកើនឡើង | |
| | • សិក្សាលើលទ្ធភាពដាក់អត្រាខុសគ្នាលើអនុបាតសន្ទនីយភាពជារូបិយប័ណ្ណនិងរូបិយវត្ថុ | • បើស្ថានភាពអនុញ្ញាត ដាក់អត្រាខុសគ្នាលើអនុបាតសន្ទនីយភាពជារូបិយប័ណ្ណនិងរូបិយវត្ថុ | • ពិចារណាបង្កើនគម្លាតឱ្យកាន់តែខ្ពស់រវាងអនុបាតសន្ទនីយភាពជារូបិយប័ណ្ណ និងរូបិយវត្ថុ | |
| | • សិក្សាលើការបង្កើនការធ្វើសំវិធានធនលើឥណទានជារូបិយប័ណ្ណ | • បើស្ថានភាពអនុញ្ញាត បង្កើនការធ្វើសំវិធានធនលើឥណទានជារូបិយប័ណ្ណ | • ពិចារណាបង្កើនសំវិធានធនលើឥណទានជារូបិយប័ណ្ណ | |
| | • បង្កើនគម្លាតជាលំដាប់លើអត្រាប្រាក់បម្រុងកាតព្វកិច្ចលើប្រាក់បញ្ញើនិងកម្ចីផ្សេងៗជារូបិយប័ណ្ណនិងរូបិយវត្ថុជាតិ | • បន្តបង្កើនគម្លាតជាលំដាប់លើអត្រាប្រាក់បម្រុងកាតព្វកិច្ចលើប្រាក់បញ្ញើនិងកម្ចីផ្សេងៗជារូបិយប័ណ្ណនិងរូបិយវត្ថុជាតិ | • បន្តបង្កើនគម្លាតជាលំដាប់លើអត្រាប្រាក់បម្រុងកាតព្វកិច្ចលើប្រាក់បញ្ញើនិងកម្ចីផ្សេងៗជារូបិយប័ណ្ណនិងរូបិយវត្ថុជាតិ | |
| | • សិក្សាលើលទ្ធភាពក្នុងការកាត់បន្ថយបន្តិចម្តងៗ លើកម្រិតនៃស្ថានភាពចំហសុទ្ធនៃរូបិយប័ណ្ណធៀបនឹងមូលនិធិផ្ទាល់សុទ្ធរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ | • បើស្ថានភាពអនុញ្ញាត កាត់បន្ថយកម្រិតនៃស្ថានភាពចំហសុទ្ធនៃរូបិយប័ណ្ណធៀបនឹងមូលនិធិផ្ទាល់សុទ្ធរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវកាត់បន្ថយបន្តិចម្តងៗ | • ពិចារណាកាត់បន្ថយកម្រិតនៃស្ថានភាពចំហសុទ្ធនៃរូបិយប័ណ្ណធៀបនឹងមូលនិធិផ្ទាល់សុទ្ធរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវកាត់បន្ថយបន្តិចម្តងៗ | |
| | • បង្កើនមូលដ្ឋានក្នុងការដាក់ប្រាក់បម្រុងកាតព្វកិច្ចលើបំណុលជារូបិយប័ណ្ណដូចជាកម្ចីបរទេសនិងការដាក់ប្រាក់បញ្ញើរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុបរទេស | • បង្កើនអត្រាប្រាក់បម្រុងកាតព្វកិច្ចលើបំណុលជារូបិយប័ណ្ណដូចជាកម្ចីបរទេសនិងការដាក់ប្រាក់បញ្ញើរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុបរទេស | • បន្តបង្កើនអត្រាប្រាក់បម្រុងកាតព្វកិច្ចលើបំណុលជារូបិយប័ណ្ណដូចជាកម្ចីបរទេសនិងការដាក់ប្រាក់បញ្ញើរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុបរទេស | |
| | • សិក្សាលើលទ្ធភាពដាក់គម្លាតលើអនុបាតឥណទានធៀបនឹងតម្លៃ(LTV) រវាងកម្ចីជារៀល និងជារូបិយប័ណ្ណ | • លើកទឹកចិត្តឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុអនុវត្តគម្លាតលើអនុបាតឥណទានធៀបនឹងតម្លៃរវាងកម្ចីជារៀល និងជារូបិយប័ណ្ណ | • ជំរុញឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុអនុវត្តគម្លាតលើអនុបាតឥណទានធៀបនឹងតម្លៃរវាងកម្ចីជារៀល និងជារូបិយប័ណ្ណ | |
| ការអភិវឌ្ឍទីផ្សារប្តូរប្រាក់ | • អភិវឌ្ឍទីផ្សារប្តូរប្រាក់ជុំ ដែលក្នុងនោះធនាគារពាណិជ្ជមានតួនាទីចម្បង | • បន្តអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនៃទីផ្សារប្តូរប្រាក់ជុំ ដើម្បីធ្វើការផ្គូផ្គងតាមប្រព័ន្ធអេឡិចត្រូនិក និងបង្កើនប្រសិទ្ធភាពលើទីផ្សារប្តូរប្រាក់ | • បន្តអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនៃទីផ្សារប្តូរប្រាក់ជុំ ដើម្បីធ្វើការផ្គូផ្គងតាមប្រព័ន្ធអេឡិចត្រូនិក និងបង្កើនប្រសិទ្ធភាពលើទីផ្សារប្តូរប្រាក់ | • ធនាគារជាតិនៃកម្ពុជា<br>• ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>• ក្រសួងមហាផ្ទៃ ក្រសួងស្ថាប័នពាក់ព័ន្ធ |
| | • តម្រូវឱ្យអាជីវករប្តូរប្រាក់ធំៗមានរបាយការណ៍ហិរញ្ញវត្ថុ | • ពង្រឹងការអនុវត្តបទប្បញ្ញត្តិតម្រូវឱ្យអាជីវករប្តូរប្រាក់ទាំងអស់មានរបាយការណ៍ហិរញ្ញវត្ថុ | • ពង្រឹងការអនុវត្តបទប្បញ្ញត្តិតម្រូវឱ្យអាជីវករប្តូរប្រាក់ទាំងអស់មានរបាយការណ៍ហិរញ្ញវត្ថុ | |
| | • តម្រូវឱ្យអាជីវករប្តូរប្រាក់រាយការណ៍ប្រចាំថ្ងៃអំពីប្រតិបត្តិការប្តូរប្រាក់របស់ខ្លួន | • អភិវឌ្ឍប្រព័ន្ធរាយការណ៍របស់អាជីវករប្តូរប្រាក់អំពីប្រតិបត្តិការប្តូរប្រាក់និងប្រតិបត្តិការពាក់ព័ន្ធនានា | • បន្តអភិវឌ្ឍប្រព័ន្ធរាយការណ៍របស់អាជីវករប្តូរប្រាក់អំពីប្រតិបត្តិការប្តូរប្រាក់និងប្រតិបត្តិការពាក់ព័ន្ធនានា | |
| | • ពង្រឹងការត្រួតពិនិត្យនិងការផ្តល់របាយការណ៍ជាប្រចាំទាក់ទងនឹងប្រតិបត្តិការប្តូរប្រាក់ | • បន្តពង្រឹងការត្រួតពិនិត្យនិងការផ្តល់របាយការណ៍ជាប្រចាំទាក់ទងនឹងប្រតិបត្តិការប្តូរប្រាក់ | • បន្តពង្រឹងការត្រួតពិនិត្យនិងការផ្តល់របាយការណ៍ជាប្រចាំទាក់ទងនឹងប្រតិបត្តិការប្តូរប្រាក់ | |

| | | | | |
|---|---|---|---|---|
| | • លើកទឹកចិត្តឱ្យគ្រឹះស្ថានធនាគារដើរតួនាទីជា dealer/broker ក្នុងទីផ្សារប្តូរប្រាក់ ជាជាងជាភ្នាក់ងារប្តូរប្រាក់ និងចូលរួមក្នុងការដេញថ្លៃទិញ-លក់រូបិយប័ណ្ណ | • លើកទឹកចិត្តឱ្យគ្រឹះស្ថានធនាគារដើរតួនាទីជា dealer/broker ក្នុងទីផ្សារប្តូរប្រាក់ ជាជាងជាភ្នាក់ងារប្តូរប្រាក់ និងចូលរួមក្នុងការដេញថ្លៃទិញ-លក់រូបិយប័ណ្ណ | • លើកទឹកចិត្តឱ្យគ្រឹះស្ថានធនាគារដើរតួនាទីជា dealer/broker ក្នុងទីផ្សារប្តូរប្រាក់ ជាជាងជាភ្នាក់ងារប្តូរប្រាក់ និងចូលរួមក្នុងការដេញថ្លៃទិញ-លក់រូបិយប័ណ្ណ | |
| | • សិក្សាលទ្ធភាពអភិវឌ្ឍឧបករណ៍ហេជដ៍ជីងអត្រាប្តូរប្រាក់ (hedging facilities) ដូចជាប្រតិបត្តិការស្វប់រូបិយប័ណ្ណ (Foreign exchange swap) នៅក្នុងទីផ្សារប្តូរប្រាក់ | • បង្កើតក្របខ័ណ្ឌបទប្បញ្ញត្តិសមស្របចំពោះការអភិវឌ្ឍឧបករណ៍ហេជដ៍ជីងអត្រាប្តូរប្រាក់ (hedging facilities) | • អនុញ្ញាតឱ្យមានការអភិវឌ្ឍឧបករណ៍ហិចជីងអត្រាប្តូរប្រាក់ (hedging facilities) | |
| | • ដាក់ឱ្យប្រើប្រាស់នូវ Plateform សម្រាប់ជួញដូរតាមអេឡិចត្រូនិកក្នុងទីផ្សារប្តូរប្រាក់ | • បន្តអភិវឌ្ឍ Plateform សម្រាប់ជួញដូរតាមអេឡិចត្រូនិកក្នុងទីផ្សារប្តូរប្រាក់ | • បន្តអភិវឌ្ឍ Plateform សម្រាប់ជួញដូរតាមអេឡិចត្រូនិកក្នុងទីផ្សារប្តូរប្រាក់ឱ្យកាន់តែទំនើប | |
| | • ពង្រឹងទំនាក់ទំនងរវាងប្រតិបត្តិការគ្រឹះស្ថានធនាគារនិងអាជីវករប្តូរប្រាក់ដូចជាជំរុញឱ្យអាជីវករប្តូរប្រាក់បើកគណនីនៅគ្រឹះស្ថានធនាគារដើម្បីធ្វើប្រតិបត្តិការប្តូរប្រាក់របស់ខ្លួន | • បង្វែរគណនីអាជីវករប្តូរប្រាក់ពីធនាគារជាតិនៃកម្ពុជាទៅធនាគារពាណិជ្ជ<br>• តម្រូវឱ្យអាជីវករប្តូរប្រាក់ធ្វើប្រតិបត្តិការប្តូរប្រាក់ជុំតាមរយៈគ្រឹះស្ថានធនាគារ | | |
| ការអភិវឌ្ឍទីផ្សារអន្តរធនាគារនិងរូបិយវត្ថុ | • បន្តអភិវឌ្ឍ NCDs ជាពិសេសជាប្រាក់រៀលឱ្យកាន់តែមានភាពទាក់ទាញតាមរយៈការកំណត់អត្រាការប្រាក់និងលក្ខខណ្ឌដទៃទៀត | • បន្តអភិវឌ្ឍ NCDs ជាពិសេសជាប្រាក់រៀលឱ្យកាន់តែមានភាពទាក់ទាញតាមរយៈការកំណត់អត្រាការប្រាក់និងលក្ខខណ្ឌដទៃទៀត | • បន្តអភិវឌ្ឍឧបករណ៍បំណុលរយៈពេលខ្លីជាប្រាក់រៀលឱ្យកាន់តែទូលំទូលាយ | • ធនាគារជាតិនៃកម្ពុជា<br>• ក្រសួងសេដ្ឋកិច្ចនិង |

| | | | | |
|---|---|---|---|---|
| | • ដាក់ឱ្យអនុវត្តប្រតិបត្តិការប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា | • អនុវត្តគោលនយោបាយឥណទានជាប្រាក់រៀល ក្នុងករណីដែលទីផ្សារអន្តរធនាគារមិនទាន់សកម្មក្នុងការផ្តល់សន្ទនីយភាពជាប្រាក់រៀល | | ហិរញ្ញវត្ថុ<br>• ក្រសួងស្ថាប័នពាក់ព័ន្ធ |
| | • គាំទ្រនិងជំរុញឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុធ្វើប្រតិបត្តិការជាមួយគ្នា ។ | • គាំទ្រនិងជំរុញឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុធ្វើប្រតិបត្តិការជាមួយគ្នា ។ | • គាំទ្រនិងជំរុញឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុធ្វើប្រតិបត្តិការជាមួយគ្នា ។ | |
| | • សិក្សាពីលទ្ធភាពបោះផ្សាយប័ណ្ណរតនាគារជាប្រាក់រៀល | • ពិចារណាបោះផ្សាយប័ណ្ណរតនាគារជាប្រាក់រៀល | | |
| ការអភិវឌ្ឍទីផ្សារមូលបត្រ | • ពិចារណាបញ្ឈប់ការទូទាត់ជារូបិយប័ណ្ណលើការជួញដូរមូលបត្រសាជីវកម្ម | | | • ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>• គណៈកម្មការមូលបត្រកម្ពុជា<br>• ក្រសួងស្ថាប័នពាក់ព័ន្ធ |
| | • សិក្សាលើការបោះផ្សាយសញ្ញាប័ណ្ណរដ្ឋចារិកជាប្រាក់រៀល | • ពិចារណាបោះផ្សាយសញ្ញាប័ណ្ណរដ្ឋចារិកជាប្រាក់រៀល និងបង្កើនកាលវសានរបស់សញ្ញាប័ណ្ណរដ្ឋជាលំដាប់ | | |

| | | | | |
|---|---|---|---|---|
| ការអភិវឌ្ឍប្រព័ន្ធទូទាត់ | • ពង្រឹងសមត្ថភាពស្ថាប័នគ្រប់គ្រងនិងអភិវឌ្ឍប្រព័ន្ធទូទាត់ដើម្បីក្សាស្ថិរភាពហិរញ្ញវត្ថុ | • បន្តពង្រឹងសមត្ថភាពស្ថាប័នគ្រប់គ្រងនិងអភិវឌ្ឍប្រព័ន្ធទូទាត់ដើម្បីរក្សាស្ថិរភាពហិរញ្ញវត្ថុ | • បន្តពង្រឹងសមត្ថភាពស្ថាប័នគ្រប់គ្រងនិងអភិវឌ្ឍប្រព័ន្ធទូទាត់ដើម្បីរក្សាស្ថិរភាពហិរញ្ញវត្ថុ | • ធនាគារជាតិនៃកម្ពុជា<br>• ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>• សមាគមធនាគារនៅកម្ពុជា<br>• សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា<br>• ក្រសួងស្ថាប័នពាក់ព័ន្ធ |
| | • ពិចារណាដាក់បទប្បញ្ញត្តិដែលអំណោយផលដល់ការទូទាត់ជាប្រាក់រៀល ដូចជា៖ ការបង្កើនតម្លាភាពកម្រៃសេវាទូទាត់និងផាត់ទាត់រវាងប្រាក់រៀលនិងរូបិយប័ណ្ណ | • ពង្រឹងបទប្បញ្ញត្តិដែលអំណោយផលដល់ការទូទាត់ជាប្រាក់រៀល ដូចជា៖ ការបង្កើនតម្លាភាពកម្រៃសេវាទូទាត់និងផាត់ទាត់រវាងប្រាក់រៀលនិងរូបិយប័ណ្ណ | • បន្តពង្រឹងបទប្បញ្ញត្តិដែលអំណោយផលដល់ការទូទាត់ជាប្រាក់រៀល ដូចជា៖ ការបង្កើនតម្លាភាពកម្រៃសេវាទូទាត់និងផាត់ទាត់រវាងប្រាក់រៀលនិងរូបិយប័ណ្ណ | |
| | • អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធទូទាត់ដែលគាំទ្រប្រតិបត្តិការជាប្រាក់រៀលដូចជា ៖បន្តពង្រឹងប្រព័ន្ធទូទាត់តាមរយៈអេឡិចត្រូនិកជាប្រាក់រៀលនិង ៖តម្រូវឱ្យរាល់ម៉ាស៊ីន ATM ទាំងអស់ត្រូវមានសេវាជាប្រាក់រៀល | • ពិចារណាលើការដកចេញជាលំដាប់ពីម៉ាស៊ីន ATMs នូវក្រដាសប្រាក់ដុល្លារ ប្រភេទ ១០ដុល្លារ, ២០ដុល្លារជាបន្តបន្ទាប់ | • ពិចារណាលើការដកចេញពីម៉ាស៊ីន ATMs នូវក្រដាសប្រាក់ដុល្លារ ប្រភេទ ៥០ដុល្លារ និង ១០០ដុល្លារ | |
| | • អភិវឌ្ឍឧបករណ៍ទូទាត់ជាប្រាក់រៀលឱ្យកាន់តែសម្បូរបែបនិងចំណាយទាបដូចជាផ្តល់សេវាប័ណ្ណឥណទាននិងឥណពន្ធជាប្រាក់រៀលនិង | • អភិវឌ្ឍឧបករណ៍ទូទាត់ជាប្រាក់រៀលឱ្យកាន់តែសម្បូរបែបនិងចំណាយទាបដូចជា ផ្តល់សេវាប័ណ្ណឥណទាននិងឥណពន្ធជាប្រាក់រៀល | • អភិវឌ្ឍឧបករណ៍ទូទាត់ជាប្រាក់រៀលឱ្យកាន់តែសម្បូរបែបនិងចំណាយទាបដូចជា ផ្តល់សេវាប័ណ្ណឥណទាននិងឥណពន្ធជាប្រាក់រៀល | |
| | • ធ្វើឱ្យកាន់តែប្រសើរឡើងនូវគុណភាពនិងសោភ័ណ្ឌភាពក្រដាសប្រាក់រៀល | • ធ្វើឱ្យកាន់តែប្រសើរឡើងនូវគុណភាពនិងសោភ័ណ្ឌភាពក្រដាសប្រាក់រៀល | • ធ្វើឱ្យកាន់តែប្រសើរឡើងនូវគុណភាពនិងសោភ័ណ្ឌភាពក្រដាសប្រាក់រៀល | |
| | • សិក្សាលទ្ធភាពកាត់បន្ថយការប្រើប្រាស់សាច់ប្រាក់ក្នុងការទូទាត់ | • បន្ថយជាលំដាប់លើការប្រើប្រាស់សាច់ប្រាក់ក្នុងការទូទាត់ | • បន្ថយជាលំដាប់លើការប្រើប្រាស់សាច់ប្រាក់ក្នុងការទូទាត់ | |

| | | | | |
|---|---|---|---|---|
| | | • ពិចារណាតម្រូវឱ្យការទូទាត់តាមរយៈអេឡិចត្រូនិកនូវចំនួនទឹកប្រាក់ជាក់លាក់មួយសមស្រប ដើម្បីកាត់បន្ថយការប្រើប្រាស់សាច់ប្រាក់ | | |
| | • សិក្សាលទ្ធភាពក្នុងការបោះផ្សាយក្រដាសប្រាក់រៀលដែលមានតម្លៃខ្ពស់ | • ពិចារណាបោះផ្សាយក្រដាសប្រាក់រៀល ដែលមានតម្លៃធំខ្ពស់ ដើម្បីសម្រួលដល់ការទូទាត់ដែលមានទំហំធំៗ | • សិក្សាលើកំណែទម្រង់តម្លៃរូបិយវត្ថុ ដោយធ្វើការកាត់លេខសូន្យ ចំនួនពីរខ្ទង់ (០០)ចេញពីក្រដាសប្រាក់គ្រប់ប្រភេទ | |
| ការលើកកម្ពស់ការយល់ដឹងនិងការទទួលយក | • បន្តបង្កើនការផ្សព្វផ្សាយអំពីយុទ្ធសាស្ត្រលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល និងអត្ថប្រយោជន៍នៃការប្រើប្រាស់ប្រាក់រៀលតាមរយៈ ប្រព័ន្ធផ្សព្វផ្សាយ សិក្ខាសាលាឬវេទិកាសាធារណៈនានា | • បន្តបង្កើនការផ្សព្វផ្សាយអំពីយុទ្ធសាស្ត្រលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល និងអត្ថ-ប្រយោជន៍នៃការប្រើប្រាស់ប្រាក់រៀលតាមរយៈ ប្រព័ន្ធផ្សព្វផ្សាយ សិក្ខាសាលាឬវេទិកាសាធារណៈនានា | • បន្តបង្កើនការផ្សព្វផ្សាយអំពីយុទ្ធសាស្ត្រលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល និងអត្ថប្រយោជន៍នៃការប្រើប្រាស់ប្រាក់រៀលតាមរយៈប្រព័ន្ធផ្សព្វផ្សាយ សិក្ខាសាលាឬវេទិកាសាធារណៈនានា | • ក្រសួងព័ត៌មាន<br>• ក្រសួងអប់រំ<br>• ក្រសួងស្ថាប័នពាក់ព័ន្ធ |
| | • លើកទឹកចិត្តឱ្យសាធារណជនរួមចំណែកអនុវត្តវិធានការនានាដែលអាចធ្វើបានចំពោះការលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល | | | |
| | • ប្រឹក្សាជាមួយវិស័យឯកជន រួមមាន សមាគមធនាគារនៅកម្ពុជា សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា សភាពាណិជ្ជកម្មជាដើមដែលមានសារៈសំខាន់ក្នុងការលើកទឹកចិត្តឱ្យឯកជនឱ្យទទួលយកកាន់តែសកម្ម | | | |

| | | | | |
|---|---|---|---|---|
| | • បញ្ចូលក្នុងកម្មវិធីសិក្សាអំពីសារៈសំខាន់នៃការប្រើប្រាស់រូបិយវត្ថុជាតិ | | | |
| កិច្ចសហប្រតិបត្តិការដើម្បីអនុវត្តផែនការយុទ្ធសាស្ត្រ | • បង្កើតក្រុមការងារអន្តរក្រសួងដើម្បីជំរុញតាមដាននិងលើកសំណើក្នុងការធ្វើឱ្យកាន់តែមានប្រសិទ្ធភាពចំពោះការអនុវត្តគោលនយោបាយនៅតាមវិស័យនីមួយៗដែលពាក់ព័ន្ធ | • បង្កើនកិច្ចសហប្រតិបត្តិការ និងការចូលរួមពីសំណាក់ភាគីពាក់ព័ន្ធ | • បង្កើនកិច្ចសហប្រតិបត្តិការ និងការចូលរួមពីសំណាក់ភាគីពាក់ព័ន្ធ | • ធនាគារជាតិនៃកម្ពុជា<br>• ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>• ក្រសួងស្ថាប័នពាក់ព័ន្ធ |
| | | • ពិនិត្យ តាមដាន និងវាយតម្លៃលើការអនុវត្តគោលនយោបាយ និងវិធានការលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល | • ពិនិត្យ តាមដាន និងវាយតម្លៃលើការអនុវត្តគោលនយោបាយ និងវិធានការលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល | |
| គោលនយោបាយគាំទ្រ | • ពិនិត្យឡើងវិញនូវក្របខ័ណ្ឌច្បាប់និងបទប្បញ្ញត្តិនៅក្នុងវិស័យនានាដែលជាឧបសគ្គក្នុងការលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល | • ធ្វើបច្ចុប្បន្នកម្មក្របខ័ណ្ឌច្បាប់និងបទប្បញ្ញត្តិនៅក្នុងវិស័យនានា ដើម្បីអំណោយផលដល់ការប្រើប្រាស់ប្រាក់រៀល | • បន្តបញ្ជ្រាបយុទ្ធសាស្ត្រលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលនៅក្នុងក្របខ័ណ្ឌច្បាប់និងបទប្បញ្ញត្តិនៅក្នុងវិស័យនានា | • ធនាគារជាតិនៃកម្ពុជា<br>• ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>• ក្រសួងពាណិជ្ជកម្ម<br>• ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា<br>• ក្រសួងស្ថាប័នពាក់ព័ន្ធ |
| | • ជំរុញឱ្យក្រុមហ៊ុនសហគ្រាសរៀបចំរបាយការណ៍ ហិរញ្ញវត្ថុជាប្រាក់រៀល | • ជំរុញឱ្យក្រុមហ៊ុនសហគ្រាសរៀបចំរបាយការណ៍ហិរញ្ញវត្ថុជាប្រាក់រៀល | • តម្រូវឱ្យក្រុមហ៊ុនសហគ្រាសរៀបចំរបាយការណ៍ហិរញ្ញវត្ថុជាប្រាក់រៀល | |
| | • លើកទឹកចិត្តវិនិយោគិនឱ្យប្រើប្រាស់ប្រាក់រៀលចាប់ពីពេលដែលស្នើសុំធ្វើការវិនិយោគ ក៏ដូចជាក្នុងអំឡុងពេលបាននិងកំពុងវិនិយោគនៅកម្ពុជា | • លើកទឹកចិត្តនិងជំរុញវិនិយោគិនឱ្យប្រើប្រាស់ប្រាក់រៀលចាប់ពីពេលដែលស្នើសុំធ្វើការវិនិយោគ ក៏ដូចជាក្នុងអំឡុងពេលបាននិងកំពុងវិនិយោគនៅកម្ពុជា | • លើកទឹកចិត្តនិងជំរុញវិនិយោគិនឱ្យប្រើប្រាស់ចាប់ពីពេលដែលស្នើសុំធ្វើការវិនិយោគ ក៏ដូចជាក្នុងអំឡុងពេលបាននិងកំពុងវិនិយោគនៅកម្ពុជា | |
| | • សិក្សាពីការបង្កើតគម្រោងសន្សំខ្នាតតូចជាប្រាក់រៀលដែលគ្រប់គ្រងដោយរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ | • បង្កើតក្របខ័ណ្ឌបទប្បញ្ញត្តិសម្រាប់គ្រប់គ្រងគម្រោងសន្សំខ្នាតតូចជាប្រាក់រៀល | • អភិវឌ្ឍគម្រោងសន្សំខ្នាតតូចជាប្រាក់រៀលនិងពង្រីកជាលំដាប់នូវការអនុវត្តការដាក់គម្រោងនេះទូទាំងប្រទេស | |
| | | • សិក្សាលើការដាក់កំហិតលើការកាន់រូបិយប័ណ្ណដោយភ្នាក់ងារដែលមិនមានប្រតិបត្តិការជាមួយភ្នាក់ងារនៅក្រៅប្រទេស (the rest of the world) | • ពិចារណាដាក់កំហិតលើការកាន់រូបិយប័ណ្ណដោយភ្នាក់ងារជាក់លាក់មួយចំនួនដែលមិនមានប្រតិបត្តិការជាមួយភ្នាក់ងារនៅក្រៅប្រទេស (the rest of the world) | |
| | • សិក្សាលើការបង្កើតប្រព័ន្ធធានារ៉ាប់រងលើប្រាក់បញ្ញើជាប្រាក់រៀល | • បង្កើតក្របខ័ណ្ឌច្បាប់ និងបទប្បញ្ញត្តិដើម្បីគាំទ្រចំពោះការបង្កើតប្រព័ន្ធធានារ៉ាប់រងលើប្រាក់បញ្ញើ | • បង្កើតប្រព័ន្ធធានារ៉ាប់រងលើប្រាក់បញ្ញើជារៀល | |
| | • ផ្សព្វផ្សាយវិធានការតម្រូវឱ្យសហគ្រាស/ក្រុមហ៊ុនបើកគណនីជូននិយោជិករបស់ខ្លួននៅគ្រឹះស្ថានធនាគារ ដើម្បីបើកប្រាក់បៀវត្សរ៍តាមប្រព័ន្ធធនាគារ | • តម្រូវឱ្យសហគ្រាស/ក្រុមហ៊ុនខ្នាតធំនិងមធ្យមបើកគណនីជូននិយោជិកដែលមានកម្រិតប្រាក់ខែចាប់ពីកម្រិតណាមួយខ្ពស់សមស្រប (ឧទាហរណ៍ ៨០០.០០០ រៀលក្នុង១ខែ) ដើម្បីបើកប្រាក់បៀវត្សរ៍តាមប្រព័ន្ធធនាគារ | • តម្រូវឱ្យសហគ្រាស/ក្រុមហ៊ុនទាំងអស់បើកគណនីជូននិយោជិក ដើម្បីទូទាត់ប្រាក់បៀវត្សរ៍ជាប្រាក់រៀល | |

- កំណត់ចំណាំ៖ នៅក្នុងគោលនយោបាយនីមួយៗ មានក្រសួង ស្ថាប័នទទួលបន្ទុកដឹកនាំអនុវត្ត (Leading agencies) និងក្រសួង ស្ថាប័នពាក់ព័ន្ធនឹងការអនុវត្តគោលនយោបាយនេះ ។
- ពណ៌ខៀវ ៖ ការងារដែលបានធ្វើ
- ពណ៌ក្រហម៖ ការងារដែលបាននិងកំពុងធ្វើ